OLD VERSION

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Feb-2015, 11:26
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី២៣៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវិន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

លោក ត្រាវិស ហ្វារ *(Mr. Travis FARR)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក សួន វិសាល

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេា ជុនធី

លោក វ៉ែន ពៅ

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JAQUIN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ត្រាវិស ហ្វារ | អង់គ្លេស |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក កែវ ច័ន្ទតារ៉ា (2-TCW-964) | ខ្មែរ |
| លោក សយ សែន ((2-TCCP-271) | ខ្មែរ |

# ឧបសម្ព័ន្ធ


**ការសួរសំណួរទៅសាក្សី÷ លោក កែវ ចំនួតារ៉ា** (2-TCW-964)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ....................ទំព័រ ៣

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី....................ទំព័រ ១១

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី....................ទំព័រ ១៣

សួរដោយលោក គង់ សំអុន ផ្តើមពី ....................ទំព័រ ១៥

**ការសួរសំណួរទៅសាក្សី÷ លោក សយ សែន** (2-TCCP-271)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................ទំព័រ ៣០

សួរដោយលោកស្រី ម៉ុច សុវណ្ណារី ផ្តើមពី ....................ទំព័រ ៣៣

សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង ផ្តើមពី....................ទំព័រ ៤៧

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី ....................ទំព័រ ៥៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មសាក្សី កែវ ច័ន្ទតារ៉ា បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-271 ហើយកត់សម្គាល់ថា នៅថ្ងៃនេះ សាក្សីបានស្នើសុំជំនួយពីបុគ្គលិកអង្គការធី.ភី.អូ ដើម្បីជួយពង្រឹងស្មារតីគាត់ក្នុងអំឡុងពេលដែលគាត់ផ្តល់សក្ខីកម្ម។

លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការក្នុងថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន លើកលែងតែលោក អាកទូរ វែកគែន មេធាវីអន្តរជាតិការពារក្តីឲ្យលោក ខៀវ សំផន អវត្តមានដោយសារមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយសារមូលហេតុសុខភាព។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក កែវ ច័ន្ទតារ៉ា លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សាលសវនាការ។ រីឯដើមបណ្តឹងរដ្ឋបប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ គឺដើមបណ្តឹងដែលមានរហស្សនាម 2-TCCP-271។ ដើមបណ្តឹងរូបនេះ មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក សុន អរុណ!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ដោយយោងទៅតាមលិខិតរបស់ពេទ្យប្រចាំការនៅ អ៊ី.ស៊ី.ស៊ី.ស៊ី នេះ លោក នួន ជា គាត់មានការឈឺចង្កេះខ្លាំងជាងរាល់ដង ហើយម្ល៉ោះ

ហើយគាត់សូមសម្រាកនៅខាងក្រោម ចាំគាត់នឹងស៊ីញេក្រដាសសូមអនុញ្ញាតហ្នឹងនៅពេលក្រោយបន្តិចទៀត ឥឡូវខ្ញុំធ្វើអត់ទាន់ជូនគាត់ចុះហត្ថលេខា។ រាល់ដឹងធ្វើលិខិតជាភាសាអង់គ្លេស និងខ្មែរ ជូនទៅខាងក្រឡាបញ្ជី ប៉ុន្តែលើកនេះធ្វើមិនទាន់ ប្រហែលជាដល់ពេលសម្រាកនឹងធ្វើជូន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី។

បាទ អង្គជំនុំជម្រះបានស្ដាប់សំណើសុំរបស់លោក នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ សូមនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈសោតទស្សន៍សម្រាប់រយៈពេលសវនាការថ្ងៃនេះ ហើយដោយលោក នួន ជា លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ហើយក្រុមមេធាវីការពារក្ដីបានសន្យាថានឹងប្រគល់មកឲ្យអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ នួន ជា យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងកំណត់ហេតុពិនិត្យសុខភាពរបស់វេជ្ជបណ្ឌិតទទួលបន្ទុកពិនិត្យថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ ហើយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។

[០៩:០៧:៣៣]

ហើយអង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់ជូនមកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខាឬផ្ដិតស្នាមម្រាមដៃយ៉ាងច្បាស់លាស់របស់លោក នួន ជា ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ពេញ១ថ្ងៃនេះ។

បាទ ជាបន្តអង្គជំនុំជម្រះ សូមផ្ដល់វេទិកា -- បាទវេទិកាជូនទៅចៅក្រម ចៅក្រមអាចមានបំណងចង់សួរសាក្សីរូបនេះ។

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍! ហើយមន្ត្រីរដ្ឋបាលតុលាការយកឯកសារជាក្រដាស ដែលដាក់បង្ហាញចំពោះសាក្សីកាលពីថ្ងៃមុនឲ្យគាត់ពិនិត្យបន្តទៀត។

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ មុននឹងបន្តផ្តល់វេទិកាទៅមេធាវីការពារក្តី ខ្ញុំមានសំណួរសួរទៅលោក កែវ ច័ន្ទតារ៉ា។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** បាទ លោកសាក្សី លោកស្តាប់ខ្ញុំឮទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ស្តាប់បានឮហើយទាន។

**ស៖** បាទ សូមអរគុណលោកសាក្សី ដែលបានត្រឡប់មកផ្តល់សក្ខីកម្មនៅថ្ងៃនេះ។ បាទ ជាបឋមខ្ញុំសូមចោទសំណួរទាក់ទងទៅនឹងសមាជិកបុគ្គលិកនៅមន្ទីរសន្តិសុខក្រាំងតាចាន់ នៅពេលដែលលោកជាប់ឃុំឃាំងនៅទីនោះ។ លោកបាននិយាយថា មន្ទីរនោះត្រូវបានដឹកនាំដោយអាចារ្យ ឆេន ហើយលោកក៏បាននិយាយពីអនុប្រធានគាត់ផងដែរ។ តើលោកអាចផ្តល់ការបញ្ជាក់បំភ្លឺបន្ថែមទៀតទេថា មានសមាជិកប៉ុន្មាននាក់? បុគ្គលិកប៉ុន្មាននាក់? មានអ្នកយាមប៉ុន្មាននាក់ដែរ? ហើយរចនាសម្ព័ន្ធមន្ទីរសន្តិសុខនោះយ៉ាងម៉េចដែរ?

[០៩:១០:០៦]

**ឆ៖** សមាជិកបុគ្គលិកនៅក្នុងមន្ទីរឃុំឃាំងក្រាំងតាចាន់ ខ្ញុំមិនបានស្គាល់អស់ទេទាន ហើយក៏មិនបានរាប់ឲ្យគ្រប់ចំនួនថាមានប៉ុណ្ណោះប៉ុណ្ណោះអីដែរ។ ខ្ញុំស្គាល់តែអាចារ្យ ឆេន មួយដែលជាអ្នកសាកសួរផ្ទាល់ ហើយនិងម្នាក់ទៀតឈ្មោះ ដាំ មិនដឹងត្រកូលអីទេ ដែលជាអ្នកវាយសម្លាប់។ ឯអ្នកដែលជួយវាយសម្លាប់ខ្លះទៀត ក៏ខ្ញុំអត់ស្គាល់គេដែរ។

**ស៖** បើលោកមិនស្គាល់ឈ្មោះគាត់ទេ អ៊ីចឹងអាចផ្តល់ចំនួនបុគ្គលិកអ្នកដែលធ្វើការនៅមន្ទីរសន្តិសុខហ្នឹងបានទេ? អត់ស្គាល់ឈ្មោះក៏អត់ទៅ តែចំនួន?

**ឆ៖** ហ្នឹងក៏ខ្ញុំមិនបានដឹងចំនួនថាប៉ុន្មានដែរ។

**សៈ** បាទ លោកបាននិយាយថា អង្គាល់ដែលលោកនៅជាប់ឃុំនៅទីនោះ គឺថាលោកធ្លាប់ធ្វើការងារមួយចំនួន កិច្ចការមួយចំនួនសម្រាប់មន្ទីរសន្តិសុខនោះ។ ឧទាហរណ៍បើសិនជាខ្ញុំមិនច្រឡំទេ លោកបានប្រាប់ថា លោកបានលើកអូសសាកសព ហើយយកទៅកប់។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ពិតប្រាកដណាស់ ដែលយើងបានអូសសាកសពយកទៅកប់នោះ។ ហើយអ្នកដែលជួយអូសសាកសពយើងនោះ បើសាកសពនោះច្រើន មានគ្នាជាង១០នាក់ទៅអូស។ សាកសពនោះតិច មានគ្នាប្រាំពីរប្រាំបីនាក់អ៊ីចឹងទៅ។ តែចំនួនទាំងអស់នៅក្នុងមន្ទីរនោះ យើងអត់បានដឹងទេ សូមទោស។

[០៩:១២:១៥]

**សៈ** តើគេឲ្យលោកធ្វើការងារផ្សេងទៀតទេ ទោះបីជានៅក្នុងមន្ទីរសន្តិសុខហ្នឹងក៏ដោយ នៅក្រៅក៏ដោយ គេមានឲ្យលោកធ្វើការងារអីផ្សេងពីហ្នឹងទេ?

**ឆៈ** ការងាររបស់ខ្ញុំ ក្រោយពីជាប់បាន១០ថ្ងៃជាង គ្រាន់តែជញ្ជូនអាចម៍ដែលអ្នកទោសអាចម៍ដាក់នៅក្នុងពេលជាប់ខ្នោះហ្នឹង យកទៅចាក់ក្នុងពាង ហើយនិងទឹកនោមតែប៉ុណ្ណឹងទេ។

**សៈ** តើលោកជាអ្នកទោសតែម្នាក់គត់ដែលគេឲ្យធ្វើការងាររបៀបហ្នឹង ឬក៏មានអ្នកទោសផ្សេងទៀតដែលធ្វើការងារផ្សេង? ឧទាហរណ៍ដូចជាធ្វើការនៅក្នុងផ្នែកផ្សេងៗ ឧទាហរណ៍ដូចនៅខាងចុងភៅអីជាដើមនោះ។

**ឆៈ** កន្លែងចុងភៅ កុំថាឡើយអ្នកទោសទៅបៀតបានអី ទៅធ្វើការអី គេមិនដែលឲ្យយើងឆ្លងកាត់ទៅទីនោះទេ ត្រឹមតែយកអាចម៍ទឹកនោមទៅចោលនៅក្នុងពាងដែលគេទុកពាងបីនៅកន្លែងខាងជើងហ្នឹង គឺគ្មានធ្វើការអីទៀតទេអ្នកទោស។

**សៈ** តើលោកបានឃើញ ឬក៏លោកបានចាំថាឃើញក្មេងៗ ឬក៏មនុស្សជំទង់ដែលធ្វើការនៅមន្ទីរសន្តិសុខក្រាំងតាចាន់ហ្នឹងទេ?

**ឆៈ** យើងឃើញសន្តិសុខដែលនៅមន្ទីរក្រាំងតាចាន់នោះ មិនមែនមនុស្សចាស់ទេ គឺច្រើនតែពួកក្មេង។

[០៩:១៤:២៨]

**សៈ** តើមានក្មេងៗដែលធ្វើការបោសសម្អាត ឬក៏ទៅធ្វើការនៅខាងក្រៅៗមន្ទីរសន្តិសុខ ឧទាហរណ៍ដូចជា ទៅឃ្វាលគោឃ្វាលក្របីអីជាដើម តើមានទេ?

**ឆៈ** អ្នកដែលគេទុកចិត្តខ្លាំង គេមានដកមនុស្សខ្លះចេញពីខ្នោះនេះ តែយប់ឡើងនៅតែគេយក

មកដាក់ខ្នោះដដែល ឲ្យទៅឃ្វាលគោ មានខ្លះដែរ។

**ស៖** បាទ ចំពោះលោកផ្ទាល់ហ្នឹង តើគេមានដោះខ្នោះចេញពីលោកទេ ពេលថ្ងៃនោះលោក? មានគេធ្វើយ៉ាងម៉េចដែរ ចំពោះលោក?

**ឆ៖** ថ្ងៃដូចយប់ យប់ដូចថ្ងៃ អ្នកដែលជាប់នៅក្នុងខ្នោះនោះ គេមិនដែលដោះចេញក្រៅពីគេប្រើយើងឲ្យទៅធ្វើការ។ ដោយឡែករូបខ្ញុំ បានរួចខ្លួនពីខ្នោះនេះតែពេលជញ្ជូនអាចម៍ និងទឹកនោមយកទៅចាក់ទុកណោះប៉ុណ្ណោះទេ។

[០៩:១៦:០០]

**ស៖** បាទ ឥឡូវខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងទៅនឹងទស្សនកិច្ចមួយដែលលោកបានលើកឡើង គឺទស្សនកិច្ចរបស់លោក នួន ជា ខណៈលោក នួន ជា គាត់មកមើលមន្ទីរសន្តិសុខក្រាំងតាចាន់។ តើលោកចាំប្រហាក់ប្រហែលទេគឺថា ពេលនុ៎ងគឺថាពេលដែលលោកទើបនឹងជាប់ឃុំឃាំងនៅហ្នឹង ឬក៏ពេលចុងក្រោយទៀតលោកចេញហើយ ឬក៏មុនពេលការរំដោះប្រទេសជាតិ ឬក៏ក្រោយពេលរំដោះប្រទេសជាតិ?

**ឆ៖** តាជា ទៅទីនោះគឺមិនទាន់រំដោះទេ ពីព្រោះខ្ញុំអត់ទាន់ឃើញមនុស្សដែលចេញពីពួក លន់ នល់ ទៅដល់ក្រាំងតាចាន់ទេ តាជា ទៅទីនោះ។

**ស៖** លោកជាអ្នកឃើញដោយផ្ទាល់ពេលគាត់មកដល់ហ្នឹង ឬក៏លោកបានឮគេនិយាយប្រាប់ទេ?

**ឆ៖** ពេល តាជា ចូលទៅក្នុងមន្ទីរក្រាំងតាចាន់នោះ យើងនៅជាប់ខ្នោះជើងនៅឡើយ តែកម្មាភិបាលខ្លះដែលគេធ្លាប់ធ្វើការ គេស្គាល់ តាជា គេថា "នោះ តាជា អញ្ជើញមកហើយ"។ យើងមើលឃើញចម្ងាយប្រហែលជា ៧០ ទៅ ៨០ម៉ែត្រ។ ខំសម្លឹងដើម្បីចង់ឲ្យស្គាល់ តាជា ហ្នឹងដែរ ព្រោះឮគេថា តាជា មិនដែលស្គាល់មុខគាត់។ យើងមើលតាមប្រហោងជញ្ជាំង តែខ្ញុំមើលតាមប្រឡោះទ្វារ។

**ស៖** លោកអាចបញ្ជាក់អំពីចម្ងាយបានទេ តើនៅជិត ឬនៅឆ្ងាយ? នៅកន្លែងណា លោកឃើញ នួន ជា ហ្នឹងយ៉ាងម៉េចដែរ? តាមរបៀបណា?

[០៩:១៨:២៨]

**ឆ៖** ខ្ញុំជម្រាបហើយថា ខ្ញុំប្រមាណពីគុកទៅកន្លែង តាជា ប្រហែលជា ៧០ ឬ ៧០ម៉ែត្រ។

**ស៖** តើលោកចាំពីចំនួនបុគ្គលិកដែលប្រាប់លោកថា នុ៎ង ហើយ តាជា នៅៗ -- គាត់មកមើល

នោះ។ តើអ្នកណាគេអ្នកបានប្រាប់លោក អ្នកប្រាប់លោកថា គាត់មកនោះ?

**ឆ៖** អ្នកដែលប្រាប់នោះគឺបាត់រហូតតាំងពី មិនដឹងជាគេស្លាប់ ឬគេរស់ទេ ពេលខ្ញុំចេញពីមន្ទីរឃុំឃាំងនោះមក គឺអត់ដែលបានជួបគេរហូត។ ហើយក៏ពេលដែលជាប់នោះ គ្រាន់តែដឹងថាគេហ្នឹងជាកម្មាភិបាលរបស់ពួកខ្មែរក្រហមដែរ តែក៏មិនដឹងគេឈ្មោះអីទេ។

**ស៖** ពួកគាត់ជាអ្នកយាម ឬក៏ជាអ្នកទោសដែរទេ ដែលគាត់ប្រាប់លោកថា គាត់មកមើលនេះ?

**ឆ៖** អ្នកដែលជាប់គុកជាមួយគ្នា អ្នកដែលជាប់ខ្នោះជាប់គ្នាហ្នឹង។

[០៩:២០:១៣]

**ស៖** ហើយលោកចាំឈ្មោះពួកគាត់ទេ? អ្នកទោសហ្នឹងឈ្មោះអីដែរ? ហើយអង្គាល់ណោះគាត់មានមុខងារអីដែរ?

**ឆ៖** យើងអត់ដែលស្គាល់គេពីមុនមកទេ ក្នុងពេលដែលមកជាប់ជាមួយគ្នាហ្នឹង ក៏យើងអត់បានសួរឈ្មោះគេដែរ មិនដឹងគេឈ្មោះអីទេ។

**ស៖** អ៊ីចឹង អ្នកទោសដែលនៅជាមួយលោកនោះគាត់បានថា តាមប្រឡោះជញ្ជាំងហ្នឹងបានប្រាប់ថា "នុ៎ងហើយជា តាជា"។ អ៊ីចឹងមែនទេតាមចន្លោះប្រហោងជញ្ជាំងហ្នឹង?

**ឆ៖** បាទ គេប្រាប់ថា "នោះអ្នកដើរមកចង្អុលខ្វែងខ្វាត់ហ្នឹងគឺ តាជា" តែក៏អត់ពេលនិយាយពីថា តានួន ជា អីអ៊ីចឹងក៏អត់ដែរ អត់មាននិយាយត្រកូលទេគឺថានិយាយតែឈ្មោះ តាជា។

**ស៖** ហើយចំពោះលោកផ្ទាល់ហ្នឹង តើ តាជា ហើយនិង នួន ជា នេះអង្គាល់នោះចំពោះលោកនោះ គឺមនុស្សតែមួយទេ ឬក៏មនុស្សពីរនាក់ផ្សេងគ្នា?

**ឆ៖** ខ្ញុំមិនស្គាល់ តាជា ទាំងបច្ចុប្បន្ននេះ តាំងពីអតីតមកគឺមិនដឹងថា តាជា ហ្នឹង ជា ណានោះទេ។

[០៩:២១:៥៧]

**ស៖** លោកបានប្រាប់ផងដែរថា លោកបានជួប នួន ជា ជាលើកទី២ គឺលោកបានប្រាប់ថាកាលនោះគឺមានការបញ្ចាំងខ្សែភាពយន្តមួយ ហើយនិងការសម្តែងសៀកចិន។ ហើយសំណួរខ្ញុំសួរថាតើលោកនៅរក្សាចម្លើយរបស់លោកទេ?

**ឆ៖** បាទ ខ្ញុំអត់ភ្លេចសោះពីព្រោះ តាជា ហ្នឹងឡើងថ្លែងសុន្ទរកថាខ្លីមួយ ហើយខ្ញុំចាំពាក្យគាត់តែពីរបីម៉ាត់ប៉ុណ្ណោះទេថា "ប្រទេសកម្ពុជាយើងសព្វថ្ងៃនេះជាប្រទេសកសិកម្ម ឥឡូវនេះ យើងកែប្រែ

ឲ្យក្លាយឲ្យទៅជាកសិឧស្សាហកម្ម”។ ខ្ញុំចាំពាក្យគាត់តែប៉ុណ្ណឹង។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថា ការបញ្ចាំងខ្សែភាពយន្ត ហើយនិងសម្ដែងសៀកនេះបានកើតឡើងនៅពេលណាដែរ ប្រហាក់ប្រហែល?

**ផ៖** អត់មានបញ្ចាំងខ្សែភាពយន្តទេ សម្ដែងសៀក។ តែខ្ញុំក៏អត់ដឹងថ្ងៃខែឆ្នាំអីដែរ ចាំមិនបានទេអាហ្នឹងនោះ។

[០៩:២៣:៤៨]

**ស៖** នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានសួរចម្លើយលោក ឬក៏ឯកសារ E3/5153 ERN ជាភាសាបារាំងគឺ 00205094 លោកបាននិយាយដូចតទៅនេះ៖ “ខ្ញុំបានឃើញ នួន ជា នៅចុងឆ្នាំ ១៩៧៦ នៅពេលដែលខ្ញុំទៅមើលខ្សែភាពយន្ត ហើយនិងការសម្ដែងសៀកនៅខេត្តតាកែវ ដែលពេលនោះ នួន ជា បានធ្វើសុន្ទរកថាបើករយៈពេលប្រហែលជា១០នាទី។ អ្នកសម្ដែងសៀកសុទ្ធតែជាជនជាតិចិន ហើយនិយាយជាភាសាចិន។ សុន្ទរកថារបស់លោក នួន ជា ដូចតទៅនេះ យើងជាកសិករ យើងនឹងកែប្រែប្រទេសយើងទៅជាប្រទេសកសិឧស្សាហកម្ម”។ អ៊ីចឹង ខ្ញុំសួរថាតើនេះគឺជាការចងចាំរបស់លោកទេ អ្វីដែលលោកបាននិយាយនេះ ឬក៏លោកមិនច្បាស់ពីកាលបរិច្ឆេទទេ?

**ផ៖** កាលបរិច្ឆេទក្នុងពេលដែលខ្ញុំនិយាយពេលគេទៅសាកសួរនៅឯគេហដ្ឋានរបស់ខ្ញុំថ្មីនេះ គឺពេលនោះមកដល់ឥឡូវនេះ ក៏ជាពេលយូរដែរហើយ ខ្ញុំចាស់ហើយ ខ្ញុំភ្លេចភ្លាំងដែរ ប៉ុន្តែពេលនោះដែលខ្ញុំនៅចងចាំ គឺខ្ញុំប្រាប់គេ។ ឥឡូវខ្ញុំភ្លេច។

**ស៖** តើលោកដឹងថា ដែលសៀកហ្នឹងមក គេមកសម្ដែងសៀកនៅតាកែវហ្នឹង ច្រើនដងដែរឬទេ?

[០៩:២៥:៤៨]

**ផ៖** ពេលដែលគេឲ្យពួកខ្ញុំចូលទៅហ្នឹង គេរេករែកធ្ងន់ធ្ងរណាស់។ ហើយខ្ញុំបានដឹងតែម្ដងហ្នឹងទេ ដងដទៃទៀត ត្រង់គេសម្ដែងនៅពេលណា ក៏ខ្ញុំអត់ដែលបានដឹងដែរ ខ្ញុំវិលទៅកសិដ្ឋានវិញ ទៅធ្វើការងារស្រែចម្ការវិញ។

**ស៖** បាទ ដូច្នេះសូមកត់ជាប្រតិចារឹក មាននៅក្នុងសំណុំរឿង ឯកសារ D366/7.1.305 គឺជាទស្សនាវដ្ដីកម្ពុជាប្រជាធិបតេយ្យ ដំណឹងពីប្រទេសកម្ពុជា ERN គឺជាភាសាបារាំងគឺ S00012468 គឺមាននិយាយអំពីក្រុមសៀករបស់ប្រទេសចិន នៅក្នុងតំបន់នៃកម្ពុជាប្រជាធិបតេយ្យជាច្រើន ហើយមាន

ការនិយាយអំពីការទស្សនកិច្ចក្នុងតំបន់ផ្សេងៗ ឧទាហរណ៍ដូចជាការទស្សនកិច្ចនៅលាយបូរ នៅថ្ងៃទី ២៥ វិច្ឆិកា ឆ្នាំ១៩៧៨ ជាដើម។ លោក កែវ ច័ន្ទតារ៉ា តើលោកបានជួបមេដឹកនាំរបស់កម្ពុជាប្រជាធិប-តេយ្យផ្សេងទៀតទេ ទោះជាមុន ឬក៏ក្រោយថ្ងៃរំដោះក៏ដោយ?

[០៩:២៧:៤៧]

**ឆ៖** នៅក្នុងឃុំបារាយណ៍ដែលខ្ញុំចេញពីផ្ទះកំណើតរបស់ខ្ញុំទៅ មេដឹកនាំសហគមន៍មានតែតាម៉ុក មួយទេ ដែលគាត់ចុះទៅការដ្ឋាន គឺទៅត្រួតពិនិត្យកន្លែងបូមទឹក កន្លែងជីកប្រឡាយ ហ្នឹងខ្ញុំបានជួប។

**ស៖** តើលោកមានចាំថា បានឆ្លើយទៅអ្នកស៊ើបអង្កេត ឬក៏សហចៅក្រមស៊ើបអង្កេតថា លោកបានជួបលោក អៀង សារី ដែរឬទេ?

**ឆ៖** ខ្ញុំអត់ស្គាល់គាត់ អត់ដែលបានជួប។

**ស៖** ឥឡូវខ្ញុំសូមកត់សម្គាល់មួយ គឺថានៅក្នុងឯកសារដែលខ្ញុំបានបង្ហាញអម្បាញ់មិញនោះ គឺឯកសារ E3/5153 ដែលលោកបាននិយាយនៅទំព័រដដែល លេខយោងដដែល។ លោកនិយាយថា៖ "ខ្ញុំមិនដែលបានជួបអ្នកផ្សេងទៀត ក្រៅពីតាម៉ុក ទេ ក៏ប៉ុន្តែខ្ញុំបានជួបលោក អៀង សារី ចន្លោះឆ្នាំ១៩៦៦-៦៧ កាលណោះ គាត់ជាគ្រូនៅសាលាចម្រើនវិជ្ជា។ ខ្ញុំកាលណោះ ខ្ញុំមិនមែនជាសិស្សរបស់គាត់ទេ"។ តើខ្ញុំរំឭកនេះ លោកធ្វើឲ្យលោកចាំឡើងវិញទេ?

[០៩:២៩:៤៧]

**ឆ៖** សាលាវិទ្យាល័យចម្រើនវិជ្ជា ខ្ញុំដែលមករៀនបំពេញ គឺជាសាលាព្រឹវ៉េ ហើយខ្ញុំមិនដែលបានស្គាល់គាត់ទេ។ បើៗស្គាល់ក្នុងពេលនោះ មកដល់ឥឡូវក៏ភ្លេចហើយទាន ព្រោះខ្ញុំក្នុងវ័យ*(ឮមិនច្បាស់)*។ ពេលនោះ មុនខ្ញុំរៀន*ហ្វាក់មេដេស៊ីន*ទៅទៀត ប្រហែលជាឆ្នាំ១៩៥០ប្លាយអីណោះ ខ្ញុំចាំមិនបានទេចំពោះមនុស្សដែលជួបតែមួយពេលមួយគ្រា។ សូម្បីគ្រូខ្ញុំសិក្សារាល់ថ្ងៃខ្ញុំមិនភ្លេច -- ខ្ញុំភ្លេចគាត់ទៅហើយដែរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំសូមបញ្ជាក់ថាចម្លើយដែលខ្ញុំបង្ហាញនេះ បានធ្វើឡើងនៅថ្ងៃទី១២ ខែ៣ ឆ្នាំ២០០៨ គឺថាវាយូរកន្លងមកហើយដែរ។ លោកសាក្សីខ្ញុំអស់សំណួរហើយៗ ឥឡូវយើងអាចផ្តល់វេទិកាទៅដល់ខាងមេធាវីការពារក្តីបាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បានជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ហើយជាដំបូងនេះអាចប្រគល់ទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាស បើមានបំណងសួរសំណួរទៅដើម -- ទៅសាក្សីរូបនេះពាក់ព័ន្ធនឹងសំណួរចុងក្រោយដែលសួរឡើងដោយលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ អម្បាញ់មិញនេះ។

[០៩:៣១:៣៦]

**លោក វិ៉ចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរអស់លោក លោកស្រីចៅក្រម ខ្ញុំមានភាពស្ទាក់ស្ទើរនៅឡើយសម្រាប់ពេលនេះ យោងតាមចម្លើយដែលបានឆ្លើយមកនឹងការតាំងសំណួររបស់ខ្ញុំ ខ្ញុំយល់ឃើញថាគាត់មិនបានឃើញ នួន ជា ពិតប្រាកដនៅទីនោះទេ។ ខ្ញុំថាប្រសិនណានេះ អាចនឹងបង្ហាញជារូបភាពតែម្តងដើម្បីសួរទៅសាក្សីរូបនេះ។ បើមិនដូច្នេះទេយើងចប់តែម្តង ចូលជាមួយនឹងសាក្សីថ្មីតែម្តង។ ដូច្នេះលោកប្រធាន ខ្ញុំសូមការអនុញ្ញាតដើម្បីបង្ហាញនូវរូបថតមួយចំនួន រូបថតស្តីអំពី កម្មាភិបាលខ្មែរក្រហម ដើម្បីអនុញ្ញាតឲ្យខ្ញុំសួរទៅសាក្សីរូបនេះ ថាតើគាត់ស្គាល់អ្នកណាម្នាក់ នៅក្នុងរូបថតទាំងនេះដែរឬក៏អត់។ បាទ សូមការអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ លោកប្រធាន។ ដើម្បីឲ្យយល់ពីនីតិវិធីឲ្យបានច្បាស់ គឺខ្ញុំ -- អំមិញនេះខ្ញុំដូចជាមានចំណាប់អារម្មណ៍ថា ក្រុមការពារក្តីលោក នួន ជា នោះគាត់បានសួរសំណួរចប់ហើយ។ អ៊ីចឹង វាដល់ពេលក្រុម ខៀវ សំផន សួរសំណួរហើយ។ ខ្ញុំចង់សួរលោកប្រធានថា តើលោកប្រធានផ្តល់វេទិកាទៅខាងមេធាវីការពារក្តីឡើងវិញ ដោយសារលោកចៅក្រមបានសួរសំណួរអម្បាញ់មិញ ឬក៏ក្នុងករណីហ្នឹងគឺថាត្រូវឲ្យភាគីទាំងអស់មានសិទ្ធិសួរដែរលោកប្រធាន? ព្រោះថានេះជារឿងមើលទៅដូចជាធម្មតា ឬក៏លោក លោកស្រីចៅក្រមគិតឃើញថា ផ្តល់វេទិកាទៅតែខាងការពារក្តីទេ ពីព្រោះថានីតិវិធីដែលយើងត្រូវគោរពនៅទីនេះ ខ្ញុំមើលឃើញទៅហាក់ដូចជាធ្វើប្លែក ហើយខ្ញុំមិនយល់ពីលំដាប់លំដោយវេទិកា គឺថាការឡើងនិយាយសម្តី ព្រោះថាអង្គជំនុំជម្រះបានសួរហើយទៅ ស្រាប់តែមានផលប៉ះពាល់

អ៊ីចឹងគឺត្រូវការបែងចែកពេលវេលាឡើងសួរមួយសាទៀត។ អ៊ីចឹង សូមឲ្យអស់លោក លោកស្រីចៅក្រមកំណត់ឲ្យច្បាស់ ចង់និយាយថាតើនៅពេលដែលចៅក្រមចោទសំណួរ តើមានផលប៉ះពាល់យ៉ាងណា ហើយបែងចែកពេលវេលាសួរបន្តទៀតយ៉ាងម៉េចដែរលោកប្រធាន? ចង់សូមជួយបញ្ជាក់។

[០៩:៣៤:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថានេះជាករណីពិសេសហើយដែលចៅក្រមសួរក្នុងពេលដែលចៅក្រមនោះគាត់សួរ ហើយពេលនោះជាពេលរបស់ខាងការពារក្តីទេ។ ក៏ប៉ុន្តែក្នុងករណីយើងនេះ យើងផ្តល់វេទិកានេះទៅក្រុម នួន ជា ឡើងវិញនេះ ដើម្បីឲ្យគាត់អាចមានលទ្ធភាពសួរសំណួរទៅ សំណួរ ពាក់ព័ន្ធនឹងសំណួរដែលខ្ញុំបានចោទអម្បាញ់មិញនេះ។ ជាពិសេសហ្នឹង គឺទាក់ទងទៅនឹងការធ្វើទស្សនកិច្ច ឬក៏ការជួបគ្នារវាងសាក្សី និង នួន ជា។ ដោយសារមូលហេតុនេះហើយ បានយើងបានផ្តល់វេទិកាទៅក្រុមការពាររបស់លោក នួន ជា វិញនោះ ហើយយើងមិនគិតថាយើងៗមិនផ្តល់វេទិកាទៅភាគីផ្សេងទៀតទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វេនស៍!

[០៩:៣៥:២៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមានសំណួរមួយទៅកាន់មេធាវីការពារក្តីលោក នួន ជា។ ខ្ញុំកត់សម្គាល់ឃើញថាយើង ខ្ញុំកំពុងគិតនៅពេលដែលលោកនិយាយ ដូច្នេះដើម្បីបញ្ជាក់ថាតើ ដែលថាសំណួរទាំងឡាយគួរតែរឹតត្បិតទាក់ទងទៅនឹងបន្ទាប់ពីការសួររបស់លោកចៅក្រម ឡាវ៉ែន៍។ ដូច្នេះលោកមេធាវី ថាតើការស្នើសុំបង្ហាញរូបថតហ្នឹង គឺឯកសារមួយនេះ តើគោលបំណងពិតប្រាកដសួរដើម្បីពាក់ព័ន្ធទៅអង្គហេតុអ្វី?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកស្រីចៅក្រម ហ្វេនស៍ ខ្ញុំព្យាយាមបង្ហាញនូវឯកសារដែលមាននៅក្នុងសំណុំរឿងរួចទៅហើយ ដើម្បីស្វែងរកថាតើសាក្សីរូបនេះអាចស្គាល់នូវស្គាល់កម្មាភិបាលណាម្នាក់ក្នុងឱកាសណាមួយនៅក្នុងរូបថតនេះដែរឬក៏អត់? ហើយអ្វីដែលខ្ញុំព្យាយាមចង់បង្ហាញឲ្យឃើញនោះគឺ ខ្ញុំសូមឲ្យមានគោល

ការណ៍ណែនាំពិតប្រាកដក្នុងការសួរតទល់គ្នា ជាពិសេសការសួរតទល់ពាក់ព័ន្ធទៅនឹងរូបថតនេះតែម្តង។ រឿងក្តីរបស់ ដាឱច នៅអាយ.ស៊ី.ធី.វ៉ាយ ដូចដែលខ្ញុំបានផ្ញើទៅអ៊ីម៉ែល គឺថាហេតុផលដោយសារថា ជំហររបស់ខ្ញុំទាក់ទងទៅនឹងសាក្សីនេះ គឺយើងចង់ដឹងបែបនេះឯង។ បើសិនណាមានការអនុញ្ញាតខ្ញុំចង់ចាប់ផ្តើមសួរតែម្តង។

ដូច្នេះសំណើរបស់យើងខ្ញុំ គឺចង់បង្ហាញឯកសារនេះ។ ពាក់ព័ន្ធទៅនឹងរូបថតមួយចំនួនទៅសាក្សីរូបនេះ ដើម្បីសួរទៅគាត់ ថាតើគាត់អាចនៅចាំអ្នកណាម្នាក់ ឬក៏នៅចាំ នួន ជា នៅក្នុងបណ្តារូបថតទាំងនេះដែរឬក៏អត់?

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ខ្ញុំក៏សួរទៅសាក្សីផងដែរ លោកស្រីសូមជួយ -- សូមលោកសាក្សីជួយរំឭកប្រាប់អំពីអាយុលោកម្តងទៀតមើល៍?

[០៩:៣៧:៥២]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បច្ចុប្បន្ននេះខ្ញុំអាយុ៨០ឆ្នាំគត់។

**ស៖** ខ្ញុំចង់ដឹងថាតើលោកធ្លាប់មានបទពិសោធន៍ ឬក៏លោកជួបប្រទះបញ្ហានៃការចងចាំ មានន័យថា ការបាត់បង់ការចងចាំណាមួយដែរទេក្នុងរយៈពេលថ្មីៗនេះ?

**ឆ៖** ខ្ញុំចូលមកក្នុងវ័យ៧៥មក៨០នេះ ខ្ញុំបាត់បង់ការចងចាំច្រើនណាស់លោកស្រី សូមទោស។

**ស៖** តើការបាត់បង់ការចងចាំនេះ បាត់បង់ការចងចាំដែលមានតាំងពីមុនយូរលង់ណាស់មកហើយ ឬក៏បាត់បង់ការចងចាំរឿងថ្មីៗនេះ? ដូចជាថាបាត់បង់ការចងចាំរឿងដែលជួបក្នុងអតីតកាល ឬក៏បាត់បង់នូវការចងចាំនូវរឿងដែលលោកទើបជួបប្រទះនាពេលថ្មីៗ?

**ឆ៖** ពីមុនក៏រឹតតែបាត់បង់ការចងចាំហើយ បច្ចុប្បន្ននេះកូនខ្ញុំហ្នឹងពីរបីនាក់ ជួនកាលឃើញមុខវាក៏មិនដឹងថាវាឈ្មោះអីផងទៀត។ បាត់បង់អ៊ីចឹងលោកស្រី សូមទោស។

**ស៖** សូមសួរបញ្ជាក់តែម្តង ថាតើក្នុងរយៈពេល៦ឆ្នាំចុងក្រោយនេះ គឺគិតបើលោកថា៦ឆ្នាំ គឺ២០០៨រហូតមក២០០៨ គឺជារយៈពេលដែលលោកផ្តល់កិច្ចសម្ភាសន៍ចុងក្រោយ រហូតមកទល់នឹងឆ្នាំ២០១៤។ ៦ឆ្នាំ។

**ឆ៖** ខ្ញុំបាទស្តាប់សំណួររបស់លោកអត់ទាន់បានច្បាស់លាស់ទាន។

[០៩:៤០:០៨]

**ស៖** ខ្ញុំសូមបញ្ជាក់ថា អ៊ីចេះលោកបានជម្រាបជូនអង្គជំនុំជម្រះថា នៅអាយុ៧៥ លោកចាប់ផ្ដើមបាត់បង់ការចងចាំ គឺនៅអាយុចាប់ពី៧៥ គឺរយៈពេលប្រហែលជា៥ឆ្នាំកន្លងទៅនេះ។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ មិនមែនបាត់ឈឹងក្នុងពេល៧៥មក៨០នេះទេ វាបាត់បន្តិចម្ដងៗតាំងពីវ័យចូលមក ៦០ មក៧០អ៊ីចឹងមកណ៎ាទាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកប្រធាន។ យើងមិនជំទាស់ទៅនឹងការស្នើសុំបង្ហាញរូបថតនេះទេ បើសិនអង្គជំនុំជម្រះគិតថា មានសារប្រយោជន៍។ ប៉ុន្តែយើងខ្ញុំមានការផ្ដល់មតិមួយចំនួនពាក់ព័ន្ធទៅនឹងតម្លៃនៃភស្តុតាង។ ទី១ ថាតើរូបថតទាំងនេះវាមកពីវីដេអូដែរ ឬក៏យ៉ាងណា ហើយវាមានគុណភាពៗវាយ៉ាងម៉េចដែរ។ ដូច្នេះ សំណើរបស់ខ្ញុំគឺចង់ឲ្យមានតម្លៃភវនីយហេតុទាក់ទងទៅនឹងភស្តុតាងក្នុងការបង្ហាញឯកសារនេះ។ រូបថតមួយចំនួនឃើញថាមិនមានគុណភាពល្អទេ។ នេះក៏ពាក់ព័ន្ធទៅនឹងតម្លៃភវនីយហេតុនៃភស្តុតាងនោះដែរ។ ដូច្នេះសំណើសុំរបស់យើងខ្ញុំ គឺថា មិនដឹងថារូបថតហ្នឹងវាពាក់ព័ន្ធទៅនឹងអ្វីដែលគាត់និយាយ ឬយ៉ាងណា ហើយថាតើរូបថតនេះ រូបថតពាក់ព័ន្ធទៅនឹងការដែលគាត់បញ្ជាក់ថាគាត់បានឃើញដែរ ឬក៏អត់នោះទេ?

[០៩:៤២:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបទៅវិញយ៉ាងខ្លីលោកប្រធាន។ ដូចដែលលោក លោកស្រីចៅក្រម បានដឹងហើយ យើងមានគោលការណ៍ណែនាំតឹងរ៉ឹងក្នុងការយករូបថតមកសួរតតាំងជាមួយនឹងសាក្សី។ បើសិនណាយើងបង្ហាញជាខ្សែវីដេអូកាន់តែ បញ្ហាកាន់តែធ្ងន់ធ្ងរទៅទៀតហើយ ដោយសារថា ដូចលោកនិយាយអ៊ីចឹង គុណភាពវាមិនច្បាស់លាស់។ យើងឃើញមានប្រពន្ធមួយ អ៎! សូមទោស មានរូបថតមួយចំនួន

គឺថាយើងឃើញអ្នកដើរហ្នឹង ដើរតាមលំដាប់លំដោយ គេថតយ៉ាងដូច្នេះឯង។ ដូច្នេះវាអាចនាំឲ្យសាក្សីអាចធ្វើសេចក្ដីសន្និដ្ឋានទៅតាមមនុស្សដែលជាជួរៗហ្នឹង ថាតើអ្នកនោះជាអ្នកណា ក្រែងគាត់អាចចងចាំបាន។ ហើយក្នុងចំណោមរូបថតទាំងអស់នេះ ក៏មានមនុស្សមួយចំនួនដែលយើងមិនព្យាយាមសូមឲ្យសាក្សីបញ្ជាក់នោះដែរ។ បទពិសោធន៍របស់ខ្ញុំនោះគឺថា ភាគីច្រើនការអនុវត្តនៅតុលាការក្នុងស្រុករបស់ខ្ញុំ គឺយើងត្រូវធ្វើឲ្យបានហ្មត់ចត់គោលការណែនាំទៅនឹងរបាយការណ៍របស់ប៉ូលិស ដែលគេហៅថា "អូស្ដ្រហ្គាយឡាញ" គោលការណ៍ណែនាំទីក្រុងអូស្លូ។

[០៩:៤៣:៤២]

បើសិនណាជាយកខ្សែវីដេអូយកមកបង្ហាញនោះ វាកាន់តែមិនមានតម្លៃភវនីយហេតុទៅទៀតហើយ។ ដូច្នេះខ្ញុំៗអាចនឹងអង្គុយចុះ ហើយឲ្យខាងតំណាងសហព្រះរាជអាជ្ញាបង្ហាញនូវទិដ្ឋភាពណាមួយដែលយល់ឃើញថាវាល្អ លើកឡើងមកបង្ហាញជូនអង្គជំនុំជម្រះ។ ប៉ុន្តែយើងមានតែរូបថតដូចនេះតែដូច្នេះ យើងខ្ញុំស្នើសុំធ្វើការតាំងសំណួរតែម្ដង។ យើងយករូបថតណាដែលយល់ឃើញថា មានគុណភាពល្អៗ ដើម្បីយកមកសួរដល់សាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាត ហើយក្រឡាបញ្ជីសវនាការយក -- មន្ត្រីរដ្ឋបាលតុលាការទទួល -- យកឯកសាររូបថត យកទៅជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

ឲ្យមើលខាងណេះមុន អក្សរ អត់មានឈ្មោះ!

សាក្សីពិនិត្យមើលសិនទៅ ឲ្យបានហ្មត់ចត់ទៅ ហើយរង់ចាំការស្ដាប់តាំងសំណួរពីសំណាក់មេធាវីការពារក្ដីបន្តិចទៀតនេះ។

អញ្ជើញលោកមេធាវី!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី ខ្ញុំសូមលោកពិនិត្យមើលឲ្យបានល្អិតល្អន់ទៅ

លើរូបថតទាំង១០ ដែលលោកបានឃើញនៅចំពោះមុខលោកនេះ។ សំណួររបស់ខ្ញុំថាតើលោកអាចកំណត់អត្តសញ្ញាណបុគ្គលណាម្នាក់នៅក្នុងរូបថតនេះ ហើយបុគ្គលដែលជាពិសេស លោកយល់ថាជា នួន ជា ដើម្បីបង្ហាញជូនអង្គជំនុំជម្រះបានទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** សុំទោសលោក ខ្ញុំមើលរូបថតទាំង១០នាក់នេះ អត់ស្គាល់នរណាម្នាក់ទេព្រោះមើលមិនច្បាស់ផងដោយភ្នែកខ្ញុំក៏ស្រវាំងហើយឥឡូវហ្នឹង។ ហើយអត់ចងចាំបានទេឥឡូវ មិនដឹងជាអ្នកណាៗទេ រូបថតទាំងអស់នេះអត់ស្គាល់ទេ។ សុំទោស។

**សៈ** លោកសាក្សីលោកប្រើវ៉ែនតាដែរទេ? ហើយឥឡូវនេះលោកមានវ៉ែនតាជាប់មកជាមួយខ្លួនទេ?

**ឆ៖** វ៉ែនតាខ្ញុំជាប់មក ប៉ុន្តែពាក់ទៅមើលមិនច្បាស់ដែរទាន អត់សូវច្បាស់ទេ។ ហើយម៉្យាងទៀត ខ្ញុំនឹកថារូបថតនេះមើលមិនស្គាល់ថាអ្នកណាម្នាក់ប្រហែលអ្នកណាម្នាក់ក៏អត់ដែរទានបាទ។

[០៩:៤៧:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ទៅមុខទៀត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសាររូបថតហ្នឹងយកមកជូនមេធាវីវិញបាទ។

ជាបន្តទៅនេះ ប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក វ៉ិចទ័រ កូប៉េ៖**

សំណួរចុងក្រោយលោកប្រធាន ខ្ញុំអាចយកជារូបថតហ្វូតូកូពីនេះអាចមានគុណភាពល្អជាងរូបថតអម្បាញ់មិញលោកប្រធាន។ ដូច្នេះ សូមការអនុញ្ញាតបង្ហាញរូបថតដើម យើងចម្លងដែរក៏ប៉ុន្តែថតចម្លងដើម គឺថាលើកដំបូង លើកទី១ ប្រហែលជាមានគុណភាពល្អ។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បានបញ្ចប់នីតិវិធីបង្ហាញចប់អស់ហើយរូបថតនេះត្រឹមនេះចុះ។ សូមប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន សូមគោរពអង្គសវនាការ សូមជម្រាបសួរលោកសាក្សី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** កាលពីថ្ងៃចន្ទ យើងបានបញ្ចប់នៅត្រង់ចំណុចទាក់ទងទៅនឹងវត្តមាននៃការឃុំខ្លួនរបស់លោកនៅក្រាំងតាចាន់។ ហើយនៅពេលនោះ យើងមានចំណុចដែលត្រូវបកស្រាយទាក់ទងថា លោកបានត្រូវជាប់ឃុំរយៈពេល២៩ថ្ងៃ ក៏ប៉ុន្តែមានចំណុចខ្វែងគ្នាត្រង់ថា តើចាប់ពីពេលណាដល់ពេលណាបាទ។ ហើយជាចម្លើយចុងក្រោយរបស់លោក លោកបានឆ្លើយថាលោកមិនបានចាំច្បាស់ពីពេលវេលានោះទេ ហើយលោកបានពិភាក្សាជាមួយនឹងគ្រួសាររបស់លោកនិងកូនរបស់លោកផង ដើម្បីកំណត់ថាតើពេលណាដែលជាពេលវេលាលោកជាប់ឃុំនៅក្រាំងតាចាន់នោះ។ តើលោកចាំចំណុចនេះបានទេ?

[០៩:៤៩:៣៩]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** តាមការត្រលប់មកពីក្រាំងតាចាន់វិញ ក្រុមគ្រួសារខ្ញុំបានកត់ត្រាថាចំនួន២៩ថ្ងៃ។ ហើយខ្ញុំគិតទៅថា២៩ថ្ងៃនេះ ខ្ញុំទៅជាប់នៅក្របីព្រៃពាក់កណ្ដាលផ្លូវនោះ មន្ទីរមួយសាកសួរផងដែរ ៥ថ្ងៃ ហ្នឹងខ្ញុំចាំ។ តែ២៩ថ្ងៃ វានៅសល់២៤ថ្ងៃទេក្នុងក្រាំងតាចាន់។ ហើយកូនប្រុសខ្ញុំច្បង វាគិតថា ប៉ាឯងប្រហែលជាជាប់ហ្នឹងពីក្នុងឆ្នាំ១៩៧៥ដែរ ប៉ុន្តែក្នុងខែមីនា ចុងខែមីនាហើយ។ ដល់ខែមេសាបែកទូទាំងប្រទេសបានប្រហែលជាជាង១០ថ្ងៃ ប៉ាឯងត្រឡប់មកវិញ មកផ្ទះវិញ។ សូមជ្រាបទាន។

**ស៖** បាទ ដូច្នេះ ការចងចាំនេះមិនមែនៗជាការចងចាំរបស់លោកទេ គឺជាការចងចាំរបស់កូនរបស់លោក។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយបាទ!

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ពិតប្រាកដដូចលោកមានប្រសាសន៍ហើយ ព្រោះថាខ្ញុំមានអីកត់ត្រានិងការចងចាំទៅបានទាន នៅក្នុងមន្ទីរឃុំឃាំងហ្នឹងគ្មានទាំងខ្មៅដៃ គ្មានអីផង សម័យនោះអត់ប៊ិកសរសេរទេ។ សូមទោសទាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោករៀបអាពាហ៍ពិពាហ៍ពេលណាដែរ លោកអាចជម្រាបបានទេ?

**ឆ៖** ខ្ញុំមានពេលវេលាមួយដែលខ្ញុំចាំបានទានណ៎ា ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ខ្ញុំមកធ្វើបុណ្យ នាំភរិយាខ្ញុំមកធ្វើបុណ្យពាក់កណ្តាលសាសនា ដែលសម្តេច នរោត្តម សីហនុ លោកចាប់ផ្តើមធ្វើ ហើយនិងសម្តេច ជួន ណាត លោកនេះ ខ្ញុំក៏ទៅថ្វាយបង្គំគ្រូ សម្តេច ជួន ណាត ហ្នឹង។ ហ្នឹងខ្ញុំចាំតែប៉ុណ្ណឹងទេទាន លោកស្រាវជ្រាវតាមហ្នឹងចុះ។ បាទបុណ្យពាក់កណ្តាលសាសនាគេធ្វើពីអង្កាល់ ៧ថ្ងៃ ៧យប់នោះបាទ។ សូមជ្រាបបាទ។

**ស៖** បាទ សូមអរគុណ។

**ឆ៖** បាទ។

[០៩:៥១:៥៥]

**ស៖** បាទ ឥឡូវខ្ញុំសូមពិភាក្សាពីរឿងក្រាំងតាចាន់ទៀត ដោយសារលោកធ្លាប់បាននៅមន្ទីរក្រាំងតាចាន់។ ហើយតាមសម្តីចុងក្រោយអម្បាញ់មិញនេះ លោកថា លោកអាចស្នាក់នៅ ឬក៏ជាប់ឃុំនៅមន្ទីរក្រាំងតាចាន់ហ្នឹងរយៈពេល២៤ថ្ងៃ។ ខ្ញុំចង់ដឹងថា តើមន្ទីរក្រាំងតាចាន់នោះមានអគារចំនួនប៉ុន្មានដែរ អគារសម្រាប់ដាក់អ្នកទោស? លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ អគារដែលអ្នកទោសជាប់គុក ជាប់ខ្នោះរាល់យប់រាល់ថ្ងៃតែម្តង យកមកនៅក្នុងមន្ទីរហ្នឹងគឺតែមួយទេទាន ដែលដាក់គុកនោះ។

**ស៖** បាទ លោកបញ្ជាក់អគារមានតែមួយទេ។ ខ្ញុំឃើញមានភាពមិនច្បាស់លាស់មួយទាក់ទងទៅនឹងទំហំអគារ ពីព្រោះនៅក្នុងឯកសារដែលលោកបានឆ្លើយមុនថា អគារនោះមានទំហំ៦ម៉ែត្រគុណនឹង២០។ ហើយមានពេលខ្លះ កាលពីពេលសាកសួរនៅក្នុងអង្គជំនុំជម្រះនេះ លោកឆ្លើយថាប្រហែលជា៣ម៉ែត្រគុណនឹង២០។ ដូច្នេះ លោកអាចបញ្ជាក់ថា ទំហំពិតប្រាកដជាទំហំមួយណា?

**ឆ៖** បាទ សូមទោស ការស្មានដោយយើងឃើញអ៊ីចឹង មិនស្មានបានត្រឹមត្រូវទេ។ ពាក្យថាស្មានគឺខុសខ្លះ ត្រូវខ្លះហើយ។ ខ្ញុំប៉ាន់ទៅប្រហែលជា ៣ម៉ែត្រទេនិង២០ម៉ែត្រ ថាអ៊ីចឹងចុះ ក្រោម២០បាទទាន។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីសណ្ឋាននៃទីតាំងអគារដែលលោកថា មានទំហំ៣ម៉ែត្រគុណនឹង២០ហ្នឹងទេ? វាសង់យ៉ាងម៉េច បណ្តោយថ្ងៃ ទទឹងថ្ងៃ ឬក៏មានស្ថានភាពបែបម៉េចលោកអាចរៀបរាប់លម្អិតបន្តិចបានទេ?

[០៩:៥៤:០៥]

**ឆ៖** បាទ អគារនោះជញ្ជាំងស្លឹកដូង សង់ផ្ទាល់ដី ហើយប្រក់ស្លឹក ខាងក្នុងជញ្ជាំងដែលមានស្លឹកដូងហ្នឹង គេប្រទាក់ល្ងួសបន្ទាហ្នឹងបីជាន់ ខាងលើក៏ប្រទាក់បីជាន់ដែរ កម្ពស់មួយក្បាលយើងទើសតែម្តង។ ហើយខាងក្រោមយើងអង្គុយហ្នឹងក៏វាមានល្ងួសបន្ទាដែរ មិនដឹងប៉ុន្មានជាន់ទេអាហ្នឹង។ ខ្ញុំមើលខាងលើហ្នឹងឃើញថាគេប្រទាក់បីជាន់ ក្រឡាហ្នឹងស្ទើរតែញឹកណាស់។ ហើយជម្រាបលោកផងដែរ ដើម្បីចូលរួមវេទនាក្នុងពេលនោះ ខាងក្រោយដែលយើងដេកទៅហ្នឹង កូនត្បែងដែលមានក្រមរខ្លាំងណាស់មិនមែនក្តារទេ យកមកដាក់ឲ្យយើងដេក ប្រហែលជាបួនប្រាំដើមទេ។ សម័យហ្នឹងសង្កើចនៅពេញក្រមរត្បែងហ្នឹង ខាងនោះក៏អ៊ីចឹងដែរ។ ហើយកណ្តាលយើងមានក្តារពីរបន្ទះហ្នឹង សម្រាប់គេដើរចែកបាយហ្នឹង គេដាក់ខ្នោះជើងយើងជាប់ហើយ។ ហូបបាយក៏ជាប់ខ្នោះ ជុះអាចម៍ក៏ជាប់ខ្នោះ ជុះនោមក៏ជាប់ខ្នោះដែរ។ សូមជ្រាបទាន សូមអរគុណ។

**ស៖** បាទសូមអរគុណ។ អំមិញលោកបញ្ជាក់ថាដំបូលស្លឹក លោកអាចបញ្ជាក់បានទេថាជាស្លឹកអ្វីដែរ?

**ឆ៖** បាទ ដំបូលស្លឹកត្នោតទាន មើលទៅយើងមើលពីក្រោមទៅឃើញស្លឹកត្នោត គេដេរជាកណ្តុបៗហ្នឹងប្រក់ហ្នឹង។

**ស៖** បាទៗ អរគុណ។ បាទ អគារនោះសង់ជាលក្ខណៈបណ្តោយថ្ងៃ ឬក៏ទទឹងថ្ងៃ?

[០៩:៥៥:៥៧]

**ឆ៖** បាទ អគារហ្នឹងបណ្តោយថ្ងៃទាន។ ខាងកើតនេះមានដើមស្លួលមួយនៅសព្វថ្ងៃទេ ហើយខាងលិចហ្នឹងគឺដើមស្វាយមួយ និងគុម្ពឫស្សីស្រុក។

**ស៖** បាទ សូមអរគុណ។ ខ្ញុំបានស្តាប់លោកឆ្លើយជាមួយនឹងលោកចៅក្រមឡាវ៉ែន៍ អម្បាញ់មិញទាក់ទងទៅនឹងចំនួនបុគ្គលដែលធ្វើការនៅក្នុងមន្ទីរក្រាំងតាចាន់ ថាលោកអត់បានចាំចំនួនទេ។ តើលោកអាចចាំថាអ្នកណាជាមេដឹកនាំ ជាប្រធានមន្ទីរក្រាំងតាចាន់នៅពេលដែលលោកជាប់ឃុំនៅទីនោះដែរទេ?

**ឆ៖** នេះដោយការសន្និដ្ឋានដែរ មិនដឹងជាមេធំគេទៅបង្កប់ខ្លួននៅឯណាក៏មិនដឹងដែរ ប៉ុន្តែអ្នកសាកសួរចម្លើយហ្នឹងគឺអាចារ្យ ឆេន, ឈ្មោះ ឆេន – អាចារ្យឆេន។

**ស៖** បាទ លោកចង់មានប្រសាសន៍ថាអាចារ្យឆេន ម្នាក់ដែលបានសួរចម្លើយលោកនៅក្របីព្រៃនោះមែនទេ?

**ឆ៖** បាទ ហ្នឹងហើយទាន។ គេមកសួរនៅក្របីព្រៃ ដល់ខ្ញុំទៅដល់ក្រាំងតាចាន់ គឺឃើញគេនៅ

ហ្នឹងទៀត បាទ។ អ៊ីចឹងគេវត្តមានជានិច្ចកាលប្រហែលជានៅក្រាំងតាចាន់ហ្នឹងហើយ បាទ ព្រោះគេនៅហ្នឹងជាប់។

**ស៖** បាទ សូមអរគុណ។ លោកអាចចាំឈ្មោះអ្នកណាទៀតដែលលោកបានដឹងថាជាមេធំម្នាក់នៅក្នុងមន្ទីរក្រាំងតាចាន់ហ្នឹងដែរទេ?

**ឆ៖** បាទ ឈ្មោះ តាដាំ ហ្នឹងជាអ្នកវាយប្រហារហើយទាន។ អ្នកណាក៏ខ្លាច តាដាំ ហ្នឹងដែរ។

**ស៖** បាទ ប៉ុន្តែលោកអត់អាចបញ្ជាក់ថា ឈ្មោះ ដាំ នេះជាមេធំនៅក្រាំងតាចាន់ទេ? តើលោកអាចបញ្ជាក់ទេ ឬមួយក៏យ៉ាងណា? លោកអាចពន្យល់បន្ថែមបន្តិចមក។

**ឆ៖** បាទតាដាំ ខ្ញុំមិនអាចបញ្ជាក់ថាគាត់ជាមេបានទេទាន ពីព្រោះថាបែក ១៧មេសាទៅ តាដាំហ្នឹងគាត់គេឲ្យទៅជាអ្នកទោសវិញដែរ គេឲ្យទៅកាប់ដីដំបូក រែកអ៊ីចឹងដែរបាទ។

[០៩:៥៨:៣៥]

**ស៖** បាទ សូមអរគុណ។ ទាក់ទងនឹងចំនួនអ្នកទោសនៅក្នុងអគារ លោកបានរៀបរាប់ថាមានចំនួនប្រហែលជា ៤០ ទៅ ៤៥នាក់។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមថា តើក្នុងរយៈពេល២៤ថ្ងៃដែលលោកនៅមន្ទីរក្រាំងតាចាន់នោះ មានការផ្លាស់ប្តូរ បានន័យថាចំនួនចេញនិងចំនួនចូលដូចម្តេចដែរ? លោកអាចចាំបានទេ?

**ឆ៖** បាទ ការផ្លាស់ប្តូរនៅកន្លែងហ្នឹងជានិច្ចកាលហើយទាន មិនមែនជាប់រហូតទេបាទ។ សូម្បីខ្ញុំហ្នឹង ២៤ថ្ងៃនៅកន្លែងហ្នឹងៗ តែប៉ុណ្ណឹងទេក៏អត់ដែលបានតទៅទៀតដែរ មិនដឹងជាអ្នកណាផ្លាស់ប្តូរអីទៀតទេ។ ប៉ុន្តែក្នុងសម័យដែលខ្ញុំនៅនោះ មានការផ្លាស់ប្តូរជានិច្ច មានការស្លាប់ក្នុងមន្ទីរហ្នឹងជានិច្ចដែរបាទ។ អ៊ីចឹងជាផ្លាស់ប្តូរទាន មិនមែនជាប់នៅតែហ្នឹងទេ បាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ពីចំនួនផ្លាស់ប្តូរនេះបានទេ? ចំនួនចេញ ហើយនិងចំនួនចូលថ្មីនេះមានជាទូទៅមានចំនួនប៉ុន្មាន? អាចគិតជាភាគរយ?

**ឆ៖** បាទ យើងគិតមិនបានទេ ជួនកាលក៏បាត់ឃើញប្រាំនាក់ទៅ ឃើញប្រាំនាក់ប្លែកមក ឬ១០នាក់ប្លែកមកទៀត ឬបាត់១០ទៅ ឃើញពីរនាក់ប្លែកមកទៀត ហ្នឹងអ្នកជាប់គុក។ ក្រោយសួរចម្លើយហើយបាត់ក៏មាន ក្រោយសួរចម្លើយហើយ មានក៏មានដែរ។

**ស៖** បាទ ចុះបើយើងគិតជាសរុបប្រចាំថ្ងៃ ឬក៏ប្រចាំសប្តាហ៍វិញ អ្នកដែលបាត់ ឬអ្នកដែលចូលថ្មីហ្នឹងមានចំនួនប៉ុន្មានដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទបញ្ជាក់ជូនមិនបានទេទាន ពីព្រោះថាការចេញចូល ដូចខ្ញុំជម្រាបអ៊ីចឹង វាអត់ប្រក្រតី។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរលោក នៅពេលដែលលោកជាប់នៅក្រាំងតាចាន់នេះដដែល លោកបានឆ្លើយកន្លងមកថា គេបានសួរលោក។ ខ្ញុំចង់ដឹងថា តើគេសួរលោកប៉ុន្មានដងនៅពេលដែលលោកជាប់ក្នុងរយៈពេល២៤ថ្ងៃនោះ?

**ឆ៖** បាទ ឃើញមនុស្សដដែលហ្នឹងសួរខ្ញុំហ្នឹង ដូចអាចារ្យឆេន ហ្នឹងនៅក្របីព្រៃម្តង។ ទៅដល់មន្ទីរនោះសួរបីដងទៀតទាន។

**ស៖** បាទ សូមអរគុណ។ សួរបីដងនោះ សួរក្នុងរយៈពេលថ្ងៃតែមួយ ឬក៏រំលងមួយថ្ងៃពីរថ្ងៃបានសួរម្តងទៀត?

[១០:០១:៥២]

**ឆ៖** មិនមែនសួរពេលតែមួយទេទានណ៎ា! បាទ គេរឭកឃើញសួរថ្ងៃណាគេហៅសួរទៅបាទ គេរឭកឃើញថ្ងៃណា គេហៅសួរទៅ សូមទោស។

**ស៖** បាទ សូមអរគុណ។ អំមិញលោកបានបញ្ជាក់ថា ឈ្មោះអាចារ្យ ឆេន បានសួរលោក។ លោកមានចាំថា មានអ្នកផ្សេងទៀតជាអ្នកសួរលោកទេ?

**ឆ៖** បាទ ឃើញតែម្នាក់ហ្នឹងទេដែលសួរខ្ញុំ ដែលសួរគេគ្រប់គ្នា ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងរណ្តៅសាកសព លោកបានបញ្ជាក់ថា លោកបានចូលរួមជីកចំនួនប្រាំបីរណ្តៅ។ ខ្ញុំចង់ដឹងថា តើការជីកនេះ លោកសំដៅទៅដល់ការជីករាប់ឆ្អឹង រាប់លលាដ៍ក្បាលដែលលោកបានរាប់ឃើញថាចំនួនមួយម៉ឺនជាងនោះ ឬមួយក៏លោកបានចូលរួមជីកដើម្បីកប់សាកសព?

**ឆ៖** រណ្តៅដែលសម្រាប់កប់សាកសពនោះ អ្នកដែលទើបចូលទៅថ្មី នៅមានកម្លាំងកំហែង គេចេះតែឲ្យជីកបន្តអ្នកហ្នឹង ជីកបន្ត ហើយដែលវ៉ៃកប់ដាក់នោះ ក៏ចេះតែវ៉ៃកប់ដាក់បន្តអ៊ីចឹងដែរណ៎ា។

**ប្រធានអង្គជំនុំ៖**

មិនចំសំណួរទេ លោកមេធាវីតាំងសំណួរសាជាថ្មីម្តងទៀត ដើម្បីឲ្យគាត់ឆ្លើយស្តាប់សំណួរឲ្យយល់ ហើយឆ្លើយឲ្យចំសំណួរ។

[១០:០៣:៥០]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ សំណួររបស់ខ្ញុំ ខ្ញុំចង់បញ្ជាក់ថា លោកជាអ្នកជីករណ្ដៅដើម្បីកប់សាកសពនៅពេលដែលសាកសពស្លាប់ ឬមួយក៏លោកជាអ្នកជីកកកាយយកឆ្អឹងដែលចេញពីរណ្ដៅនោះឬក៏ទាំងពីរ? សូមលោកបញ្ជាក់។

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ ទាំងការជីកកប់ក៏ជាមួយពួកអ្នកទោសដែរ ហើយការជីកឡើងវិញក៏ខ្ញុំបានរួមជីកដែរ។

**ស៖** បាទសូមអរគុណ។ លោកអាចបញ្ជាក់ពីទំហំរណ្ដៅដែលលោកបានជីក ដើម្បីកប់នោះទេ?

**ឆ៖** ការដែលយើងជីក យើងអត់បានដឹងទំហំទេ ចេះតែជីកតាមគេវាស់ដីឲ្យជីកទានណ៎ា តែដល់ពេលយើងគាស់ ក៏រណ្ដៅនៅសព្វថ្ងៃហ្នឹងដែរទេ ប្រហែលជាបីម៉ែត្របួនជ្រុង ជម្រៅពីម៉ែត្រ បីម៉ែត្រពីរម៉ែត្របួនជ្រុង ជម្រៅមួយម៉ែត្រកន្លះ អ៊ីចឹងទាន មិនដូចគ្នាទេ។

**ស៖** បាទ សូមអរគុណ។ ទំហំទាំងប្រាំបីរណ្ដៅដែលលោកបានជីកនោះ មានទំហំប្រហាក់ប្រហែលគ្នា ឬមួយក៏មានទំហំតូចធំជាងគ្នាច្រើន លោកអាចបញ្ជាក់បានទេ?

**ឆ៖** ពេលដែលយើងជីកយកឆ្អឹងខ្មោចឡើងវិញនោះ ទំហំឃើញថាអត់ដូចគ្នាទេ ខ្លះក៏ធំ ខ្លះក៏តូច ខ្លះក៏ជ្រៅ ខ្លះក៏រាក់។

**ស៖** បាទ លោកអាចបញ្ជាក់ធំបំផុតប៉ុន្មាន ហើយតូចបំផុតទំហំប៉ុន្មាន?

**ឆ៖** បាទ រណ្ដៅដែលធំបំផុតមានត្រឹមបួនម៉ែត្របួនជ្រុង និងតូចបំផុតគឺពីរម៉ែត្របួនជ្រុង។

[១០:០៦:១៤]

**ស៖** បាទ សូមអរគុណ។ កាលពីថ្ងៃទី០២ ខែកុម្ភៈ កន្លងទៅនេះ នៅក្នុងបន្ទប់សវនាការនេះ នៅម៉ោង ១៥:១៦:៤៩ លោកបានឆ្លើយបញ្ជាក់អំពីចំនួនមនុស្សស្លាប់នៅក្នុងរណ្ដៅ ដែលលោកបានប្រមូលបាន ហើយលោកបានរកឃើញថា មានចំនួនមួយពាន់ -- សុំទោស -- ១០.០១៣នាក់។ ហើយចំនួននេះគឺក្រោយពីការបាត់បង់ដោយសារមានការយកចេញពីអ្នកស្រុក ហើយឬក៏សត្វឆ្កែដែលបានពាំចេញទៅក្រៅបាត់ខ្លះផង។ តើលោកនៅបញ្ជាក់ថានេះជាចំនួនពិតប្រាកដទេ?

**ឆ៖** បាទចំនួនដែលគាស់ឃើញនេះ ខ្ញុំសន្និដ្ឋានក្នុងចិត្តថាមិនពិតប្រាកដ។

**ស៖** សុំទោស ខ្ញុំសួរថាតើជាចំនួនដែលលោកបានរាប់ច្បាស់លាស់ពិតប្រាកដថា ឃើញចំនួន ១០.០១៣ លលាដ៍ក្បាលនេះដែរទេ?

**ឆ៖** បាទ លលាដ៍ក្បាលនេះដែលយើងរាប់ហើយហ្នឹង គឺពិតប្រាកដហើយ។

**ស៖** បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោកតំណាងសហព្រះរាជអាជ្ញា? បើលោកជំទាស់ៗនៅពេលសាក្សីមិនទាន់ឆ្លើយ តើលោកមានមតិយោបល់អ្វីទៅ? កុំឱ្យការឡើងហ្នឹងទៅជាការគ្រាន់តែជាការរំខានរបស់ដល់អង្គជំនុំជម្រះប៉ុណ្ណោះ។ គប្បីមានការប្រុងប្រយ័ត្ន។

**លោក ត្រាវិស ហ្វារ៖**

សូមអភ័យទោសលោកប្រធានដើម្បីបញ្ជាប្រតិចារឹក -- ចំនួនតួលេខនេះគឺមិនមែនតួលេខដែលឱ្យដោយសាក្សីទេ គឺ១២ -- គឺមានចំនួន ១២.១៣២នាក់ នេះជាតួលេខដែលសាក្សីបានផ្តល់។

[១០:០៨:៥៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតទៀតលោកមេធាវី។

**លោក គង់ សំអុន៖**

បាទសូមអរគុណ។ លោកប្រធានសូមអនុញ្ញាតបង្ហាញជាឯកសារ D22/1370.2 ដែលមាន ERN ជាភាសាខ្មែរ 00527797, ជាភាសាអង់គ្លេស 314056។ បាទ សុំទោសៗ លោកប្រធានដោយសារឯកសារនេះអត់មានជាភាសាអង់គ្លេសទេ ឬក៏ភាសាបារាំង។ ខ្ញុំចង់សួរបញ្ជាក់ទៅលើចំណុចមួយដែលនេះជាអត្ថបទរបស់អ្នកស្រាវជ្រាវម្នាក់ឈ្មោះ ញាណ សុជាតិ ចេញពីទស្សនាវដ្តីស្វែងរកការពិតផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ ដែលអត្ថបទនោះបានចេញលេខ៦០ នៅខែធ្នូ ឆ្នាំ២០០៤ ដែលមានចំណងជើង "អ្នកទោសគុកក្រាំងតាចាន់" ដែលមានលើកសម្តីមនុស្សម្នាក់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ត្រាវិស ហ្វារ៖**

សូមអធ្យាស្រ័យចំពោះការរំខាននេះ។ សូមឱ្យមេធាវីលើកឡើងពីលេខឯកសារឡើងវិញ ដោយសារយើងមិនមានឯកសារនេះទេ។

[១០:១១:០៣]

**លោក គង់ សំអុន៖**

សូមបញ្ជាក់ D22/1370.2។ បាទ ខ្ញុំសូមបញ្ជាក់ ERN ជាភាសាអង់គ្លេស 00527800។

**សួរដោយលោក គង់ សំអុន៖**

**ស៖** នៅក្នុងអត្ថបទនេះ ខ្ញុំសូមអានជូន ដកស្រង់៖ "គុកក្រាំងតាចាន់មានទីតាំងនៅទួលមួយក្នុងភូមិក្រាំងតាចាន់ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ។ គុកនេះគឺជាផ្នែកមួយនៃការកាន់កាប់ និងដឹងឮរបស់សមមិត្ត ឈិត ជឿន ហៅ ម៉ុក ដែលជាលេខាភូមិភាគនិរតី។ តាមការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រជាជនចំនួន១០៤៥នាក់ត្រូវឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ចោលនៅក្នុងគុកនេះ"។ លោកសាក្សី លោកស្តាប់សម្តីដកស្រង់របស់ខ្ញុំអម្បាញ់មិញបានទេ?

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** បាទ អត់ស្តាប់បានទេទាន។

**ស៖** បាទ ខ្ញុំសូមបញ្ជាក់ឡើងវិញ។ អ្នកស្រាវជ្រាវម្នាក់នេះបានលើកឡើងពីចំនួនអ្នកទោសដែលត្រូវស្លាប់ ឬក៏ត្រូវសម្លាប់នៅមន្ទីរឃុំឃាំងក្រាំងតាចាន់នោះ គឺចំនួន១០៤៥នាក់។ ខ្ញុំចង់សួរថា តើលោកអាចមានការឆ្លើយតបយ៉ាងម៉េចទៅនឹងការរកឃើញរបស់អ្នកស្រាវជ្រាវម្នាក់នេះដែរទេ? ពីព្រោះថាមានវាចំនួនខុសគ្នាពីចំនួនដែលលោកបានបង្ហាញជូនអង្គជំនុំជម្រះ។

[១០:១៣:៣១]

**ឆ៖** ខ្ញុំដូចជាមិនយល់អំពីពាក្យគេថាហ្នឹងសោះ ពីព្រោះពេលខ្ញុំវ៉ៃ -- ពួកគេវ៉ៃមនុស្សដាក់យើងអត់ដឹងចុះ តែដល់គាស់ឡើងមិនទាន់អស់រណ្តៅទេ ប៉ុន្តែឃើញមួយម៉ឺននាក់ជាងទៅហើយ ក្បាលលលាដ៍ក្បាលមនុស្សហ្នឹង ហើយដល់គេថាអ៊ីចឹង ខ្ញុំដូចជាមិនយល់ទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមបញ្ជាក់ត្រឡប់ទៅវិញទាក់ទងនឹងការជីករណ្តៅ។ ក្នុងអំឡុងពេលដែលលោកជាប់ឃុំរយៈពេល២៤ថ្ងៃនៅក្រាំងតាចាន់ លោកបានចូលរួមជីករណ្តៅចំនួនប៉ុន្មានដែរ?

**ឆ៖** ខ្ញុំបានចូលរួមជីករណ្តៅចំនួនបួនខាងកើតផុតបាទ។

**ស៖** បាទ លោកមានបានជួយកាយកប់រណ្តៅនោះវិញទេ?

**ឆ៖** បាទ ខ្ញុំបានជួយកប់គេតែម្តង ព្រោះថារណ្តៅនោះវាធំ ខាងកើតផុតខាងជើងផុត រណ្តៅហ្នឹងធំជាងគេ ជ្រៅ។ គេហៅយើងអ្នកទោសហ្នឹងចេញទៅទាំងអស់ ទៅជួយកប់គេ។

**ស៖** បាទ ចុះដល់ពេលក្រោយរំដោះ ១៩៧៩ លោកបានទៅកាយរណ្ដៅមួយនោះវិញទេ?

**ឆ៖** បាទ រណ្ដៅហ្នឹងដែលខ្ញុំច្បាស់លាស់ជាងគេ ស្គាល់ប្រាដកទីតាំងជាងគេ ក៏ខ្ញុំកាយមុនគេដែរទាន។

**ស៖** បាទ អរគុណ។ រណ្ដៅហ្នឹងមានទំហំប៉ុនណា លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ រណ្ដៅខាងជើងផុតខាងកើតផុតនេះទំហំបួនម៉ែត្របួនជ្រុងទាន។

**ស៖** ជម្រៅ?

**ឆ៖** ជម្រៅបីម៉ែត្រ។

**ស៖** បាទ អរគុណ។ លោកមានបានរាប់ចំនួនលលាដ៍ក្បាលដែលយកចេញពីរណ្ដៅមួយហ្នឹងដោយឡែកទេ?

**ឆ៖** បាទ ពេលរាប់គឺរាប់ផ្ដួបទាំងអស់ទាន។ អ្នកដែលចាំរាប់នោះគឺលោក គេជញ្ជូនក្បាលមកបានប៉ុន្មាន លោកចាំរាប់កត់ប៉ុណ្ណឹង។ អ៊ីចឹងរាប់ផ្ដួបទាំងអស់ ដែលលើកសពហ្នឹងបានក្រោយហ្នឹងមកប្រហែលជាមួយអាទិត្យបានយើងប្រមូលក្បាលហ្នឹងយកដាក់លើរានមួយ ក្រោយពីពេលបាត់ខ្លះទៅហើយហ្នឹង។

[១០:១៦:២៤]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីនៅមានសំណួរច្រើនទេ?

**លោក គង់ សំអុន៖**

នៅសល់ប្រហែលជា១៥នាទីទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីនិងមន្ត្រីនៃអង្គការ ធី.ភី.អូ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រលប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៅវេលា

ម៉ោងដប់សាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៧ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

[១០:៣៣:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបជូនសង្ខេបទេ ខ្ញុំមានបំណងកែតម្រូវសម្រាប់ប្រតិចារឹក។ ខ្ញុំថាវាជាបញ្ហាមួយលើកឡើងខុសទេនៅក្នុងសួរយកសក្ខីកម្ម គឺការសិក្សាស្រាវជ្រាវរបស់ ឌី.ស៊ី.ខេម ដែល -- គឺដែលថាតួលេខ -- ឯកសារ E3/206 ដែល ឌី.ស៊ី.ខេម បានរកឃើញតួលេខហ្នឹងថាវាមាន១០៤៥នាក់ហ្នឹង គឺមិនជារឿងត្រឹមត្រូវទេ។ ហើយនៅក្នុងរបាយការណ៍របស់យើងគឺមានចំនួន ១០០៤៣នាក់។ បាទ ហើយតួលេខជាតួលេខដែលសរសេរដោយដៃរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដូច្នេះខ្ញុំចង់ឲ្យបង្ហាញតួលេខត្រឹមត្រូវ មិន -- សូមជម្រាបអង្គជំនុំជម្រះថា បើស្នើសុំមិនឲ្យយកតួលេខដែលសរសេរឡើងដោយអ្នកណាម្នាក់ ក្រោយពេលមជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។

**លោក គង់ សំអុន៖**

ប្រធាន ខ្ញុំសូមឆ្លើយតបដោយខ្លីថា យើងកំពុងតែបង្ហាញសួរដេញដោលសាក្សី ចំពោះកំហុសផ្សេងៗដែលកើតឡើងទាក់ទងនឹងឯកសារនោះ អាហ្នឹងជាការស្វែងយល់ ហើយយើងនឹងលើកធ្វើការវាយតម្លៃនៅពេលធ្វើសេចក្តីសន្និដ្ឋាន។ ដូច្នេះ ខ្ញុំយល់ថាសហព្រះរាជអាជ្ញាមិនគួរលើកនៅពេលនេះទេ ពីព្រោះមិនមែនជាពេលវេលារបស់សហព្រះរាជអាជ្ញា ធ្វើការសន្និដ្ឋានកែតម្រូវទៅលើសក្ខីកម្មរបស់សាក្សីទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ទៅមុខទៀត បាទ សូមអញ្ជើញ! ហើយលោកមានមេធាវីមានរយៈពេល ៣០នាទីទៀត។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** អម្បាញ់មិញយើង -- ខ្ញុំមានបំណងចង់សួរលោកសាក្សីទាក់ទងទៅនឹងបន្ទប់ ឬក៏ទីតាំងសួរចម្លើយ។ លោកបានឆ្លើយថា លោកត្រូវបានគេសួរចម្លើយបីដងក្នុងរយៈពេលដែលលោកជាប់ឃុំនៅក្រាំងតាចាន់។ លោកអាចរៀបរាប់ពីសណ្ឋានហ្នឹងថែមទៀតបានទេ លោកបានបញ្ជាក់ហើយថា មានទំហំបួនគុណ -- ប្រាំមួយគុណ -- ប្រាំមួយម៉ែត្របួនជ្រុងបាទ ហើយមាន១ផាងដូងបាំងជាជញ្ជាំង។ ខ្ញុំចង់សួរបញ្ជាក់ថា តើទីតាំងពីកន្លែងសួរចម្លើយហ្នឹងទៅអគារឃុំខ្លួនជាទូទៅនោះ ដែលលោកបញ្ជាក់ថាមានទំហំប្រហែលបីម៉ែត្រគុណនឹង២០ម៉ែត្រនោះ មានចម្ងាយប្រហែលប៉ុន្មានពីគ្នាដែរ?

[១០:៣៦:៥៦]

**លោក កែវ ច័ន្ទតារ៉ា៖**

**ឆ៖** មិនមែនប្រាំមួយម៉ែត្របួនជ្រុងទេ ប្រហែលជាបីម៉ែត្រប្រាំមួយម៉ែត្រ។ ហើយគ្រាន់តែខាំងជញ្ជាំងមួយប៉ុណ្ណឹងទេ ហើយខាងគុកនេះមានរាន ខាងកន្លែងសួរចម្លើយនោះគឺនឹងដី ហើយអ្នកដែលគេមកសួរយើង គេអង្គុយកៅអី។

**ស៖** បាទ សូមអរគុណ។ មានទិសទីតាំងហ្នឹងខុស -- ចំទិសខាងលិច ឬខាងជើង ទិសខាងណាពីអគារហ្នឹងដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ នៅខាងលិចគុកហ្នឹងតែម្តងទាន។

**ស៖** បាទ សូមអរគុណ។ ចំពោះជញ្ជាំងដែលលោកនិយាយថា ប្រក់ស្លឹក បាំងស្លឹកដូង តើការបាំងនេះបាំងទាំងបួនទិស ឬក៏ -- ហើយទុកតែប្រឡោះទ្វារចូលទៅក្នុងបន្ទប់នោះ ឬមួយក៏បាំងយ៉ាងម៉េចដែរ សូមលោកពន្យល់ចំណុចនេះផង?

**ឆ៖** បាំងទាំងបួនទិស ទុកប្រឡោះចូលពីខាងជើង។

**ស៖** បាទ បាំងហ្នឹងគឺបាំងជិតតែម្តង ឬមួយក៏បាំងតែពាក់កណ្តាលនៃជញ្ជាំងទេ? ឧទាហរណ៍ថា បាំងត្រឹមចង្កេះជាដើម។

**ឆ៖** បាទ បាំងតាំងពីសំយ៉ាបដំបូលមកទល់គ្នានឹងដីទាន។

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់អំមិញថា វានៅជិត នៅខាងលិចនៃអគារធំ នៅជាប់នឹងជញ្ជាំង។ តើលោកអាចបញ្ជាក់ពីចម្ងាយពិតប្រាកដបានទេថា ប្រហែលប៉ុន្មានម៉ែត្រ?

[១០:៣៩:០៣]

**ឆ៖** បាទ ប្រហែលជាមួយម៉ែត្រទេ មិនឆ្ងាយទេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំមានសំណួរមួយទៀតទាក់ទងទៅនឹងរចនាសម្ព័ន្ធនៅភូមិភាគនិរតី។ លោកបានឆ្លើយបញ្ជាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយថា លោកបានស្គាល់ តាម៉ុក តាំងពីមុនរំដោះ ហើយធ្លាប់មានទំនាក់ទំនងជាមួយនឹងគ្រួសាររបស់លោកដែល កាលណោះ តាម៉ុក ជាលោកសង្ឃនៅឡើយ។ ខ្ញុំចង់សួរថា ក្នុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ជាពិសេសក្នុងពេលដែលលោកជាប់ឃុំនៅមន្ទីរក្រាំងតាចាន់នោះ លោកបានជួប តាម៉ុក មុនដំបូងបង្អស់នៅពេលណា?

**ឆ៖** បាទ ជួបតែម្ដង ដែលពេលគាត់ទៅស្រែកហៅឲ្យគេដោះលែងខ្ញុំចេញ។

**ស៖** បាទ ពេល តាម៉ុក ទៅស្រែកហៅហ្នឹង គាត់ចូលទៅក្នុងអគារឃុំឃាំងហ្នឹងដែរទេ?

**ឆ៖** បាទ ពេល តាម៉ុក ទៅស្រែកហៅហ្នឹងគឺស្រែកហៅពីក្រៅរបងបរិវេណទៅទៀត មិនមែនចូលទៅក្នុងមាត់របងទេទាន គឺខាងកើត។

**ស៖** បាទ សូមអរគុណ។ ស្រែកហៅថាម៉េច លោកចាំបានទេពេលហ្នឹង?

**ឆ៖** បាទ ចាំច្បាស់ណាស់សម្ដី តាម៉ុក ពេលហ្នឹងប៉ុន្តែធ្វើឲ្យខ្ញុំស្លុត គាត់ថា៖ “អាចារ្យឆេនឌុកទ័រម្នាក់យកមកទុកហ្នឹងធ្វើម្ហូបស៊ីនៅ?” ហើយយូរណាស់បានអាចារ្យឆេន ឆ្លើយថា៖ “នៅទេបង” អ៊ីចឹងគេថា៖ “អើ ឲ្យមកវិញមក អញមកពីត្បូងវិញយកទៅមន្ទីរពេទ្យ។”

**ស៖** បាទ អរគុណ។ លោកបានឃើញ តាម៉ុក ហ្នឹងច្បាស់ទេនៅពេលដែលឮសំឡេងស្រែកហៅហ្នឹង?

**ឆ៖** ខ្ញុំនៅក្នុងមន្ទីរឃុំឃាំងមើលអត់ឃើញគាត់ទេ បាទ ដល់តែពេលចេញមកវិញ ក៏គាត់អត់មកជាមួយអ្នកដែលយកម៉ូតូមកឌុបខ្ញុំហ្នឹងដែរ។

**ស៖** បាទ សូមអរគុណ។ លោកដឹងពីថ្នាក់នាំនៅភូមិភាគនិរតីហ្នឹងដែរទេ?

[១០:៤២:២៣]

**ឆ៖** ខ្ញុំអត់បានដឹងទេទានហើយ មិនដឹងអ្នកណាជាថ្នាក់ដឹកនាំនៅក្នុងភូមិភាគហ្នឹងទេ។

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលនោះលោកដឹងថា តាម៉ុក មានឋានៈជាអ្វីដែរទេ?

**ឆ៖** ពេលនោះខ្ញុំអត់ដឹងថា តាម៉ុក មានឋានៈជាអ្វីទេ។ ប៉ុន្តែចំពោះប្រជាពលរដ្ឋទាំងអស់ ដែលគេហៅ "តាៗ" ហ្នឹងគឺថាអ្នកធំហើយទាន សម័យខ្មែរក្រហម។

**ស៖** លោកមានដឹងថា តាម៉ុក មានការគ្រប់គ្រងនៅក្នុងភូមិភាគនិរតីហ្នឹងយ៉ាងដូចម្ដេចដែរទេ?

**ឆ៖** ចំពោះខ្ញុំជាមួយ តាម៉ុក ដូចជាមិនមានអ្វីដែលធ្វើឲ្យខ្ញុំថាគាត់ហ្នឹងជាមនុស្សកាចសាហាវទេ តែអ្នកដទៃខ្ញុំអត់ដឹងទេ បាទ។

**ស៖** បាទ ខ្ញុំសូមរំឭកលោក លោកមានប្រសាសន៍អំពីការចុះពិនិត្យនៅសហករណ៍មួយឈ្មោះសហករណ៍ឃុំកន្ទួតរបស់ តាម៉ុក។ តើលោកនៅចាំពីព្រឹត្តិការណ៍ហ្នឹងដែរទេ?

[១០:៤៥:០០]

**ឆ៖** បាទ គាត់ចូលទៅដល់នោះ ខ្ញុំក៏នៅហូបបាយហ្នឹងដែរ។ តាម៉ុក ហ្នឹងជេរស្ដីឲ្យអ្នកប្រធានសហករណ៍ថា៖ "ពួកអ្វែងធ្វើការអ៊ីចឹង ឲ្យគេចូលធ្វើបដិវត្តជាមួយម៉េចកើត?" ហើយគាត់ចាក់សម្លដែលមានស្លហើយហ្នឹងចោលអស់ គាត់ឲ្យស្លជាថ្មីដើម្បីឲ្យហូបទាន បាយក៏អ៊ីចឹងដែរ។

**ស៖** បាទ សូមអរគុណ។ ក្រោយមកលោកមានឃើញប្រតិកម្មរបស់អ្នកនៅក្នុងសហករណ៍នោះតបទៅនឹង តាម៉ុក វិញដូចម្ដេចដែរ?

**ឆ៖** បាទ ពេលនោះគ្មាននរណាហ៊ានមាត់អ្វីមួយម៉ាត់ទេ សូម្បីអ្នកទៅអង្គុយរង់ចាំហូបបាយក៏អត់មានមាត់អីដែរទាន។

**ស៖** លោកបានជួប តាម៉ុក ញឹកញាប់ទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** មិនបានជាជួបញឹកញាប់អ្វីទេ ប៉ុន្តែតានេះពូកែដើរណាស់ ខ្ញុំនៅក្នុងការដ្ឋានជីកប្រឡាយការដ្ឋានបូមទឹក ការដ្ឋានជីកសំណាប ហើយជួបគាត់ញឹកញាប់ទៅ។ ជួបតែក្នុងពេលដែលធ្វើការងារហ្នឹង ក្រៅពីនោះមិនដែលបានជួបទេ។

**ស៖** បាទ ទាក់ទងទៅនឹងមូលហេតុនៃការដោះលែងលោកចេញពីក្រាំងតាចាន់ នៅពេលដែល តាម៉ុក មកយកលោកទៅនោះ លោកបានបញ្ជាក់ពីការប្រើប្រាស់ម៉ាស៊ីនម្យ៉ាង ថាដែលលោកសន្និដ្ឋានថាប្រហែលជា ដោយសារលោកមានសមត្ថភាពផ្នែកប្រើប្រាស់ ឬក៏ជួសជុលឧបករណ៍នោះ ទើប តាម៉ុក មកយកលោកទៅ។ តើលោកអាចបញ្ជាក់ពីជំនាញរបស់លោកទាក់ទងនឹងឧបករណ៍នោះបានទេ? តើឧបករណ៍ជាអ្វីដែរ លោកអាចបញ្ជាក់ម្ដងទៀតបានទេ?

[១០:៤៦:៣២]

**ឆ៖** បាទ ឧបករណ៍ហ្នឹង គឺម៉ាស៊ីនវ៉ាដ្យូក្រាហ្វី តែក៏ខ្ញុំមិនធ្វើតែម្នាក់ឯងដែរ មកដល់ទីហ្នឹង គឺមានគ្នាច្រើនជួយធ្វើ ទាន។

**សៈ** បាទ តើ តាម៉ុក គាត់មានបានបញ្ជាក់ ឬក៏និយាយប្រាប់លោកពីសេចក្តីត្រូវការរបស់គាត់ឲ្យទៅជួយជួសជុលម៉ាស៊ីនវ៉ាដ្យូហ្គ្រាស់ហ្វីនេះដែរទេ?

**ឆ៖** គាត់អត់បានបញ្ជាក់អីទាំងអស់ទាន អត់បានប្រាប់ថា យ៉ាងណាៗក៏អត់ដែរ។ គ្រាន់តែយកទៅចោលនៅកន្លែងមន្ទីរពេទ្យហ្នឹងទៅ ក៏ជួយធ្វើគេអ៊ីចឹងទៅ គេឲ្យធ្វើអី ក៏ខ្ញុំធ្វើហ្នឹងទៅ។

**សៈ** លោកអាចបញ្ជាក់យ៉ាងដូចម្តេចចំពោះគ្រួសាររបស់លោក ហើយនិង តាម៉ុក អំពីទំនាក់ទំនងរវាងគ្រួសារលោកទាំងពីរហ្នឹង? មានស្ថានភាព ឬក៏លក្ខណៈយ៉ាងដូចម្តេចដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ក្រោយពេលម្តាយខ្ញុំស្លាប់ទៅ មិនជាទំនាក់ទំនងជិតស្និទ្ធអ្វីទេ។ គ្រាន់តែមានការផ្តាំផ្ញើពី តាម៉ុក នោះមកថា ឲ្យខ្ញុំខំក្បត់ធាតុដើមឲ្យអស់ ពីព្រោះបញ្ញវន្ត អនុធន ជាស្រទាប់សេរី។ គេគ្រាន់តែមកប្រាប់ខ្ញុំតែប៉ុណ្ណឹងទេទាន។

**សៈ** បាទ ពេលដែលលោកចាកចេញពីមន្ទីរក្រាំងតាចាន់ ការងារដំបូងដែលលោកបាន -- ទីកន្លែងដំបូង និងការងារដំបូង ដែលលោកបានធ្វើនោះជាការងារអ្វី ហើយនិងកន្លែងណាដែរ?

**ឆ៖** បាទ ចេញពីមន្ទីរក្រាំងតាចាន់ទៅ ខ្ញុំអត់ទាន់បានមកចូលផ្ទះទេ។ គេនាំខ្ញុំទៅរហូតមន្ទីរពេទ្យរបស់ពួកខ្មែរក្រហមហ្នឹងទានណ៎ា។ ខ្ញុំទៅជួយធ្វើម៉ាស៊ីនគេហ្នឹងហើយ ក៏គេសួរអំពីសម្ភារៈពេទ្យអានេះឈ្មោះអី ថ្នាំពេទ្យអានេះឈ្មោះអីអ៊ីចឹងទាន ហើយអស់រយៈពេល ខ្ញុំអត់បានគិតជាថ្ងៃដែរ ទើបគេជូនខ្ញុំមកផ្ទះ។

[១០:៤៩:០២]

**សៈ** បាទ សូមអរគុណ។ បាទ ទាក់ទងទៅនឹងការស្រាវជ្រាវមួយ ក្រោយព្រឹត្តិការណ៍១៩៧៩ លោកមានធ្លាប់មានទំនាក់ទំនងជាមួយនឹងមន្ត្រីណាម្នាក់នៃអង្គការអុកហ្វាមដែរទេ?

**ឆ៖** បាទ ធ្លាប់ទាក់ទងនឹងមន្ត្រីអង្គការអុកហ្វាមហ្នឹង គឺម្នាក់ស្រីឈ្មោះ អេលីប្រេន ហើយប្រុសម្នាក់ឈ្មោះ តូហ្សព្យែរ។

**សៈ** បាទសូមអរគុណ។ លោកអាចបញ្ជាក់អំពីការងារដែលលោកបានធ្វើជាមួយអ្នកទាំងពីរ

អម្បាញ់មិញបានទេ ថាជាការងារអ្វី?

**ឆ៖** គាត់ទៅជួយផ្ដល់ពោតសាលី ទឹកដោះគោម្សៅ និងជួយជីកអណ្ដូងដល់ប្រជាពលរដ្ឋដែលក្រីក្រ ដែលអត់។

**ស៖** បាទសូមអរគុណ។ លោកមានរៀបរាប់ពីការប្រមូលឆ្អឹង ឬអដ្ឋិធាតុនៅក្នុងមន្ទីរក្រាំងតាចាន់ដែរទេ ទាក់ទងនឹងបញ្ហាប្រមូលឆ្អឹងក្រាំងតាចាន់?

**ឆ៖** ឆ្អឹងនេះ យើងជីកហើយទុកគរមួយកន្លែង ប្រមូលដាក់លើផ្ទះមួយ។ ក្រោយមកទៀតយើងប្រមូលដាក់ក្នុងស្ដូបដែលយើងសុំឱ្យអ្នកសប្បុរសជនដែលជួយធ្វើស្តូបសព្វថ្ងៃនេះ យកដាក់ក្នុងស្តូប កុំឱ្យបាត់បង់ឆ្អឹងនេះតទៅទៀត។

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរ។

[១០:៥១:២៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ លោក កែវ ច័ន្ទតារ៉ា អង្គជំនុំជម្រះសូមអរគុណចំពោះលោកដែលបានចំណាយពេលវេលាដ៏មានតម្លៃ មកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយរហូតមកដល់ពេលនេះ ការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីបានចប់ហើយ។ វត្តមានរបស់លោកនៅក្នុងបន្ទប់សវនាការនេះ លែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅវិញ។ ហើយក៏ដូចគ្នាដែរ សូមអរគុណចំពោះបុគ្គលិក ធី.ភី.អូ ដែលបានមកជួយគាំពារពង្រឹងស្មារតីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មព្រឹកនេះ។ បាទលោកអាចត្រឡប់ទៅវិញបានហើយ។

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី TCCP-271 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១០:៥៤:៤៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ**

**ស៖** សួស្តី ដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកឈ្មោះអី?

**លោក សយ សែន៖**

**ឆ៖** បាទសូមគោរពចៅក្រមជាទីគោរព! ខ្ញុំឈ្មោះ សយ សែន នៅឈើទាលប្រគាប ឃុំអង្គតាសោម ត្រាំកក់។

**ស៖** បាទ អរគុណ។ ហើយលោកចាំទេថាលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** បាទ មិនអាចចាំបាន កាលហ្នឹងខ្ញុំវានៅវ័យក្មេងដែរ ក៏ជំនាន់ហ្នឹង ខ្ញុំក៏វាអត់--

**ស៖** លោកចាំឆ្នាំកំណើតរបស់លោកទេ តើលោកកើតនៅក្នុងឆ្នាំណា?

**ឆ៖** បាទ មិនអាចចាំបានទេ។

**ស៖** ចុះលោកអាយុប៉ុន្មានហើយឥឡូវនេះ?

**ឆ៖** បាទ អាយុ៥៧។

**ស៖** អរគុណ ហើយទីកន្លែងកំណើតរបស់លោក តើលោកកើតនៅទីកន្លែងណា?

**ឆ៖** បាទ ទីកំណើតខ្ញុំកើតនៅ ពីដើមគេហៅថាភូមិត្រពាំងពោធិ៍ ឃុំសំរោង ស្រុកត្រាំកក់តាកែវដូចគ្នា។

[១០:៥៦:១៩]

**ស៖** អរគុណ។ ចុះទីលំនៅសព្វថ្ងៃនេះ តើលោកនៅទីកន្លែងណា?

**ឆ៖** ស្រុកកំណើតសព្វថ្ងៃ ខ្ញុំនៅអង្គតាសោម ត្រាំកក់ តាកែវដដែល។

**ស៖** តើលោកប្រកបមុខរបរធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** កសិករ ធ្វើស្រែ។

**ស៖** ឪពុករបស់លោកឈ្មោះអី ហើយម្តាយរបស់លោកគាត់ឈ្មោះអីដែរ?

**ឆ៖** ឪពុកខ្ញុំឈ្មោះ ណាំង សយ, ម្តាយ ឃុត សែ -- ឃុន សន។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោក គាត់ឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** បាទ គ្រួសារខ្ញុំឈ្មោះ ឃិន សាវង្ស។ កូនទាំងអស់មានប្រាំពីរនាក់។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបលោក សយ សែន ថាជានៅដំណាក់កាលចុងក្រោយបង្អស់នៃការផ្តល់សក្ខីកម្មរបស់លោក នៅក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ បាទនេះជានៅពេលចុងក្រោយទេយើងនឹងសួរលោក នឹងផ្តល់ឱកាសឲ្យលោកលើកបញ្ហានេះប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

ហើយឥឡូវនេះដើម្បីអនុវត្តនូវបទប្បញ្ញត្តិវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះមុនភាគីដទៃទៀតនៃរឿងក្តី។ សូមអញ្ជើញបាទ!

[១០:៥៨:២៥]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម មេធាវីនាំមុខសូមគោរពអនុញ្ញាតលោកប្រធាន លោក លោកស្រីចៅក្រម ផ្ទេរសិទ្ធិជូនលោកស្រី ម៉ុច សុវណ្ណារី និងលោកស្រី ម៉ាទីន ហ្សាកកាំងដើម្បីសួរសំណួរទៅលើដើមបណ្តឹងរដ្ឋប្បវេណី សយ សែន។ បាទសូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអាធ្យាស្រ័យដែលខ្ញុំរំខានតាំងពីដើមទី ខ្ញុំមានច្របូកច្របល់បន្តិច តាំងពីកាលបរិច្ឆេទ ថ្ងៃខែឆ្នាំកំណើត និងឈ្មោះឪពុករបស់គាត់ ដូចមានភាពច្របូកច្របល់។ គ្រាន់តែចង់បញ្ជាក់ថា តើយើងមានដើមបណ្តឹងរដ្ឋប្បវេណីត្រឹមត្រូវដែរឬក៏អត់ ពីព្រោះខ្ញុំមានឈ្មោះឪពុករបស់គាត់ គឺថាខុសគ្នា ហើយថ្ងៃខែឆ្នាំកំណើតរបស់គាត់ក៏ខុសគ្នាផងដែរ។ ដូច្នេះ ខ្ញុំសូមស្នើសុំឲ្យអង្គជំនុំជម្រះបង្គាប់ទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរចំចំណុចនេះឲ្យបានច្បាស់លាស់។

**ប្រធានអង្គជំនុំ៖**

លោកដូចមានពេលវេលាសួរសាក្សីរូបនេះដែរ ហើយគួរតែលៃពេលវេលាសម្រាប់ របស់លោក

សួរបញ្ជាក់លើចំណុចណាដែលលោកចង់ដឹងទៅ។ ទី២ បញ្ហាអាយុគាត់មិនចាំថ្ងៃខែឆ្នាំកំណើត ប៉ុន្តែគាត់បានបង្ហាញពីអាយុរបស់គាត់យ៉ាងច្បាស់លាស់ហើយ។ ដោយសារវប្បធម៌ខ្មែរ ភាគច្រើនគាត់មិនប្រើឆ្នាំកំណើតទេគាត់ប្រើអាយុ អ៊ីចឹងគាត់ចាំអាយុ ជាងឆ្នាំកំណើត។ យើងប្រឹងនិយាយសួរនាំអំពីពាក្យឆ្នាំកំណើតនេះក្នុងគោលបំណងមួយទៀត គឺទី១ ឲ្យត្រឹមត្រូវ ទី២ បញ្ហាបលើនីតិវិធីនៃការសួរដេញដោលបុគ្គលដែលពាក់ព័ន្ធនៅក្នុងចំពោះមុខអង្គជំនុំជម្រះនៅក្នុងកម្ពុជានេះ ឲ្យប្រើប្រាស់អាយុ ឬក៏ឆ្នាំកំណើតនេះជាគោល ដើម្បីឲ្យមូលដ្ឋាននៃការកំណត់ហេតុហ្នឹងវាស្ថិតស្ថេរទៅ ជៀសវាងថាប៉ុន្មានឆ្នាំក្រោយគាត់ឆ្លើយថាអាយុដដែល ឬក៏ឯកសារហ្នឹងមើលទៅអាយុដដែល ១០ឆ្នាំក្រោយក៏ឃើញនៅតែអាយុ៥៧។ តាមពិតបើយើងប្រាប់ឆ្នាំកំណើតវាស្ថិតស្ថេរតែម្តង បានន័យថា ប្រាប់តែម្តងយើងយល់ដឹងថាមនុស្សហ្នឹងគឺមានឆ្នាំកំណើតយ៉ាងម៉េច ហើយអាយុគាត់ប៉ុន្មាន យើងគិតជាក់ស្តែងនៅពេលនោះ។

សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមធ្វើសំណូមពរតូចមួយទាក់ទងនឹងឯកសារ E319.1.5 ដែលតំណាងសហព្រះរាជអាជ្ញាបានដាក់ ហើយនិងឯកសារមួយចំនួនទៀតទាក់ទងនឹងប្រភេទឯកសារស្រដៀងគ្នានេះ ដោយខាងយើងមិនអាចចូលបានដើម្បីបើកយកឯកសារទាំងអស់នោះទេ។ ដូច្នេះសូមឲ្យអង្គជំនុំជម្រះមេត្តាចាត់ចែងយ៉ាងម៉េចឲ្យយើងអាចបើកឯកសារ ដែលដាក់ដោយតំណាងសហព្រះរាជអាជ្ញានេះបានបាទ។ សូមអរគុណ។

[១១:០១:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៥:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការលើសំណើសុំរបស់លោកមេធាវី គង់ សំអុន ដែលបានលើកឡើងពីបញ្ហាឯកសារដែលនឹងប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ ដែលខ្លួនលោកដែលជាភាគីមួយដែលមិនអាចមើលឃើញនូវឯកសារដែលដាក់នៅក្នុងសំណុំរឿងមួយចំនួននេះ។ ហើយអង្គជំនុំជម្រះនឹងលើកយកបញ្ហានេះមកពិនិត្យ ហើយនិងសម្រេចនៅក្នុងអំឡុងពេលនៃការអាហារថ្ងៃត្រង់នេះ ដើម្បីបញ្ជាក់ទៅជាមួយនឹងខាងមន្ត្រីគ្រប់គ្រងឯកសារដើម្បីរៀបចំបញ្ហានេះឲ្យប្រព្រឹត្តទៅបានល្អប្រសើរ។

បាទ សូមផ្ដល់វេទិកានេះជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអញ្ជើញ!

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណ។ ជាដំបូង នាងខ្ញុំសូមគោរពដល់លោកប្រធានអង្គជំនុំជម្រះ ក៏ដូចជាអស់លោក លោកស្រី ដែលជាចៅក្រមនៃអង្គជំនុំជម្រះ សហភាតា សហព្រះរាជអាជ្ញា លោក សយ សែន ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គសវនាការទាំងមូល។

[១១:០៦:៣៥]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនចង់សួរដល់លោក។ ជាដំបូង នាងខ្ញុំសូមសួរទាក់ទងជាមួយនឹង -- សូមឲ្យលោកបញ្ជាក់ទាក់ទងជាមួយនឹងប្រវត្តិរូបរបស់លោក។ ទាក់ទងជាមួយនឹងដើមកំណើតរបស់លោក ឪពុកម្ដាយរបស់លោកនៅមុនពេលដែលសម័យខ្មែរក្រហមបានមកដល់។ តើលោកអាចជម្រាបជូនអង្គសវនាការទាំងមូលបានទេពីទំនាក់ទំនងថាតើឪពុករបស់លោកជាអ្នកណា? ហើយហេតុអ្វីបានជាស្គាល់ម្ដាយរបស់លោក? តើលោកកើតមកនៅកន្លែងណា? ហើយតើទំនាក់ទំនងលោកជាមួយនឹងឪពុករបស់លោកយ៉ាងម៉េចដែរ?

**លោក សយ សែន៖**

**ឆ៖** បាទ ម្ដាយខ្ញុំមុនដំបូងបង្អស់ គាត់ទៅស៊ីឈ្នួលតាមេស្រុក សយ ហ្នឹងពីជំនាន់សីហនុៗ អ៊ីចឹង គាត់មេស្រុក សយ ហ្នឹងគាត់យកម្ដាយខ្ញុំបានខ្ញុំមួយហ្នឹងមានទារកនៅក្នុងផ្ទៃពោះ គាត់ក៏បកមកនៅខាងដីរំដោះ ខាងខ្មែរក្រហមឆ្នាំ៧០ ៗគាត់ចេញពីអង្គតាសោមនោះទៅនៅខាងដីរំដោះ ហើយក៏បានខ្ញុំមួយហ្នឹង។ ហើយក៏គាត់អត់មាន -- តាជាឪពុកខ្ញុំហ្នឹងមេស្រុក សយ ហ្នឹងក៏មិនមែនជាឪពុកគ្រប់លក្ខណៈជាពេញច្បាប់ដែរបាទ។

**ស៖** អ៊ីចឹង បើសិនជាខ្ញុំចាប់មិនខុសទេ យល់មិនខុសទេ មានន័យថាលោកពូគឺកើតនៅក្នុងទឹកដីរំដោះ មិនមែននៅខាងទឹកដីដែលឪពុកលោកពូស្នាក់នៅទេ។ អ៊ីចឹងតើលោកពូ ហើយនិងទំនាក់ទំនងរបស់លោកពូ ហើយនិងឪពុកលោកពូហ្នឹងយ៉ាងម៉េចដែរ? តើលោកពូស្គាល់គាត់ដែរ? ស្គាល់គាត់នៅក្នុងកម្រិតណា?

[១១:០៨:៣៨]

**ឆ៖** បាទ ខ្ញុំអត់បានស្គាល់គាត់ជាច្បាស់លាស់ទេ ប៉ុន្តែក្រែងតែបងប្អូនគាត់សាច់សាលោហិត គាត់នៅជុំវិញហ្នឹងគាត់ប្រាប់ខ្ញុំ ថាតាមេស្រុក សយ ហ្នឹងជាឪពុកអ្អែងហើយ ព្រោះម្ដាយអ្អែងទៅនៅជាមួយគេមុនដំបូងបាទ។ គ្រាន់បានដឹងតែប៉ុណ្ណឹងទេខ្ញុំ។

**ស៖** សំណួរចុងក្រោយទាក់ទងជាមួយនឹងចំណុចនេះ អ៊ីចឹងខ្ញុំសូមសួរលោកបញ្ជាក់ថា តើយើងអាចនិយាយបានទេថាលោកពូ ហើយនិងឪពុកលោកពូគឺមិនដែលស្គាល់គ្នា ហើយមិនដែលរស់នៅជាមួយគ្នាទាល់តែសោះ?

**ឆ៖** បាទ អត់ៗដែលបាននៅជាមួយគ្នាទេ ប៉ុន្តែបានជាបងប្អូនសាច់សាលោហិតគាត់ប្រាប់ថា ៗហ្នឹងហើយជាឪពុកអ្អែង។ ប៉ុន្តែខ្ញុំមិនបានជួបគាត់ផ្ទាល់ អត់ដែលបានជួបទេ ប៉ុន្តែបានឃើញពីចម្ងាយ ៗ ដោយសារតាគាត់នៅជិតហ្នឹងគាត់ប្រាប់បាទ។

**ស៖** អរគុណលោកពូ។ អម្បាញ់មិញនេះឆ្លើយតបទៅនឹងសំណួររបស់លោកប្រធាន ទាក់ទងជាមួយនឹងឈ្មោះលោកពូ លោកពូបានជម្រាបជូនអង្គសវនាការថាលោកពូឈ្មោះ សយ សែន។ អ៊ីចឹងខ្ញុំមានសំណួរចង់សួរលោកពូថា តើឈ្មោះនេះគឺលោកពូបាននៅក្នុងពេញមួយរបបខ្មែរក្រហម តាំងតែពីពេលដែលលោកពូកើតមក តើលោកពូប្រើឈ្មោះនេះ ឈ្មោះ សយ សែន នេះតែម្ដងឬក៏អត់ដែរ -- ឬៗដែរឬទេ?

[១១:១០:០៩]

**ឆ៖** បាទ ពីមុនមកខ្ញុំអត់ប្រើឈ្មោះ សយ សែន ខ្ញុំប្រើ ឃុត សែន។ កាលណាប្រើ សយ សែន ថាខ្ញុំជាកូនតាមេស្រុក សយ អ៊ីចឹងគឺគេសម្លាប់អស់ អត់ទុកទេ។

**ស៖** អ៊ីចឹង ខ្ញុំសូមសួរបន្ថែមមួយទៀត ដោយសារលោកពូមានប្រសាសន៍នឹងចម្លើយហ្នឹង ខ្ញុំចង់សួរថា ហេតុអ្វីបានជាលោកពូយកត្រកូល "ឃុត" ហ្នឹង យកជាៗ -- យក "ឃុត" ហ្នឹងជាត្រកូលរបស់លោកពូនៅសម័យនោះ?

**ឆ៖** បាទ មានយាយដូនមួយគាត់នៅក្បែរហ្នឹង គាត់ឲ្យដាក់អ៊ីចឹងតែម្ដង គាត់ថាឲ្យដាក់ "ឃុត សែន" ទៅកុំដាក់ "សយ សែន" តែដាក់ "សយ សែន" គេថាអ្អែងនេះកូនមេស្រុក សយ គេសម្លាប់ទាំងអស់។ បើអ៊ីចឹងដាក់ ឃុត សែន ហើយថាកូនកំព្រាអត់ម៉ែអត់ឪ។

**ស៖** ទាក់ទងជាមួយនឹងអាយុរបស់លោក ខ្ញុំចង់សួរលោកពូអាចបញ្ជាក់ជូនអង្គសវនាការម្ដង

ទៀតថា នៅពេលដែលខ្មែរក្រហមបានរំដោះតំបន់ដែលលោកពូរស់នៅហ្នឹង ថាតើពេលហ្នឹងលោកពូមានអាយុប្រហែលជាប៉ុន្មានដែរ?

**ឆ៖** មិនអាចចាំបានខ្ញុំ ប៉ុន្តែអាចដឹងថា ខ្លួនឯងប្រហែលជាជាង១០ឆ្នាំ តែប៉ុណ្ណឹង។

**ស៖** ចាស អរគុណលោកពូ។ មុននឹងខ្ញុំចូលដល់សំណួរទាក់ទងជាមួយនឹងរឿងហេតុដែលកើតឡើងចំពោះលោកពូនៅក្នុងរបបខ្មែរក្រហម ខ្ញុំចង់សួរមួយទៀតទាក់ទងជាមួយនឹងការស្តាប់ចម្លើយរបស់លោកពូ ដោយអង្គ -- ដោយសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ នៅក្នុងឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់លោកពូ នៅ -- ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ នៅក្នុងឯកសារលេខ E3/5129 លោកពូបានអះអាងថា លោកពូ -- "ខ្ញុំមិនអាចផ្តល់ចម្លើយចំពោះរឿងរ៉ាវដែលពាក់ព័ន្ធនឹងមន្ទីរក្រាំងតាចាន់បានទេពេលនេះ ដោយសារបញ្ហាសន្តិសុខ"។ តែនៅក្នុងកំណត់ស្តាប់ចម្លើយមួយទៀតដែលសហចៅក្រមស៊ើបអង្កេតបានសួរលោកពូ ចុះនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ គឺឯកសារលេខ E3/5214 លោកពូបែរជាបានឆ្លើយនូវសំណួររបស់សហចៅក្រមស៊ើបអង្កេតវិញ។ អ៊ីចឹងខ្ញុំចង់សួរលោកពូថា ហេតុអ្វីបានជានៅក្នុងឆ្នាំ២០០៨ហ្នឹង លោកពូអាចឆ្លើយនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេតបាន? តើលោកពូនៅមានការភ័យខ្លាចទៀតដែរឬទេ?

[១១:១៣:០៥]

**ឆ៖** អាចដែរអាខ្ញុំមិនហ៊ានឆ្លើយ ពីមុនខ្ញុំអត់ហ៊ានឆ្លើយ ដោយសារខ្ញុំយល់ទៅតាមថា ខ្លាចលោរបបហ្នឹងវាវិលវែង វិលមកក្រោយវិញ បានជាខ្ញុំអត់ហ៊ានឆ្លើយ។ កាលណាវិលមកក្រោយ គឺខ្ញុំបាត់បង់អាយុជីវិតមុនគេ។ បើអ៊ីចឹង ដល់ចុងបញ្ចប់និងក្រោយមកបានខ្ញុំដេកគិត និងពិចារណាថា មិនអាចរបបហ្នឹងវិលមកក្រោយបានៗខ្ញុំហ៊ានឆ្លើយបាទ។

**ស៖** ចាស សូមអរគុណលោកពូ។ អម្បាញ់មិញទាក់ទងជាមួយនឹងការភ័យខ្លាច អ៊ីចឹងខ្ញុំចង់ខ្ញុំៗចង់សួរលោកពូថា ចប់របបខ្មែរក្រហមហើយ លោកពូនៅភ័យខ្លាចនៅក្នុងពេលដែលគេទៅសួរលោកពូលើកទី១ហ្នឹង។ អ៊ីចឹង ខ្ញុំចង់សួរលោកពូថា នៅក្នុងរបបខ្មែរក្រហមហ្នឹង តើលោកពូធ្លាប់ទទួលរងនូវការប៉ះទង្គិចនូវការរំលោភរបៀបណាដែរ លោកពូអាចរៀបរាប់ឡើងវិញបន្តិចជូនអង្គសវនាការនៅពេលនេះបានទេ? ហើយវាប៉ះពាល់យ៉ាងម៉េចដល់លោកពូ?

**អ្នកបកប្រែ៖**

លោកប្រធាន សូមការអនុញ្ញាតពីបកប្រែខាងប៊ូតអង់គ្លេសថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្ប-

វេណីនិយាយញ្ជាប់ពេកបកអត់ទាន់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មេធាវី -- ស្តាប់ឮហើយសូមបន្ថយល្បឿនក្នុងការនិយាយឲ្យបានយឺតៗ ដើម្បីស្តាប់បានទាំងអស់គ្នាផង ហើយដើម្បីវាប្រយោជន៍ក្នុងការបកប្រែភាសាទៅជាភាសាអង់គ្លេស និងភាសាបារាំងបានត្រឹមត្រូវល្អផង។

[១១:១៤:៣៣]

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** លោកពូចាប់សំណួរខ្ញុំបានទេ ឬក៏ចង់ឲ្យខ្ញុំសួរម្តងទៀត?

**លោក សយ សែន៖**

**ឆ៖** គាត់សួរម្តងទៀត។

**ស៖** លោកពូបានលើកឡើងពីការភ័យខ្លាច អ៊ីចឹងខ្ញុំចង់សួរលោកពូថា នៅក្នុងរបបខ្មែរក្រហមហ្នឹង តើលោកពូធ្លាប់ទទួលរងនូវការវាយប្រហារណាមួយ នូវការវាយដំ ការប៉ះពាល់ណាមួយដែលធ្វើឲ្យលោកពូភ័យខ្លាចអ៊ីចឹងដែរទេ? ឬក៏មានហេតុការណ៍ណាមួយដែលធ្វើឲ្យលោកពូមានរបួសស្នាមអ៊ីចឹង តើមានហេតុការណ៍អ៊ីចឹងដែរទេ?

**ឆ៖** បាទអាចមាន ព្រោះខ្ញុំមិនប៊ានឆ្លើយពីដំបូងដែមកវា កាលអ្នកដែលនៅមន្ទីរគុកក្រាំងតាចាន់ហ្នឹងអាចជាកងទ័ពគាត់នៅប៉ុន្មានប្រាំប្រាំមួយនាក់នៅតែទៅទៀត ម៉្លោះហើយខ្ញុំមិនអាចប៊ានឆ្លើយដោយសារខ្ញុំ មុខរបរខ្ញុំជាកសិករដើររកស៊ីយប់ព្រលប់អីខ្លាចគេគុំកួនជាមួយខ្ញុំ។ ហើយម៉្យាងគេអ្នកធ្វើទុក្ខធ្វើទោសខ្ញុំហ្នឹង ក៏នៅដែររាល់ថ្ងៃហ្នឹង គឺគាត់បានវ៉ៃខ្ញុំបែកក្បាលពីក្រោយអត់ទាន់បាត់ ទុកស្នាមរាល់ថ្ងៃគាត់វាយស្នូកកាំភ្លើងការ៉ាង គាត់ថាខ្ញុំលួចដំឡូងមី។ ប៉ុន្តែដំឡូងមីហ្នឹង ខ្ញុំអត់លួចទេ ដំឡូងមីហ្នឹងវាខែវស្សាវាដួល ដល់ដួលទៅ ដល់ដួលខ្ញុំសែងលាមកចេញទៅ ខ្ញុំក៏កាច់ដំឡូងមីហ្នឹងមក គាត់ថាខ្ញុំលួចដំឡូងមី គាត់វ៉ៃ យកកាំភ្លើងវ៉ៃបែក បាក់ស្នូកកាំភ្លើងការ៉ាងមួយដើម។

[១១:១៦:០៨]

**ស៖** ចាស សូមអរគុណលោកពូ។ អ៊ីចឹង អម្បាញ់ហ្នឹងគឺលោកពូបានលើកឡើងថាគេបានចាប់

នៅក្នុងទាក់ទងជាមួយនឹងគុកក្រាំងតាចាន់។ អ៊ីចឹង ខ្ញុំចង់សួរលោកពូបញ្ជាក់ថា តើលោកពូចាំបានទេប្រហែលជានៅក្នុងពេលណាដែរ ដែលគេចាប់លោកពូទៅដាក់នៅក្នុងគុកក្រាំងតាចាន់ហ្នឹង?

**ឆ៖** អាច ខ្ញុំដឹងឆ្នាំ ប៉ុន្តែមិនអាចចាំខែទេ ប៉ុន្តែឆ្នាំគឺឆ្នាំ៧៤ បាទ។

**ស៖** ចាស សូមអរគុណលោកពូ។ តើលោកពូអាចរៀបរាប់ជូនអង្គសវនាការបន្តិចបានទេពីហេតុការណ៍នៃការចាប់ខ្លួនលោកពូនៅពេលហ្នឹង? តើអ្នកណាខ្លះចាប់លោកពូ? គេចាប់របៀបម៉េច? ហើយតើមូលហេតុអ្វីបានជាគេចាប់លោកពូ?

**ឆ៖** ពីមុនដំបូងបង្អស់មានឈ្លប ឈ្លបក៏នាំខ្ញុំមកថា បញ្ជូនទៅអង្គរកា ទៅកងយុវជននៅអង្គរកា។ ទៅដល់យុវជននៅអង្គរកា ក៏ខ្លះក៏ យាយគាត់ថា៖ "អ្ហឺ! វានៅតូចដែរ មិនទាន់ចូលយុវជនកើតទេ" ថា៖ "អត់អីទេប៉ុណ្ណឹង ល្មមពេញយុវជនហើយយាយ មិនអីទេ"។ ក៏គាត់ឈ្លបពីរនាក់ហ្នឹងទៅចាប់ខ្ញុំយកដាក់អង្គរកាកន្លែង តាឃននៅអង្គកាហ្នឹង ដល់ជូនទៅដល់កន្លែងតាឃន នៅអង្គរកា។ តាឃនហ្នឹងបញ្ជូនខ្ញុំមកត្រពាំងព្រីងកន្លែងតាកិល១ ត្រពាំងព្រីងខាងលិចក្រាំងតាចាន់ហ្នឹង។ ទៅដល់លិច ដល់កន្លែងផ្ទះតាកិលហ្នឹង តាកិលក៏បញ្ជូនខ្ញុំទៅគុកក្រាំងតាចាន់ហ្នឹងទៅ។ ហើយដល់ចូលជូនទៅដល់គុកហ្នឹង គេជាប់គុកហ្នឹងប្រហែលជាអាច ខ្ញុំមិនអាចចាំបាន ខ្ទង់ប្រហែលជាកន្លះខែ ឬក៏ ១០ថ្ងៃក៏មិនដឹងអត់ដែលសួរចម្លើយទេ ស្រាប់តែដាក់ខ្នោះរហូតទាំងយប់ទាំងថ្ងៃ។ រហូតបានប្រហែលជា១០ថ្ងៃមិនដឹងកន្លះខែក៏មិនដឹង ហៅខ្ញុំមកសួរចម្លើយថា វាមានពាក់ព័ន្ធ ថាខ្ញុំនេះពាក់ព័ន្ធជាមួយចោរ ព្រំ សាន់។ ចោរព្រំ សាន់ ក្នុងព្រៃ ខ្ញុំអត់ដែលស្គាល់ផង មិនដឹង ព្រំ សាន់ អីខ្ញុំអត់ដែលស្គាល់។ តែប៉ុណ្ណឹងទេ បាទ។

[១១:១៨:២៥]

**ស៖** នៅពេលដែលគេចាប់លោកពូឃុំនៅក្នុងគុកក្រាំងតាចាន់ហ្នឹង តើគេឃុំលោកពូរហូត ឬក៏យ៉ាងម៉េចដែរ? ឬក៏គេឲ្យលោកពូធ្វើអីគេខ្លះ?

**ឆ៖** ពីដំបូងឃុំខ្ញុំរហូត ឃុំរហូតប្រហែលជាអាចរយៈកាលខ្ទង់មួយខែឬក៏មួយខែជាង បានលែងខ្ញុំមកឲ្យមកក្រៅមកធ្វើការ មកស្ទូងដកខាងក្រៅហ្នឹង មកធ្វើថាដូចថាស្ទូង បោចស្នៅ សែងលាមក១ដែលនៅក្នុងគុកហ្នឹង កាលណាគេបត់ជើងហើយ គេត្រូវដាក់នៅក្នុងកាដុងក្នុងលាមកហ្នឹង។ នេះខ្ញុំអ្នកសែងចេញពីរនាក់ខ្មោច តាចិន សែងយកចេញដាក់ចាក់វាលស្រែអស់ហើយអ៊ីចឹងទៅ។ ដល់យូរ១ទៅ នៅបានយូរ១ គេរាងដូចថាទុកខ្ញុំ ខ្ញុំរាងនៅក្មេងជាងគេផង រាងទុកចិត្ត គេក៏លែងឲ្យរាងដូចថាមានសេរីភាពមើលគោមើលក្របីអីបានខ្លះអ៊ីចឹងទៅ។

**ស៖** លោកពូអាចជម្រាបជូនអង្គសវនាការបានទេថា លោកពូដឹងទេថា ហេតុអ្វីបានជាគេលែងលោកពូឲ្យទៅធ្វើការនៅក្នុងគុកហ្នឹង?

**ឆ៖** គាត់លែងឲ្យខ្ញុំចេញធ្វើការខាងក្រៅ គាត់នឹកឃើញថាខ្ញុំវានៅក្មេងជាងគេ ហើយម៉្យាងគាត់ពន្យល់ប្រាប់ខ្ញុំថា៖ "អ្អែងនៅមាត់ឲ្យស្ងៀមៗ អ្អែងគេទុកឲ្យរស់ហើយ បើអ្អែងមាត់អត់ស្ងៀមទេ នៅឲ្យស្ងៀមអ្អែង អត់មានមាត់រអេចរអូច មាត់ដាចទៅនេះទៅនោះទេ អត់ទេ! អ្អែងមាត់ឲ្យស្ងៀម អញទុកឲ្យរស់"។ បើអ៊ីចឹងគាត់លែងឲ្យខ្ញុំធ្វើការ នៅក្នុងហ្នឹងមានតែមើលក្របី ហើយមើលក្របីមកសម្រាប់ទៅកាប់រណ្ដៅសម្រាប់កប់សពហ្នឹង ហើយនិងខ្មោចស្លាប់នៅក្នុងគុក។ ហ្នឹងគេវ៉ៃស្លរចម្លើយហ្នឹង បង្អត់បាយដាក់ក្នុងគុកហ្នឹង គឺកាលណាស្លាប់ហើយ ហូតខ្នោះចេញ ដល់ហូតខ្នោះចេញហើយ ខ្ញុំយកសែងយកទៅដាក់កប់តាមៗជួររបង កប់ហើយដាក់ដាំដូងពីលើ ដាំដូងពីលើជាមួយ តាចិន ពីរនាក់ តាចិន ហ្នឹង។ វារឿងវាវែងអន្លាយដែរ ប៉ុន្តែខ្ញុំវាអាចភ្លេចខ្លះហើយ វាច្រើនយូរឆ្នាំហើយ ៤១ឆ្នាំអាចភ្លេចខ្លះហើយ។

[១១:២០:៤១]

**ស៖** ចាស អរគុណលោកពូ។ ខ្ញុំចង់សួរលោកពូបញ្ជាក់ថា នៅគុកហ្នឹង សម័យហ្នឹងអត់មានបុគ្គលិកធ្វើការ ឬក៏ម៉េចបានគេប្រើអ្នកទោសឲ្យទៅធ្វើការអ៊ីចឹងលោកពូ? លោកពូដឹងពីមូលហេតុហ្នឹងទេ?

**ឆ៖** អាចដឹង ព្រោះគ្នាវាកាលណា កងទ័ពវាមានទាំងអស់វាតែពីរដណ្ដប់នាក់ទេ។ ពីរដណ្ដប់នាក់ ខាងផ្នែកកងទ័ពជំនាន់ហ្នឹងគេអត់ហៅបុគ្គលិកទេ ហៅកងទ័ព។ អ៊ីចឹង ប្រធានៗនោះមាន ប្រធានមួយ អនុប្រធានមួយ សមាជិកមួយ ទាំងអស់មានបី។ បើអ៊ីចឹងគ្នាវា អាកងទ័ពនោះ ពួកគាត់នោះពីរដណ្ដប់នាក់ទៀត វាឡើងប្រាំដណ្ដប់។ បើអ៊ីចឹងត្រូវគាត់ហ្នឹងវាការងារអត់ហត់នឿយសម្រាក នៅកន្លែងអ្នករកដែលទុកចិត្ត ដូចថាខ្ញុំហើយខ្មោចតាចិន ហ្នឹងទុកចិត្តជាងគេ។ បើអ៊ីចឹង ប្រើឲ្យទៅកាប់រណ្ដៅកាប់អីហ្នឹងតែប៉ុណ្ណឹង កាប់រណ្ដៅ។ ដល់ពេលគេសម្លាប់ អាហ្នឹងកងទ័ពគេអ្នកសម្លាប់ផ្សេង ហើយយើងគ្រាន់តែដឹងថា គ្រាន់តែទៅកាប់គ្រលុក ទៅលុបអីអ៊ីចឹងទៅ ស្អុយអីទៅលុបដីលុបអីអ៊ីចឹងគេប្រើខ្ញុំបាទ។ ហើយខ្ញុំដោយសារខ្ញុំ គាត់សួរ ប្រធានមន្ទីរគាត់សួរខ្ញុំថា "អ្អែងចេះធ្វើត្នោត?" ខ្ញុំថា "ខ្ញុំចេះ" ចេះៗខ្ញុំចេះតែសួរគេ ខ្ញុំលួចសួរគេថា ត្នោតគេកៀបប៉ុន្មានថ្ងៃៗ លួចសួរគេ គេប្រាប់។ អ៊ីចឹងខ្ញុំទៅធ្វើត្នោតហើយ បានទឹក បានទឹកហើយគាត់ឲ្យខ្ញុំត្រាំជូរឲ្យគាត់។ ត្រាំជូរឲ្យគាត់ គាត់ចេះតែប្រើខ្ញុំ

នៅក្រៅ នៅវាលអីអ៊ីចឹងទៅ គ្រាន់សម្រាប់ដាក់ទឹកត្នោតជូរឲ្យគាត់អ៊ីចឹង។

**ស៖** ចាស អរគុណលោកពូ។ ការងារដែលគេប្រើឲ្យលោកពូធ្វើទាំងប៉ុន្មានហ្នឹង លោកពូប្រកែកមិនធ្វើបានទេ?

**ឆ៖** អត់ប្រកែកបានទេ បន់ឲ្យគេប្រើបាទ ខ្ញុំបន់ឲ្យតែប្រើខ្ញុំមក បាននៅក្រៅ ខ្ញុំអរលើកដៃឡើងលើ ឲ្យបានថាខ្ញុំបានរស់រានមានជីវិត បានឃើញមុខម៉ែឪខ្ញុំតទៅទៀត។ ហើយបើគេដាក់គុកហ្នឹង គឺខ្ញុំមានតែថ្ងៃស្លាប់ បើថាឲ្យនៅក្រៅ ខ្ញុំធ្វើអីក៏ធ្វើដែរ អត់ចេះ ក៏ខ្ញុំដើរសួរគេដែរ។

[១១:២២:៤៨]

**ស៖** ចាស សូមអរគុណលោកពូ។ លោកពូថាគេបានដោះលែងលោកពូឲ្យធ្វើការនៅពេលថ្ងៃ។ អ៊ីចឹងតើនៅពេលយប់ហ្នឹង លោកពូសម្រាកនៅកន្លែងណាដែរ?

**ឆ៖** ពេលថ្ងៃ គឺខ្ញុំគេដោះលែងនៅក្រៅ មើលក្របីមើលគោ។ ពេលម៉ោងបួនល្ងាចៗ គេបញ្ចូលអ្នកដែលធ្វើការខាងក្រៅហ្នឹងជាង១០នាក់ ពីរដណ្ដប់នាក់ បីដណ្ដប់នាក់ គឺអ្នកធ្វើការខាងក្រៅ ដែលធ្វើស្នូងដក ដាំដំណាំកសិកម្មអីផ្សេងៗអ៊ីចឹងទៅ ដូចខ្ញុំខាងគោក្របីហ្នឹង គឺហើយខាងពីរនាក់ តាចិន ហ្នឹង ខ្ញុំនៅជាប់ខាងគេ នៅជាប់គុកដូចគ្នា យប់ឡើងចូលដូចគ្នា ប៉ុន្តែចូលដាក់ខ្លួនឯង ចូល ប៉ុន្តែខ្ញុំជាប់កៀនជញ្ជាំងខាង។ កាលណាមានអ្នកខ្មោចស្លាប់អី ខ្មោចដោយស្លាប់ដែលគេវ៉ៃបង្អត់បាយ បង្អត់ទឹកអីនៅតាមគុកទាំងអស់វាមានបួន កាលណាស្លាប់គុកណា គឺខ្ញុំទៅយកខ្មោចសពហ្នឹងយកទៅទុកហើយ បានអាចមកដាក់ខ្លួនឯងចុងក្រោយ។

**ស៖** ចាស សូមអរគុណលោកពូ។ អ៊ីចឹង ទាក់ទងនឹងរបបអាហារដែលលោកពូត្រូវទទួល តើរបបអាហាររបស់លោកពូដែលជាអ្នកទោសគេលែងឲ្យធ្វើការនៅពេលថ្ងៃហ្នឹង ហើយនិងអ្នកទោសដទៃទៀតដែលគេអត់លែងហ្នឹង តើរបបអាហារយ៉ាងម៉េចដែរ?

[១១:២៤:២៦]

**ឆ៖** បាទ ជាគិតជារបបម្ហូបអាហារវិញ គឺនិយាយមិនកើត វាដូចថានិយាយមិនកើត។ បើទាំងអស់ហ្នឹង គុកទាំងអស់វាមានបួន បួនគុកវាអត់ចិតថេរទេ មានគុកខ្លះ៥០ គុកខ្លះ១០០ គុកខ្លះ៧០ ២០ អ៊ីចឹង អង្ករក្នុងមួយខ្ទះគេឲ្យតែបួនកំប៉ុងទេ។ ប៉ុន្តែពេលឆ្អិនអ៊ីចឹង ខ្ញុំអ្នកលើកយកឲ្យអ្នកទោសខាងក្នុងហ្នឹង ក្នុងមួយនាក់មួយត្រឡោក ប៉ុន្តែត្រឡោកៗហ្នឹងមិនមែនត្រឡោកធ្វើរលីងទេ ត្រឡោកយើងធម្មតាហ្នឹង ត្រឡោកហើយ -- ម្នាក់ៗមួយត្រឡោកៗ ហើយវែកក៏វែកត្រឡោកដែរ ដួសយកដាក់ជូន ដាក់គ្រប់

អ្នកទោស។ ហើយអ៊ីចឹងបានខ្ញុំចេញក្រៅមក ជូនទៅដាក់គុកមួយទៀត។ ចេញគុកមួយទៀត ដាក់ដូចគ្នាអ៊ីចឹង ប៉ុន្តែក្រែងខ្ញុំហ្នឹងនិយាយថា ដូចថាក្បត់បន្តិចចុះ ព្រោះពួកនៅក្រៅហ្នឹងបានសល់អាកាកខាងក្រោមៗហ្នឹង រស់រានមានជីវិតទល់រាល់ថ្ងៃ ដោយសារបានកាកនៅក្រោមៗអាឆ្នាំងខ្ទះនៅក្រោមកាកបានកាក។ ហើយបើអ្នកគ្នាជាប់នៅក្នុងគុកហ្នឹងបានច្រើនតែទឹក បាទនិយាយឲ្យត្រង់ភ្លឹងទៅចុះ។

**ស៖** សូមអរគុណលោកពូ។ អ៊ីចឹងខ្ញុំចង់សួរលោកពូបន្តទៀតថា តើលោកពូរស់នៅក្នុងស្ថាន-ភាពបែបនេះ មានន័យថាពេលថ្ងៃគេលែងឲ្យធ្វើការ ពេលយប់គេយកមកឃុំឃាំងក្នុងគុកៗវិញ រហូតដល់ចប់របបខ្មែរក្រហមតែម្តង ឬក៏វាមានអីប្រែប្រួលនៅចន្លោះហ្នឹង?

**ឆ៖** បាទ ទាល់តែចប់ ទាល់តែចប់តែម្តង ប៉ុន្តែសម្រាប់គេ យើងដែលថា ទោសៗស្រាលដូចថាទោសស្រាលទៅចុះ គេថាឲ្យៗយើងរស់រានមានជីវិតហើយ ដូចគេថាដូចរាងស្រាលជាងគេ។ គេថាថ្ងៃល្ងាចជិតយប់អី បានគេបញ្ចូលខ្ញុំ បញ្ចូលនុ៎ង ប៉ុន្តែបញ្ចូលហ្នឹងដាក់ខ្នោះខ្លួនឯង។ ខ្នោះខ្លួនឯង ហូតដែករនុកក្រោមហ្នឹង ហូតដាក់ខ្លួនឯង ប៉ុន្តែគេចាក់សោខាងក្រៅ បាទអាហ្នឹងចូលក្រោយគេ។ ប៉ុន្តែនៅប្រមែប្រមូលដូចថា មានសពមានអីស្លាប់តាមគុកប្អូនហ្នឹងទាំងអស់ហ្នឹង យកសពអីទុកដាក់ហើយអស់បានមកចូលខ្លួន ដាក់ខ្លួនឯងបាទ។

[១១:២៦:៤៨]

**ស៖** អម្បាញ់មិញលោកពូបានរៀបរាប់ទាក់ទងជាមួយនឹង -- ខ្លះៗទាក់ទងជាមួយនឹងស្ថានភាពអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងហ្នឹង។ អ៊ីចឹងសំណួរដែលខ្ញុំចង់សួរលោកពូនេះ គឺខ្ញុំចង់សួរទាក់ទងស្ថានភាពនៃការឃុំខ្លួនអ្នកទោសដែលនៅក្នុងមន្ទីរឃុំឃាំងទាំងយប់ ទាំងថ្ងៃ ដែលមិនត្រូវបានគេដោះលែងហើយចាប់ពីថ្ងៃដែលសម័យខ្មែរក្រហមបានទទួលជោគជ័យ គឺចាប់ពីខែមេសា ឆ្នាំ១៩៧៥ ទៅ។ អ៊ីចឹងខ្ញុំសូមឲ្យលោកពូបានជួយរៀបរាប់ពីស្ថានភាពអ្នកទោសដែលត្រូវបានគេឃុំនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗហ្នឹង ថាតើស្ថានភាពអ្នកទោសហ្នឹងយ៉ាងម៉េចដែរ ដែលលោកពូមើលឃើញផ្ទាល់ភ្នែក? សូមលោកពូអាចរៀបរាប់ជូនសវនាការនៅពេលនេះ។

**ឆ៖** វាបើនិយាយពីអ្នកទោសនៅក្នុងហ្នឹងវិញ គួរណានិយាយមិនចេញ ហើយក៏និយាយមិនរួចដែរពីបញ្ញារបស់ខ្ញុំ និយាយមិនចេញ។ បានន័យថា វាហួសនិស្ស័យ ហួសអាល័យមិនដែលជួប ហើយក៏មិនដែលឃើញ តាំងខ្ញុំចេះកើតមកមិនដែលឃើញទេ អត់ដែលឃើញ។ វេទនាហួសខ្លាំងណាស់ និយាយពីសម្រាន្តវិញ វាសង្អើចហើយចៃមិនដឹងយកទៅណាអស់ទេ ចៃសាច់យើងហ្នឹង។ គ្រាន់តែអ្នកចៃ ហើយ

សង្កើចខាំស្លាប់ក្នុងមួយយប់ អត់បាត់ពីគុកមួយ បាត់ពីបួននាក់និងបីនាក់ទេក្នុងមួយយប់ ចៃហើយសង្កើចខាំ។ ហ្នឹងចៃហើយសង្កើចខាំ និងពីបញ្ហាអត់អាហារផង។ វាវែងអន្លាយ និយាយទៅវាច្រើនណាស់ ប៉ុន្តែវាខ្ញុំភ្លេចខ្លះ នៅចាំខ្លះអីខ្លះ វាយូរឆ្នាំដែរហើយ។

[១១:២៨:២៥]

**ស៖** អម្បាញ់មិញលោកពូបានមានប្រសាសន៍ទាក់ទងជាមួយនឹងរបបអាហាររបស់អ្នកទោស លោកពូបានមានប្រសាសន៍ថា អ្នកទោសគេមានត្រឡោកមួយដើម្បីដាក់អាហារហ្នឹង។ អ៊ីចឹងតើ -- មួយទៀតទាក់ទងជាមួយនឹងការបន្ទោបង់វិញ ថាតើគេបន្ទោបង់របៀបម៉េច?

**ឆ៖** បាទ ការបត់ជើង និយាយពីបញ្ហាបត់ជើងវិញ ខ្ញុំអត់ចង់និយាយ ម៉េចថាអត់ចង់និយាយបត់ជើង ជើងជាប់ទាំងពីរផ្អៀងខ្លួនអ៊ីចឹង ផ្អៀងហើយយកអាត្រឡោកហូបបាយហ្នឹងដាក់ពីក្រោមទៅដាក់ពីក្រោមហើយបន្តគ្នាមក។ បត់ជើងហ្នឹងហើយ បន្តគ្នាជាប់ៗគុក តគ្នាចេះតែតគ្នាអ៊ីចឹងទៅ តចាក់នៅប៊ីដុងនៅកណ្ដាល ដាក់ប៊ីដុងនៅសសរកណ្ដាល។ ប៊ីដុង៣០លីត្រ កាត់មាត់ហើយ ដាក់នៅកណ្ដាលហើយ បន្តអាត្រឡោកបត់ជើងហ្នឹងហើយ។ ហើយដល់ពេលបត់ជើងហើយ ដល់ចាក់ហើយ យកត្រឡោកមកក្រលែងទឹកហ្នឹង ក្រលែងទឹកត្រឡោកហ្នឹង ហើយយកចាក់ចោលនៅនឹងមុខហើយ ដងទឹកយកមកហូប អាទឹកហ្នឹងដដែល ត្រឡោកហ្នឹងដដែល បានថាខ្ញុំអត់ចង់និយាយទេ តែនិយាយវាវែងអន្លាយជ្រៅពេក។ បាទអត់ចង់និយាយរឿង ខ្ញុំអត់រំឮកឃើញទេ តែរំឮកឃើញ ខ្ញុំនិយាយអត់រួចទេ អត់ចង់រំឮកសោះ បាទ។

[១១:២៩:៣៥]

**ស៖** លោកពូនិយាយទាក់ទងជាមួយនឹងត្រឡោកដែលគេដាក់លាមក ហើយនិងត្រឡោកដែលគេដាក់អាហារ ហើយនិងដាក់ទឹក។ ខ្ញុំចង់សួរលោកពូបញ្ជាក់ថា តើត្រឡោកតែមួយគេប្រើសម្រាប់ដាក់អាហារផង ដាក់ទឹកញ៉ាំផង ហើយដាក់ម្ហូបអាហារផង ឬក៏គេឲ្យត្រឡោកផ្សេងៗគ្នា សម្រាប់អ្នកទោសម្នាក់?

**ឆ៖** បាទ ត្រឡោកតែមួយហ្នឹង អត់មានត្រឡោកច្រើនទេ។ កាលណាត្រឡោកហ្នឹងបត់ជើងបត់ដៃហើយ ត្រូវខ្ញុំហ្នឹងប្រមូលត្រឡោកៗយកចេញទៅក្រៅទាំងអស់ អត់មានទុកត្រឡោកក្នុងហ្នឹងទេ។ កាលណាទុកត្រឡោកក្នុងហ្នឹង គេថាយើងគាស់ខ្នោះ គាស់ខ្នោះដៃ ខ្នោះជើងហ្នឹង ចេញរួចអីយប់ព្រលប់អីហ្នឹង មានគាស់ក្រោកក្រាកអី គេចូលមកវ៉ៃស្លាប់នៅកន្លែងក្នុងគុកហ្នឹង អត់ទាន់ដោះខ្នោះចេញ វ៉ៃឲ្យ

តែមានឮសូរខ្ទោះក្រេកក្រោកៗហ្នឹង ចូលមកវ៉ៃទាំងយប់ហ្នឹង អត់ទុក។ ថ្មើរម៉ាន -- ព្រោះកងទ័ពវាយាម ដូរវេនគ្នាយាម មួយម៉ោងពីរនាក់ៗ។ អ្នកណាខ្ទោះណាវើ ចូលមកចាប់អាដង្កាប់មួយចាប់ញើង ខ្ទោះ ក្រោកក្រោកៗ តែមានរបូតខ្ទោះ វ៉ៃស្លាប់យប់ហ្នឹងអត់មានយកទៅណាទេ វ៉ៃមុខៗអ្នកទោសទាំងអស់គ្នាក្នុងគុកទាំងអស់ហ្នឹង វ៉ៃឲ្យមើល បាទ។

**ស៖** សូមអរគុណលោកពូ។ ខ្ញុំចង់សួរលោកពូថា តើនៅក្នុងហ្នឹង គេដាក់អ្នកទោសប្រុស អ្នកទោសស្រីដាច់ដោយឡែក ឬក៏លាយឡំជាមួយគ្នាដែរ?

**ឆ៖** កាលពីសម័យសង្គ្រាម នៅសង្គ្រាមអត់ទាន់បែកភ្នំពេញ បែកអីហ្នឹង គឺដាក់មួយជួរ ក្នុងមួយគុកហ្នឹងវាមានពីរជួរ ទុកតែផ្លូវកណ្ដាលសម្រាប់ដើរមើល។ អ៊ីចឹង គេដាក់ស្ត្រីហ្នឹងមួយជួរខាងជើងហ្នឹង បុរសជួរខាងត្បូងអ៊ីចឹងទៅ។ ហើយដល់បែកឆ្នាំ៧៥ហ្នឹង ដាក់ទូទៅហើយ លែងគិតជួរគិតអីហើយ ទូទៅទាំងអស់ៗ។

**ស៖** អ៊ីចឹងបានន័យថាលោកពូ នៅក្នុងបន្ទប់ឃុំឃាំងរបស់លោកពូហ្នឹង គឺលោកពូមើលឃើញមានអ្នកទោសស្រីនៅក្នុងហ្នឹងដែរ។ អ៊ីចឹងលោកពូអាចរៀបរាប់ជូនសវនាការបានទេថាតើ ដោយសារគាត់ជាស្ត្រី អ៊ីចឹងក្នុងការដែលគាត់ជាប់ឃុំនៅក្នុងបន្ទប់ហ្នឹងលាយឡំជាមួយនឹងមនុស្សប្រុស តើលោកពូសង្កេតឃើញថាគាត់មានការលំបាករបៀបណាខ្លះ?

[១១:៣២:១៦]

**ឆ៖** គាត់ជាស្ត្រីនៅក្នុងជាប់គុកជាមួយគ្នាហ្នឹង គាត់ពិបាកនោះ ពិបាកពេកហើយ ប៉ុន្តែខ្ញុំកាលហ្នឹងវានៅវ័យក្មេង។ ប៉ុន្តែម៉្យាងគេលែងគិតថាពិបាកហើយ គាត់ទោះបីរូបគាត់ក៏ដោយ រូបខ្ញុំក៏ដោយ បត់ជើងតូច បត់ជើងធំ ចង់ម៉េចក៏អត់កើតទុក្ខដែរ ឲ្យតែបានកើត -- ឲ្យតែបានរស់រានមានជីវិត ចង់របៀបម៉េចក៏ដោយ។ ប៉ុន្តែវាលែងប្រកាន់ឋានៈអីគឺអត់មានទេ អត់មានប្រកាន់ឋានៈទេ ព្រោះអ្នកជាប់គុកទាំងអស់គឺអត់មានអ្នកណាមួយអាច គឺឡូឡើងចេញពីនេះទៅថា៦០ ទៅដល់នោះឡើង៦៥ អត់មានទេ មានតែ៣០ និង៤០ទេ គឺឡូបាទ។

**ស៖** ចាស សូមអរគុណលោកពូ។ ដោយសារមុនហ្នឹងលោកពូបានបញ្ជាក់ថា លោកពូត្រូវបានចាប់ខ្លួនចូលនៅក្នុងគុកក្រាំងតាចាន់ហ្នឹងតាំងពីឆ្នាំ៧៤ រហូតទៅដល់ពេលដែលវៀតណាមវ៉ៃបែកទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៩។ អ៊ីចឹង ខ្ញុំចង់សួរលោកពូទាក់ទងជាមួយនឹងហេតុការណ៍ដែលលោកពូឃើញនៅក្នុងគុក ទាក់ទងជាមួយនឹងចំនួនមនុស្សដែលគេចាប់មកចូលនៅក្នុងគុកហ្នឹង។ អ៊ីចឹងតើលោកពូអាច

ដឹងទេថា ក្នុង១ថ្ងៃអីអ៊ីចឹង តើមានអ្នកទោសមក គេចាប់មកប្រហែលជាប៉ុន្មានអ្នកដែរ? ថាតើចំនួនហ្នឹង វាជាចំនួនដែលថេរ ឬក៏វាប្រែប្រួលពីមួយពេលទៅមួយពេល?

**ឆ៖** ខ្ញុំមិនអាចចាំបានទេហ្នឹង ប៉ុន្តែឃើញមនុស្សច្រើនជាងគេ ខ្ញុំដឹងថាបែក ប៉ុន្តែខ្ញុំមិនដឹងជាឆ្នាំប៉ុន្មានៗ ក៏ខ្ញុំអត់ដឹងបានដឹងដែរ។ បានដឹងថា គេថា "ហ៎ុក! បែកជ័យជម្នះ" អាហ្នឹងកាលឆ្នាំហ្នឹងច្រើនមែន។ មាន១ថ្ងៃមាន១០០ មាន៧០ មាន៨០ តាមចិតថេររបស់វាណ៎ា ហើយបើពីសម័យសង្គ្រាមឃើញតែគេនាំចូលតែយប់ទេ។ យប់មានបួនមានប្រាំៗ មានបីមានពីរ សម័យសង្គ្រាម។ ហើយដល់ពេលគេថាបែកហើយ ខ្ញុំក៏មិនដឹងបែកឆ្នាំប៉ុន្មានៗ ក៏អត់ដឹងដែរ ដឹងតែថា ដឹងឃើញតែមនុស្សច្រើន គេថា គេបែកភ្នំពេញហើយ ជ័យជម្នះ។ ដល់ថាអ៊ីចឹង ឃើញគេនាំទៅម្ដង មាន៥០, ៦០, មាន៣០, មាន២០ មានប្រាំអត់ទៀងៗទេ ហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទអរគុណណាស់លោកស្រីមេធាវី។ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ រួមទាំងបុគ្គលិករបស់អង្គការ ធី.ភី.អូ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាឲ្យបានមុនម៉ោងមួយសាមសិបនាទីរសៀលនេះ។

ហើយបង្គាប់ឲ្យមន្ត្រីអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៣៨]

**ប្រធានអង្គជំនុំៈ**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងមុនផ្តល់វេទិកាជូនទៅក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទទួលសិទ្ធិៗក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី ខៀវ សំផន ក្នុងការទទួលបានឯកសារដែលព្រះរាជអាជ្ញាបានដាក់នៅក្នុងអ៊ីនធីហ្វេស។

តទៅនេះអង្គជំនុំជម្រះសម្រេចអំពីសំណើរបស់មេធាវីការពារក្តី ខៀវ សំផន កាលពីព្រឹកមិញនេះទាក់ទងនឹងការបានទទួលបានឯកសារមួយចំនួន ដែលខាងសហព្រះរាជអាជ្ញាបានដាក់ចូលទៅក្នុងអ៊ីនធីហ្វេស។ អង្គជំនុំជម្រះកត់សម្គាល់ថា គ្រប់ភាគីទាំងអស់បានទទួលឯកសារជា *ហាត*កូពីរួចហើយពីការិយាល័យសហព្រះរាជអាជ្ញា។ អង្គជំនុំជម្រះក៏បានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងនីតិវិធីនៃការប្រើប្រាស់ឯកសារទាំងនេះនៅក្នុងឯកសារលេខ E319/7។ ដូច្នេះ អង្គជំនុំជម្រះសូមរំឭកទៅដល់ភាគីអំពីនីតិវិធីនៃការប្រើប្រាស់ឯកសារទាំងនេះ ដូចមាននៅក្នុងឯកសារ E319/7 នេះ។ ហើយដើម្បីជួយសម្រួលដល់ភាគីក្នុងការប្រើប្រាស់ឯកសាររូបនេះ អង្គជំនុំជម្រះនឹងផ្តល់ឲ្យភាគីនូវតារាងដែលមានយោងលេខឯកសារដើម និងលេខឯកសារដែលបានដាក់សម្រាប់ប្រើប្រាស់ក្នុងសំណុំរឿង០០២/០២។

ហើយនៅក្នុងពាក់ព័ន្ធនឹងបញ្ហានេះ ហើយលោក -- យើងកត់សម្គាល់ឃើញថាលោកមេធាវី គង់ សំអុន បានទទួលឯកសារហ្នឹងរួចហើយ។ យើងមើលនៅក្នុងឯកសារ E319/6.1 ឃើញចុះហត្ថលេខា បើលោកចុះហត្ថលេខាទទួលនូវឯកសារទាំងអស់នេះរួចហើយ។

បាទ ជាបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទទួលសិទ្ធិដើម្បីមានឱកាសបន្តការតាំងសំណួរដេញចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយសូមជម្រាបរំឭកដាស់តឿនដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា សូមបន្ថយល្បឿនក្នុងការតាំងសំណួរ ពីព្រោះលោកស្រីនិយាយភាសាញាប់ អាចបញ្ហាបកប្រែភាសាមិនបានល្អទេ។

សូមអញ្ជើញ!

**លោកស្រី ម៉ុច សុវណ្ណារីៈ**

ចាស សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ជម្រាបសួរលោកពូជាថ្មីម្តងទៀត។ បន្តមកទៀតនេះ ខ្ញុំនឹងសួរសំណួរលោកពូទាក់ទងជាមួយនឹងស្ថានភាពរបស់កុមារនៅក្នុងគុកក្រាំងតាចាន់។ ទាក់ទងជាមួយនឹងការសម្លាប់កុមារតើលោកពូធ្លាប់បានឃើញករណីដែលគេសម្លាប់កុមារ តើគេសម្លាប់កុមារដោយរបៀបណាដែរ?

[១៣:៣៥:៤៨]

**លោក សយ សែន៖**

**ឆ៖** បាទ ខ្ញុំបានឃើញតែមួយដង ដែលកុមារគេសម្លាប់ហ្នឹងដោយសារឪពុកម្តាយគេយកមកសម្លាប់មុន។ ហើយនៅសល់ក្មេងហ្នឹងសល់ពីរនាក់ គេនាំមកតាមក្រោយ ប្រហែលជារំលងប្រហែលអាច មិនចាំថ្ងៃ ប្រហែលជា២ថ្ងៃ ក៏៣ថ្ងៃក៏មិនដឹង ម៉ែឪគេសម្លាប់ហើយ គឺនាំក្មេងមកក្រោយពីរនាក់ទៀតថា ម៉ែឪគេនាំយកមកដាក់ហ្នឹងហើយ។ ហើយទទួលក្មេងគេយកទៅសម្លាប់ហ្នឹង មានក្មេងមួយក៏តាមខ្ញុំប៉ាន់មើលប្រហែលជាប្អូន ប្រហែលជាខ្ទង់អាយុ៣ឆ្នាំ ឬក៏៤ឆ្នាំ ហើយបងហ្នឹងខ្ទង់ប្រហែលជាអាច៦ឆ្នាំ ឬក៏៥ឆ្នាំក៏មិនដឹង។ ប៉ុន្តែយកប្អូនទៅមុនៗ ខ្ញុំទៅឡើងត្នោតដើមត្នោតជូរឡើងឲ្យប្រធានគុកក្រាំងតាចាន់ ទៅដាក់ទឹកត្នោតជូរឲ្យគាត់ថ្ងៃរសៀលហ្នឹងថ្ងៃល្ងាចហ្នឹង។ ទៅដល់ខ្ញុំនៅពីលើចុងត្នោតហ្នឹង នៅលើចុងត្នោត ហើយគាត់យកក្មេងទៅតាមក្រោយពីរហ្នឹងក៏ ធម្មតាពួកគាត់ទៅតែងតែរក កាលណាខ្ញុំឡើងត្នោត គាត់ទៅអង្គុយចាំគល់នៅត្នោតថា "អ្វែងដាក់មក ចុះមកឲ្យលឿនមក អញផឹកបន្តិចមើលអ្នា" គាត់ក៏បាននិយាយអ៊ីចឹង ខ្ញុំក៏ -- សព្វថ្ងៃគាត់និយាយតែអ៊ីចឹង ដល់តែថ្ងៃហ្នឹង គាត់នាំក្មេងទៅឮសូរមាត់គឹលៗនៅខាងក្រោមដើមត្នោត ខ្ញុំនៅលើចុងត្នោតពីលើហ្នឹង។ នៅចុងខាងលើឮសូរ "ផូស"ៗគល់ត្នោតអ៊ីចឹង ខ្ញុំងាកមើលក្រោម ចុម! បោកក្មេង។ ដល់បោកក្មេងអ៊ីចឹងវា ពាក់អាក្មេងព្យួរជើងឡើងលើអ៊ីចឹង វារះយកប្រមាត់។ បាទវះយកប្រមាត់ ក៏វាហែកអា -- មានកូនត្នោតមួយដើម កូនត្នោតដែលដុះនៅក្បែរហ្នឹង ហែកអត្រចៀកត្នោតអាក្បាបត្នោតហ្នឹង ហែកខ្វាកអ៊ីចឹងមក ចងប្រមាត់ហ្នឹងព្យួរដាក់នៅជាប់នឹងបង្កោងត្នោត ខ្ញុំអ្នកឡើងហ្នឹង។ ហើយដល់ព្យួរហ្នឹងហើយ ក៏វាបោះមកដាក់ខាងត្បូងដើមត្នោតហ្នឹងមានគ្រលុក គេកាប់គ្រលុកហើយ ក៏បោះក្មេងហ្នឹងដាក់នៅគ្រលុកហ្នឹង។ ពីរនាក់នៅចាំហ្នឹងៗក៏ខ្ញុំអត់ទាន់មានធ្វើអីនៅលើចុងត្នោត អត់ទាន់មានចុះអត់ទាន់ឡើង នៅនឹងថែសអង្គុយនៅលើដើមត្នោតហ្នឹង។ ដើមត្នោតហ្នឹងមានមួយជួរហ្នឹងវាមានដើមត្នោត ដូចប្រាំឬប្រាំមួយដើម ប៉ុន្តែខ្ញុំឡើងតែមួយដើម ប៉ុន្តែខ្ញុំឡើងឆ្លងទៅតាមគ្នាប្រាំប្រាំមួយដើម ដើមត្នោតហ្នឹង។

[១៣:៣៧:៥៤]

ដល់អ៊ីចឹង ចាំមើលមួយសន្ទុះទៀត ស្រាប់មកដល់គាត់មកដល់ទៀត មកដល់ទៀតនាំក្មេងមីមួយបងមកដល់ទៀត។ មកដល់ទៀត ក្មេងជាមួយបងមកដល់ហ្នឹង អត់មានសម្លាប់បោកគល់ត្នោតទេ គឺវ៉ៃ។ វ៉ៃហ្នឹងក៏អត់មានចងដៃចង់មុខដូចមនុស្សចាស់ទេ អត់ទេ។ ស្រាប់មកដល់ ឲ្យអង្គុយនៅគល់ត្នោតហ្នឹងពីខាងលិចគល់ត្នោតហ្នឹង ក៏គាត់វ៉ៃនឹងត្បូងចប ដងចបហ្នឹងប្រហែលជាអាចមួយម៉ែត្រទេដែលសម្រាប់វ៉ៃមនុស្ស ប្រហែលមួយម៉ែត្រ។ វ៉ៃផ្ទូងអ៊ីចឹងៗ មនុស្សចាស់គេច្រើនតែវ៉ៃផ្ទូងពីក្រោយផ្ទារ កាលណាធាក់ផ្ទារអ៊ីចឹង គេយកដាវចាក់ផ្ដាច់បំពង់ក។ ហើយដល់លើកនេះ អត់មានផ្ដាច់ ក្មេងហ្នឹងអត់មានផ្ដាច់បំពងកទេ វ៉ៃផ្ទូងអ៊ីចឹង គេថែមមួយផ្ទូសទៀតអ៊ីចឹង គេអូសដាក់រណ្ដៅ ហើយក៏លុបៗហើយក៏នាំគ្នាដើរទៅកន្លែងវិញជាធម្មតាអ៊ីចឹងទៅ។ ខ្ញុំក៏បានចុះពីចុងត្នោតមក តែប៉ុណ្ណឹងទេបាទ។

**ស៖** ចាស សូមអរគុណលោកពូ។ អ៊ីចឹង ក្រៅពីករណីនេះមួយ ជាករណីពិសេសដែលពូបានឃើញគេសម្លាប់ក្មេងស្រីពីរនាក់ ដែលសម្លាប់ក្មេងស្រីប្អូនហ្នឹងរះពោះយកប្រមាត់។ អ៊ីចឹងតើលោកពូធ្លាប់បានឃើញ ឬក៏ធ្លាប់បានដឹង ឮគេនិយាយទាក់ទងជាមួយនឹងការដែលគេសម្លាប់កុមារសម្រាប់ករណីផ្សេងទៀតដែរទេ?

**ឆ៖** បាទ ខ្ញុំបានឃើញៗផ្ទាល់ ហើយស្គាល់ទាំងអ្នកសម្លាប់ ហើយសព្វថ្ងៃក៏គាត់នៅដែរ នៅខ្លះ ស្លាប់ខ្លះនៅខ្លះអ្នកសម្លាប់សព្វថ្ងៃក៏នៅដែរបាទ។

[១៣:៣៩:៣៣]

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណលោកពូ អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ ខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីជូនវេទិកាសួរសំណួរតដល់លោកស្រីមេធាវី ម៉ាទីន ហ្សាកកាំង សហភាគាខាងផ្នែកអន្តរជាតិរបស់ខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រី អស់លោក លោកស្រីចៅក្រមជាទីគោរព ភាគីទាំងអស់ជាទីគោរព។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

**ស៖** ជម្រាបសួលោកសាក្សី លោកៗបានឆ្លើយទាក់ទងទៅនឹងអេតាស៊ីវិលរបស់លោក ហើយខាងមេធាវីការពារក្ដីបាននិយាយថា លោកពុំមានឈ្មោះដូចគ្នាសម្រាប់តែឈ្មោះឪពុករបស់លោកជាដើម មុនហើយនិងក្រោយ។ តើអ៊ីចឹងអាចពន្យល់បានពីភាពខុសគ្នានេះ ទាក់ទងអត្តសញ្ញាណរបស់លោកនេះ?

**លោក សយ សែន៖**

**ឆ៖** បាទខ្ញុំពន្យល់បាន ពីមួយសន្ទុះពីមុនហ្នឹង ខ្ញុំចូលមក ខ្ញុំភ័យ ខ្ញុំខ្លាចពេក និងភ័យខ្លួនឯងពេក គឺខ្ញុំឆ្លើយខុសពីឪពុកខ្ញុំ។ នាមត្រកូលគាត់ ទិត្យ សយ មិនមែន ណាំង សយ ទេ ទិត្យ សយ។ ណាំង សយ ហ្នឹងជាបងគាត់។

**ស៖** បើតាមចម្លើយចេញពីសំណុំរឿងហ្នឹង ហើយលោកក៏បានបញ្ជាក់ដែរថា ពេលដែលលោកនៅក្នុងមន្ទីរឃុំឃាំងក្រាំងតាចាន់ហ្នឹងរយៈពេល៥ឆ្នាំ។ តើលោកអាចបញ្ជាក់ពីចំណុចនេះជូនតុលាការបានទេ?

[១៣:៤១:៣១]

**ឆ៖** អាចៗបញ្ជាក់បានពីប្រវត្តិរបស់ខ្ញុំ អាចបញ្ជាក់បានបាទ។ ខ្ញុំពីដើមឡើយមក វា -- ថាដូចតែជាប់ហ្នឹងគឺខ្ញុំនៅក្មេង គឺអាចមិនអាចចាំបានពីរឿងបញ្ហាមូលហេតុដែលរឿងរ៉ាវខ្ញុំមិនអាចដឹង ប៉ុន្តែតាមខ្ញុំស្មានទៅគឺថា ពីរឿងខ្ញុំពីបញ្ហាវាពាក់ព័ន្ធពីឪពុកធ្វើមេស្រុកពីជំនាន់លន់នល់ -- ពីជំនាន់សីហនុៗ។ ហើយពាក់ព័ន្ធតែប៉ុណ្ណឹងរឿងខ្ញុំ អត់ដែលមានរឿងហេតុអីពីបញ្ហាណាមួយក៏អត់មានដែរ មានពាក់ព័ន្ធដែលហៅថា ជំនាន់ហ្នឹងគេរើសប្រវត្តិរូបថា សក្តិភូមិនិងនាយទុន។ គេនិយាយពីសក្តិភូមិនិងនាយទុនជំនាន់នោះ។

**ស៖** តើលោកអាចរៀបរាប់អំពីគុកហ្នឹងថា ក្រឡាផ្ទៃប៉ុន្មាន ហើយមានរបងយ៉ាងម៉េចអីម៉េចដែរ? សូមជួយរៀបរាប់បន្តិចមើល។

**ឆ៖** បាទ ក្នុងតួគុកមួយទាំងមូល គឺឧទាហរណ៍ថា វាទទឹងប្រាំម៉ែត្រអ៊ីចឹង បណ្ដោយវាមានជួនខ្លះមានដល់ពីរដណ្ដប់ ខ្លះមានប្រាំបួន ខ្លះមានដល់១៥ វាមានតាមដែលគេធ្វើតាមក្រោយ ប៉ុន្តែគុកហ្នឹងអ្នកទោសអ្នកធ្វើដដែល អត់មាន ក្រែងតែគាត់ -- ពួកគាត់នៅឈរបញ្ជាឲ្យអ្នកទោសអ្នកធ្វើទេ។ ប៉ុន្តែរឿងគុកហ្នឹង វាថាពីក្រោមក្ដារយើងសម្រាន្តអ៊ីចឹង វាមានត្បាញលួសបន្លានៅពីក្រោយហើយជីកជញ្ជាំងពីខាងហ្នឹងក៏មានលួសបន្លា កប់លួសបន្លានៅក្រោមដីជម្រៅប្រហែលជិតមួយម៉ែត្រ។ កប់ហើយ

E1/256.1/Old-4

បានជីកកូនឈើផ្ទប់ ឈើបង្គោលផ្ទប់ហើយបានវ៉ៃជញ្ជាំង វ៉ៃជញ្ជាំងហើយបានផ្ទប់កូនឈើសងខាង។ ហើយរនាបពីក្រោមយើងសម្រាន្តហ្នឹងក៏មានលួសសំណាញ់ដែរ ពីលើយើងហ្នឹងក៏មានលួសសំណាញ់ ដែរ មានលួសសំណាញ់។ ប៉ុន្តែពីលើគេប្រក់ក្បឿង ពីដើមគេហៅក្បឿងស្រកាលេញ ដែករណែងយើង វ៉ៃវាងញ៉ើកស្ដឹបហ្នឹងការពារកុំឱ្យមនុស្ស កាលណារួចពីគុកអីទៅ កាច់ខ្នោះកាច់អីរួចទៅឡើងទាញដំបូល ឡើងលើរួចបាត់។

[១៣:៤៣:៤៧]

**ស៖** តើមានរបងច្រើនទេ នៅជុំវិញបរិវេណគុកហ្នឹង?

**ឆ៖** មានរបងទី១ ៗជាប់ហួសរបងគុកហ្នឹងដីប្រហែលចេញពីគុកហ្នឹងមក ដីប្រហែល សម័យ បច្ចុប្បន្នរាល់ថ្ងៃគេធ្វើរបងជាប់នឹងរបងទី១ហ្នឹង សម័យបច្ចុប្បន្នរាល់ថ្ងៃនេះ។ តែដល់របងទី២ នោះផ្លូវ ខាងកើត។ ហើយដល់របងទី៣នោះត្បូង ឯទំនប់ត្បូងនោះ ប៉ុន្តែរបងទី៣នោះ វាអត់ជាគោលចូលទេ បើ ថា របងទី២ និងទី១ បានរបងធំ បានរបងរាយលួសបន្លាធំ ហើយតឹងមែនទែនតែម្ដង របងទី១។

**ស៖** លោកបាននិយាយអំពីអ្នកទោសដោយពន្យល់ថា ពួកគាត់ហ្នឹងត្រូវបានគេដាក់ខ្នោះនៅក្នុង អគារ។ តើលោកអាចបញ្ជាក់បានដែរឬទេថា នៅក្នុងអគារទាំងអស់នោះមានស្ត្រី ហើយនិងកុមារផង ដែរ។ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បានបាទ។ ស្ត្រីនិងកុមារ កុមារដែលតូចៗ មិនអាចដាក់ខ្នោះកើត អត់អាចដាក់ខ្នោះកើត ឱ្យនៅជាមួយឪពុកម្ដាយៗ។ កាលណានេះ ដេកជាប់នឹងឪពុកម្ដាយអីចឹងទៅ ដេកចំហៀងជាមួយឪពុក ម្ដាយ អត់អាចដាក់ខ្នោះបានទេ ក្មេងតូចៗវាអត់មានខ្នោះដាក់ តូចៗពេកវាដាក់ខ្នោះ វាមានច្រើនតែធំៗ កងជើងអីចឹង កាលណាដាក់កងជើងទៅ ដាក់ក្មេងទៅ កដៃតូចៗដាក់ម៉េចនឹងជាប់ គេអត់ដាក់ទេ។

**ស៖** តើជាទូទៅនឹងមានមនុស្សស្លាប់ប៉ុន្មាននាក់ដែរក្នុងមួយអគារៗ?

[១៣:៤៥:៤៥]

**ឆ៖** មិនអាចកំណត់បានទេ។ អ្នកស្លាប់ គឺកាលណាស្លាប់ គេវ៉ៃយកមកថ្មីអីចឹង យកទៅសួរ ចម្លើយ។ សួរចម្លើយ ចូលដល់សួរចម្លើយហ្នឹង គេវ៉ៃសួរចម្លើយនៅកន្លែងសួរចម្លើយនោះ។ វ៉ៃសួរកន្លែង សួរចម្លើយ មកកន្លែងអត់រួច ខ្ញុំអ្នកទៅគ្រាពីកន្លែងសួរចម្លើយយកមកដាក់នៅកន្លែងគុកនេះ។ ទៅគ្រា មក នាំមក ជួនកាលសែងមកអីចឹងទៅ គ្រាអត់រួចសែង សែងមកដាក់នៅកន្លែងសួរ -- យកមកដាក់នៅ កន្លែងគុកនេះ យកមកដាក់គុកវិញ។ វ៉ៃសួរចម្លើយ ទារុណកម្មប៉ុណ្ណឹងហើយ យកមកដល់ដាក់ខ្នោះដៃ

ដាក់ខ្នោះដៃ ដាក់ខ្នោះជើងទាំងពីរវិញដដែល។ ប៉ុន្តែបាយគេអត់ឲ្យហូបទេ អត់ដួសបាយឲ្យទេ បបរអត់ អីអត់ អ្នកដែលគេថា ទោសក្បត់ជាតិ ជំនាន់ហ្នឹងគេហៅ "ទោសក្បត់ជាតិ" អត់ឲ្យបាយហូបទេ។ ទៅដល់ដាក់ខ្នោះចោលហ្នឹងហើយ ចេះតែចោលទៅ ចោលទល់ៗយប់ទល់ព្រឹក បាយក្នុងគុកហ្នឹងរយៈកាល -- បើមនុស្សប្រុសវិញអត់បាយអត់ទឹកបាន១៨ថ្ងៃ បាទគឺស្លាប់។ ខ្ញុំបាន -- បានខ្ញុំអត់បានរាប់ទេ ខ្ញុំកាច់ខ្ទាច់ ខ្ទាច់ជាដូចថាៗ មានស្លឹកត្នោតអី កាច់ថាថ្ងៃហ្នឹង១ថ្ងៃ កាច់ស្លឹកត្នោតមួយសន្លឹក កាច់មួយកំណាត់ដាក់ទុកចោលនៅហ្នឹង ទុកនៅក្បែរកន្លែងខ្ញុំដេកហ្នឹង។ ដល់ស្អែកឡើងកាច់មួយសន្លឹកទៀត បានខ្ញុំរាប់មើល១៨ថ្ងៃ គឺអាចដាក់ខ្យល់ម៉ាត់។ ដាច់ម៉ាត់ គឺយើង -- គេឲ្យខ្ញុំយកចេញយកសពហ្នឹងទៅទុក ដាក់ហើយយើងលុប យកដាក់កប់ដាក់អី។

[១៣:៤៧:១៥]

**ស៖** ចំពោះលោកនោះ មូលហេតុដែលធ្វើឲ្យមនុស្សស្លាប់ មូលហេតុចម្បងហ្នឹងគឺអ្វីដែរ?

**ឆ៖** គេវ៉ៃៗសួរចម្លើយហើយគេយកមកដល់ អាហ្នឹងស្លាប់ទៅតាមគុកទេណា៎ មិនមែនសម្លាប់ទេ។ អាហ្នឹងគេសួរចម្លើយៗដែលថា មិនដឹងថា សួរយ៉ាងណាយ៉ាងណី ខ្ញុំអត់ដែលបានទៅជិតទេ ដែលថា គេសួរចម្លើយហើយ គេវ៉ៃទារុណកម្មហើយ ដូចថាកន្លែងសួរចម្លើយហ្នឹងយកទៅគេចងដៃ។ គេសួរហើយ យើងអត់ឆ្លើយ គេចងដៃ។ ចង់ដៃ ចងកំណាត់កៅស៊ូយើង កៅស៊ូស្តើងៗ កៅស៊ូ សម័យបច្ចុប្បន្នឥឡូវគេថា សែងភ្លៀង។ ចងមុខៗ កន្ទ្រប់នៅហ្នឹង ហើយកាលណាអ្នកណាអត់សូវឆ្លើយ អ្នកណាដែលឆ្លើយថា នៅតាមសហករណ៍ថា លួច ប្លន់អី ឬថាលួច។ លួចហើយ អត់មានលួចពីខុសពីរឿងថាលួចដូង លួចស្វាយ លួចដូចថា ជាពិសេសលួចដំឡូង ហើយដូងញ៉ាំជាងគេតែម្តង មានតែប៉ុណ្ណឹង។ កាលណាហេវ អត់ឃ្លានចេះតែលួចហើយ លួចហើយ ឆ្លើយថា "លួច" រួចខ្លួន វ៉ៃតែម្តងហ្នឹងហើយ យកបញ្ជូនមកដាក់គុកហើយ។ ហើយបើឆ្លើយថា "អត់លួចទេ" គេវ៉ៃហ្នឹងហើយ នៅតែវ៉ៃ វ៉ៃទាល់តែឆ្លើយ។

**ស៖** តើលោកមានព័ត៌មានបន្ថែមអំពីមធ្យោបាយធ្វើទារុណកម្មលើអ្នកទោសដែរឬទេ?

[១៣:៤៨:៤៧]

**ឆ៖** មានៗតែអ្នកដែលលែងចេញក្រៅមកថា មានដៃ មានជើង ដូចថាៗ ដើរទៅអីចឹង ឃើញអី ដូចឃើញដំឡូងឃើញអីចឹង បើសម័យនុ៎ងមានអីមានតែដំឡូង បាទ ឃើញដំឡូងឃើញអីវាដួលដំឡូងមីវាដួលអីបេះអីចឹងទៅ គេថាយើងលួចហើយ គេវ៉ៃ គេតប់អីអីចឹងទៅណា៎ មានតែប៉ុណ្ណឹង។ ថែម

E1/256.1/Old-4

បើថាគេលែងធ្វើអី ធ្វើហ្នឹងកុំប៉ះកុំពាល់អី អាហ្នឹងអត់អីទេ។ តែប៉ះពាល់អី ប៉ុន្តែប៉ះពាល់ៗតែចំណីហូបទេ ក្រៅពីចំណីហូបអត់ប៉ះពាល់ទេជំនាន់ហ្នឹង។

**ស៖** តើការធ្វើទារុណកម្មពិសេសហ្នឹង ត្រូវបានប្រើប្រឆាំងនឹងអ្នកទោសដើម្បីឲ្យគេសារភាពដែរឬទេ?

**ឆ៖** បាទ ប្រើអាហ្នឹង ប្រើ។ ឧទហរណ៍ថា គេឆ្លើយដូចខ្ញុំបាននិយាយពីមុនមកបន្តិចថា កាលណាយើង សួរយើងថានៅតាមសហករណ៍។ មកដល់តាមដែលខ្ញុំដឹង អាចដឹង គាត់សួរឮៗ ឲ្យខ្ញុំទៅយកអ្នករបួស អ្នកគេវ៉ៃទារុណកម្មយកមកទុក គេសួរថា “អ្អែងនៅតាមសហករណ៍ អ្អែងអី អ្អែងបានវ៉ៃចបចោល អ្អែងបានកាប់បង្គីចោល ឬអ្អែងលួចដូងស៊ីអត់?” ប្រាប់ថា “លួច” “អ្អែងបាក់ចប បាក់ស្ពាបព្រា បាក់ដងអីហ្នឹង” ដឹងតែគេលែងវ៉ៃ បញ្ជូនយកមកឲ្យដាក់គុកហើយអាហ្នឹង គេឲ្យយកមកដាក់ខ្នោះវិញ។ លែងវ៉ៃ លែងសួរហើយ។

[១៣:៥០:១៨]

**ស៖** តើហេតុអ្វីបានគេដាក់ បានគេច្រកថង់ប្លាស្ទិកទៅនែលើក្បាលអ្នកទោសនោះ ហេតុអីបានគេធ្វើអីចឹង?

**ឆ៖** បាទអាហ្នឹងខ្ញុំអត់ដឹងដែរ។ អាហ្នឹងវាផែនការរបស់ពួកគាត់ ខ្ញុំអត់បានដឹងដែរ។ ហ្នឹងកន្លែងគេសួរចម្លើយ អត់ដឹង។

**ស៖** តើមានរឿងអ្វីកើតឡើង បើសិនជាអ្នកទោសដែលគេយកចេញហើយហ្នឹង ហើយគាត់ព្យាយាមរត់គេចខ្លួន តើមានរឿងអីកើតឡើង?

**ឆ៖** អូ៎! អាហ្នឹងៗធ្ងន់តែម្តងអាហ្នឹង។ តែគេចវេះនៅកន្លែង អ្នកទោសហ្នឹងគេចវេះនៅកន្លែងធ្វើការហ្នឹង គេចតែមួយជំហានចេញពីក្រៅកន្លែងធ្វើការហ្នឹង គេចោទយើងថារត់ គេបាញ់តែម្តង។ អត់មានវ៉ើៗ បាញ់តែម្តងៗ។ គឺអ្នកយាមកងទ័ពគឺចេញទៅការពារអ្នកទោសប្រាំនាក់ទៅធ្វើការអីចឹង កងទ័ពពីរនាក់ ឬបីនាក់ កាំភ្លើងគ្រប់ដៃទាំងអស់។ បាញ់តែម្តង អត់មានចាំបាច់វ៉ៃអីទេ បាញ់តែម្តង បាញ់ហើយយកឲ្យអ្នកទោសឃើញទាំងអស់គ្នា បាទ។

**ស៖** តើនេះ -- តើគេធ្វើរបៀបម៉េច ដើម្បីយកមនុស្សចេញពីអគារទាំងអស់នុ៎ង ដើម្បីយកទៅសម្លាប់នោះ គេធ្វើរបៀបម៉េច?

[១៣:៥១:៥៦]

**ឆ៖** បាទមុននឹងគេយកសម្លាប់ ឧទាហរណ៍ថាក្នុងអគារហ្នឹងអ៊ីចឹង ទៅដល់អនុប្រធាន ប្រធានអត់សួរទេ ច្រើនតែអនុប្រធាន អនុប្រធានគាត់--

**ប្រធានអង្គជំនុំ៖**

ឈប់ៗឈប់ៗ កុំអាលទាន់ឆ្លើយតប សូមសាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រី ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងបានទទួលសារពីអ្នកបកប្រែមកថា លោកស្រីនិយាយដាក់មាត់កៀកក្បាលមីក្រូពេក ដូច្នេះធ្វើឱ្យសំឡេងហ្នឹងខ្ទរឡើងមក មិនអាចបកប្រែបានពេញលេញទេ។

[១៣:៥២:៥០]

**លោកស្រី ម៉ាទីន ហ្សាកកាំង**

សូមអរគុណលោកស្រីចៅក្រម។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

**ស៖** តើគេធ្វើយ៉ាងម៉េចដែរ ដើម្បីយកមនុស្សទៅសម្លាប់ប្រចាំថ្ងៃនោះ?

**លោក សយ សែន៖**

**ឆ៖** បាទ មុននឹងយកមនុស្សទៅសម្លាប់ គឺទៅដល់គេបើកទ្វារ បើកទ្វារគុកហ្នឹង គេប្រាប់ថាឥឡូវបើកទ្វារគុកហ្នឹង គេប្រាប់ថាបងប្អូនទាំងអស់បានរួចទៅតាមសហករណ៍វិញហើយ បើអ៊ីចឹងយើងត្រូវ និងគោរពនឹងផែនការនឹងអង្គការ ប៉ុន្តែមិនបានទៅអស់គ្នាទេ បានទៅមួយចំនួន ប៉ុន្តែគាត់យកក្រដាសមួយមកសម្រាប់មើលបញ្ជី។ ទៅដល់ផ្សាយប្រាប់ គាត់ធ្វើនាម -- ក្នុងនាមនយោបាយ គាត់ថា "បើបានរួចទៅតាមសហករណ៍វិញ ហ្នឹងយើងគោរពនឹងអង្គការ គោរពនឹងផែនការអង្គការ កុំខ្មាស់នឹងកង់ប្រវត្តិសាស្ត្ររបស់អង្គការ យើងគោរពនឹងអង្គការ"។ ទៅដល់ គាត់ហៅឈ្មោះម្តងពីរ ហៅឈ្មោះម្តងពីរៗ ហូតខ្នោះៗចេញខ្ទាក ដាក់ឈ្មោះអី ថាដាក់ឈ្មោះ "ក" ឈ្មោះ "ខ" ចេញមកក្រៅមក។ ដល់ដើរចេញមកក្រៅ ហួសកន្លែងគុកហ្នឹង ហួសមកដល់ខាងត្បូងបន្តិច មានព្រៃដំឡូងមីៗ ទៅដល់ឃើញកងទ័ពនៅចាំហ្នឹងពីរនាក់។ ចាំហ្នឹងពីរនាក់ ដល់ហ្នឹង "អ្ហឺ! យើងបានៗរួចទៅតាមសហករណ៍វិញ យើងជួបនឹងអង្គការ សូមចងដៃៗហើយចងមុខ" ហួសកន្លែងដែលគុកនៅឆ្ងាយបន្តិចដែរ ដីប្រហែលជាអាច ១០ម៉ែត្រ។ សូមចងដៃចងមុខថា "ហេតុខ្ញុំត្រូវចងដៃចងមុខ មិនឱ្យនឹងឃើញនឹងអង្គការ គុំក្លួនជាមួយ

អង្គការ"។ មកដល់ ហើយយកជិតទៅដល់កន្លែងសម្លាប់ហើយ បាទមានកូនមីក្រូមួយ ចាក់កូនមីក្រូមួយនៅអាដើមស្វាយកន្លែងចុងភៅអ្នកទោសហ្នឹង។ ហើយយើងពុះខសៗកង់ខ្លីៗ នៅពុះនៅក្រោមដើមស្វាយជិតរបងជញ្ជាំងអ្នកទោសហ្នឹង កុំឲ្យឮសូរស្នូរអានោះមកដល់។ ស្រាប់តែជិតទៅដល់ហើយខ្ញុំនេះ គេឲ្យខ្ញុំហ្នឹងសម្រាប់ពុះខសរណ្ដួងរណាងៗ ហើយមីក្រូចាក់បទចម្រៀងសម័យ ប៉ុល ពត ហ្នឹង។ ហើយទៅដល់នោះមួយសន្ទុះ បកមកយកវិញៗ កាលណាគេមកយកវិញ យើងបន្ថយនឹងពុះខសបន្តិចទៅ ហើយបន្ថយចម្រៀងបន្តិចហ្នឹង បាទ។

[១៣:៥៥:០០]

**ស៖** តើលោកអាចបញ្ជាក់បានដែរឬទេថា តើគេសម្លាប់មនុស្សរបៀបណាដែរ?

**ឆ៖** បាទ គាត់ដណ្ដើរទៅដល់ គាត់ឲ្យអង្គុយ។ អង្គុយហើយ គាត់វ៉ៃនឹងត្បូងចបៗពីក្រោយហើយ គាត់ធាក់ប្រមៀល។ ខ្ញុំបានមានប្រសាសន៍ពីមុនមកថា ធាក់ប្រមៀលហើយ ដូចប្រុសៗ និងចាស់ៗ គេអាចយកដាវមួយ ដាវវែងៗ ផ្ដែប្រហែលជាអាចជាបួនតឹក និងប្រាំតឹកផ្ដែដាវហ្នឹង។ វ៉ៃពីក្រោយហើយ យកដាវកាត់បំពង់កនេះ។ កាត់បំពង់កហើយ អូសទម្លាក់រណ្ដៅហើយ ស្រាតខោអាវចេញទាំងអស់ ខោអាវមិនថាស្ត្រីមិនថាបុរស ស្រាតទុកគរមួយកន្លែងៗហ្នឹង បោះគរហ្នឹង តែពេលវ៉ៃ១ថ្ងៃហ្នឹង ចប់ថ្ងៃហ្នឹងអ៊ីចឹង ថ្ងៃល្ងាចឡើងគាត់ឲ្យខ្ញុំទៅប្រមូលខោអាវ និងខោអាវយកទៅគក់។ គក់យកទៅទុកចោលនៅត្រពាំងខាងលិច ខាងលិចមានត្រពាំងភូមិមួយខាងលិចមួយទៀត យកទៅគរចោលហ្នឹង បានហាលទុកចោលហ្នឹងពីរបីថ្ងៃ បានប្រមូលខោអាវហ្នឹងដាក់ យកមកដាក់នៅឃ្លាំងៗជិតកន្លែងសួរចម្លើយហ្នឹង។ ប្រមូលទុកដាក់បានយូរបន្តិច បានមានឡានឡង់រ៉ូវែរគាត់ដឹកចេញទៅចែកតាមសហករណ៍។

**ស៖** បើសិនជាៗគេមិនសម្លាប់ភ្លាមៗទេនោះ តើមនុស្សដែលនៅមន្ទីរឃុំឃាំងហ្នឹង អាចត្រដររស់បានរយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** អ្នកគេដាក់គុកក្នុងហ្នឹង ដែលវ៉ៃសួរចម្លើយទារុណកម្មដាក់គុកក្នុងហ្នឹង មិនអាចរត់រួចក្នុង១ខែក្នុងម្នាក់ទេ ព្រោះគេអត់ឲ្យអីហូបទាំងអស់ អត់មានហូបអីទាំងអស់។ គេដាក់ខ្នោះចោលតែម្ដង។

**ស៖** អ៊ីចឹងបានន័យថា ទោះបីយ៉ាងណាក៏ដោយគឺថា រយៈពេល១ខែហើយហ្នឹង ពួកគេនឹងស្លាប់ហើយទោះបីថា គេមិនបានយកទៅសម្លាប់ភ្លាមៗនោះក៏ដោយ។ អ៊ីចឹងមែនទេ?

[១៣:៥៧:២៣]

**ឆ៖** បាទ ព្រោះមុននឹងយកមកសួរចម្លើយ ហើយមុនយកមកទុកនៅកន្លែងវិញ គឺគាត់ធ្វើទារុណកម្មឡើងហួត់ឡេវអស់ហើយ គ្មានសល់អី ឈាមចេញតាមមាត់តាមអណ្ដាតអស់ហើយ លែងដឹងលែងអីជាមនុស្សអស់ហើយហ្នឹង បាទ។

**ស៖** តើលោកបានធ្លាប់ជីករណ្ដៅដើម្បីកប់សាកសពទេ?

**ឆ៖** បាទ ខ្ញុំបានជីកពីឆ្នាំ ឆ្នាំគេថាជ័យជម្នះ ហ្នឹងគេអត់ទាន់ប្រើខ្ញុំជាហ្វឹកហ្វឺនទេកន្លែងហ្នឹង គេអាចថា ដូចជាមិនសូវទុកចិត្តខ្ញុំទេ។ បើជីកខ្លាំង ហ្វឹកហ្វឺនខ្លាំង ដែលអាចឲ្យខ្ញុំទៅជួយកប់សពហ្នឹង ទុកដាក់ខ្មោចមែនទែនតែម្ដង ឆ្នាំ៧៧។ ៧៧ ហ្នឹងដោយសារវាមានកើតសង្គ្រាមមួយនៅតាមព្រំដែនវៀត-ណាម កាលហ្នឹងវាធ្វើសង្គ្រាមមួយសម្រាប់មកចូលមកស្រុកខ្មែរហ្នឹង ហ្នឹងបង្ខំ ហើយខ្ញុំដឹងឆ្នាំហ្នឹងវាយខ្លាំងហើយ បង្ខំខ្លាំងឆ្នាំ៧៧ហ្នឹង បាទ។

**ស៖** តើអ្នកយាមខ្លះហ្នឹងមានអត្តចរិតមិនអាចទទួលយកបានជាមួយនឹងស្ត្រីភេទដែរឬទេ?

**ឆ៖** មាន បាទ។ មានកងទ័ពខ្លះមានធម៌មេត្តាខ្លះ រាងអាណិតអាសូរអ្នកទោសខ្លះ។ បើកងទ័ពខ្លះអត់ទេ អត់អាណិតៗធម៌មេត្តាចំពោះអ្នកទោសទាំងអស់។

[១៣:៥៩:១៧]

**ស៖** តើលោកបានឃើញអ្នកយាមម្នាក់ ឬក៏ច្រើននាក់រំលោភស្ត្រីភេទដែរឬទេ?

**ឆ៖** បាទៗ ខ្ញុំបានឃើញតែម្នាក់ទេ។ ម្នាក់ហ្នឹងប្រើខ្ញុំទៅ កុំអីខ្ញុំអត់បានឃើញទេ។ គាត់ ប៉ុន្តែរឿងរំលោភផ្ទាល់គឺអត់បានឃើញទេ ប៉ុន្តែគាត់ប្រាប់ខ្ញុំ។ កងចល័តត្រូវបញ្ជូនមកថ្ងៃល្ងាចអ៊ីចឹងមក មកដល់ប្រហែលជាថ្ងៃម៉ោងបួន ប្រហែលម៉ោងបួនម៉ោងបីអីតាមមើល ថ្ងៃល្ងាចហើយ ខ្ញុំដឹកក្របីចូលក្រោលហើយហ្នឹង។ ដល់គាត់រំលោភអ៊ីចឹងនៅកន្លែងគុកងងឹត កន្លែងដើមអំពិលពីខាងត្បូងគុកហ្នឹងមានគុកងងឹតមួយ។ គុកងងឹតហ្នឹង គឺដូចថាគុកគេថាជីកដីទៅក្រោម ប៉ុន្តែអត់នៅក្នុងគុកហ្នឹងទេ នៅលើគុកនៅក្បែរគុកហ្នឹងប៉ុន្តែសុទ្ធតែព្រៃដំឡូងមី។ គាត់ថា៖ “អ្អែងដើរទៅត្បូងមួយភ្លែតមើល៍!” គាត់ឲ្យខ្ញុំដើរទៅត្បូង ហើយដើរទៅត្បូងអ៊ីចឹង ខ្ញុំថា៖ “ទៅធ្វើអីបង?” គាត់ថា៖ “ហ៊ឺ! ទៅមួយភ្លែតទៅ!” ហើយទៅគាត់ថា៖ “អញធ្វើហើយ អ្អែងទៅរៀបចំធ្វើដាក់ទុកឲ្យហើយ” ហើយគាត់ថា៖ “អញធ្វើហើយ”។ ទៅដល់គាត់រំលោភកងចល័តពីរនាក់ហ្នឹងហើយ ខមាទោស គាត់រំលោភហើយអ៊ីចឹងទៅ គាត់យកអាគ្រាប់ក្បាលម៉ាស៊ីន ហៅសេវេនធីណៃហ្នឹង យកទៅញាត់ក្នុងកេរ្តិ៍ខ្មាសស្ត្រី ហើយឲ្យខ្ញុំទៅលុបសពនោះទៀត បាទ ហើយអ្នកហ្នឹងក៏រស់នៅសព្វថ្ងៃដែរ បាទ។

[១៤:០០:៤២]

**ស៖** តើជាទូទៅមានទំនាក់ទំនងផ្លូវភេទរវាងប្រធានគុក ហើយនិងអ្នកទោសដែរឬទេ?

**ឆ៖** មានឃើញ ប៉ុន្តែខ្ញុំមិនអាចមើលឃើញជាក់ស្តែង ដូចថាគាត់ញ៉េះញ៉ោះ ប្រធានគុកហ្នឹង គាត់ញ៉េះញ៉ោះជាមួយអ្នកទោស លែងដាំបាយហូប ឱ្យអ្នកទោសដាំបាយហូបខ្លួនឯងហ្នឹង មានឃើញ។ ប៉ុន្តែដល់ពេលរត់ពីឆ្នាំ៧៨ វៀតណាមចូលមក គាត់នាំអ៊ីអ្នកទោសហ្នឹងមួយ ទៅរត់ទៅជាមួយគាត់ក្នុងព្រៃទៅ។ អ៊ីហ្នឹងគាត់នៅរស់សព្វថ្ងៃ ប៉ុន្តែប្រធានហ្នឹងក៏ស្លាប់ទៅ។ ប៉ុន្តែចុងបញ្ចប់ ថាគាត់ -- អ៊ីហ្នឹងថា គាត់យកអ៊ីហ្នឹងសព្វថ្ងៃហ្នឹង។

**ស៖** តើនៅក្នុងគុកនោះ មានប្រភេទអ្នកទោសច្រើនទេ ផ្សេងៗគ្នាទេ?

**ឆ៖** វាសម័យនោះ វាប្រភេទវា តាមខ្ញុំមើលដូចជាមិនលើសខ្វះគ្នា ព្រោះសម័យហ្នឹងវាអត់ដែលមានប្លែកៗគ្នា មើលដូចៗតែគ្នាដដែល ប៉ុន្តែវាងច្រើន។ ប៉ុន្តែវាច្រើនដោយថ្ងៃ ដោយខែ មិនមែនថាច្រើនរាល់ថ្ងៃ អត់ទេ ក៏វ៉ៃចោលរាល់ថ្ងៃ ក៏អត់ដែរ វាមានខ្លត។ ជួនកាល១ខែ មានវ៉ៃបួនដង ប្រាំដង ឬ១០ដង អ៊ីចឹងទៅ និយាយរឿងអត់ មិនអត់ទេ នៅមានរហូតអ៊ីចឹង អត់ខានទេ។ ប៉ុន្តែប្រភេទវាដូចតែគ្នាៗ អត់មានអ្នកណាមួយរាងដូចថា ឱ្យតែចំពោះអ្នកទោស បើថាពួកខាងគាត់ ហ្នឹងបានរាងមើលភ្លឺៗជាងអ្នកទោស ហើយចំពោះអ្នកទោសអត់ទេ ដូចតែគ្នាទាំងអស់។

**ស៖** តើអ្នកទោសខ្លះត្រូវបានគេហៅថាជា "ប្រជាជនថ្មី" ដែរឬទេ?

**ឆ៖** បាទ ភាគច្រើនថ្មីហ្នឹងតែម្តង។ ភាគច្រើន ច្រើនតែ១៧មេសាហ្នឹង ប៉ុន្តែមកឆ្នាំ អាហ្នឹងឆ្នាំ៧៥ទេ បើថាឆ្នាំ៧៧អត់ទេ លែងប្រកាន់១៧មេសាហើយអាហ្នឹង ឆ្នាំ៧៧ហ្នឹង។ ឱ្យតែឮសួរថាមានខ្មាស់អីបន្តិចបន្តួច គេបញ្ជូនមកហើយ អាហ្នឹងឆ្នាំ៧៧ វាកំពុងតែច្រួលច្របល់ នៅកើតសង្គ្រាមនៅតាមព្រំដែន។

[១៤:០៣:២៦]

**ស៖** តើរូបលោកផ្ទាល់ លោករិះនឹងត្រូវបានគេសម្លាប់ ធ្លាប់ទេ?

**ឆ៖** ខ្ញុំបានគាត់វ៉ៃម្តង វ៉ៃបែកក្បាលពីក្រោយ ទាល់ស្នាមទាល់តែរាល់ថ្ងៃហ្នឹង។ គាត់វ៉ៃ ខ្ញុំបានឆ្លើយពីព្រឹកម្តង គឺវ៉ៃស្នូកកាំភ្លើងការ៉ាង តែម្តងហ្នឹង បាទ។ ហើយរឿងរំពាត់ហ្នឹង វ៉ៃញឹកញាប់ដែរ។ វ៉ៃ ឧទាហរណ៍ថា យើងដើរទៅណា បេះបោចអីជាដំណាំដំឡូងមីអី ត្រួយដំឡូងមីត្រួយអី យកមកលាយបាយបបរអ៊ីចឹង ឃើញគាត់វ៉ៃពីរបីរំពាត់អ៊ីចឹង បើរឿងខ្លាំង វ៉ៃតែម្តង ថាខ្ញុំលួចដំឡូង តែម្តងហ្នឹង។

**ស៖** តើលោកបាត់បង់សមាជិកគ្រួសារច្រើនដែរឬទេ នៅក្នុងគុកនុ៎ង?

**ឆ៖** បាទ ខ្ញុំមានតែឪពុកមួយទេ ក្នុងគុកហ្នឹង។

**ស៖** តើលោកបានឃើញ ឬក៏គ្រាន់តែដឹងថាអំពីការសម្លាប់ឪពុករបស់លោកទេឬ?

**ឆ៖** បាទ បានដឹង។ ដឹងៗពីកងទ័ពហ្នឹង ហើយចាស់ៗអ្នកប្រាប់ទេ បើថាចំពោះម៉ា -- កន្លែងហ្នឹងវាដូចមេៗវាអត់ប្រាប់ទេ ប្រាប់តែកងទ័ពដែលថាជិតស្និទ្ធអី ដូចថាគេមានការអាណិតអាសូរដល់ខ្ញុំអ៊ីចឹង គេប្រាប់។

**ស៖** តើមានអ្នកណាម្នាក់ពាក់មួកឪពុករបស់លោកដែរឬទេ?

**ឆ៖** បាទ មួកហើយនិងសារុង ហើយនិងអាវ ខ្ញុំបោកទឹកហើយ ខ្ញុំយកមួកហ្នឹងហើយសារុងហើយអាវ យកមកទុក។ ដល់យកមកទុកថាដេកដណ្តប់ហ្នឹង ដល់នេះ តាចេងៗ គាត់អនុប្រធានហ្នឹងគាត់យកមួកទៅពាក់ទៅ។ ពាក់ទៅដល់នៅ បន្តិចនៅប្រធាន នៅតាចេងអ៊ីចឹងទៅ វាអត់ទៀងទេមួកគាត់យកទៅពាក់ គ្នាគាត់ពីរបីនាក់ ជួនកាល តាចេង ពាក់ ជួនកាល តាអាន់ ពាក់អ៊ីចឹងទៅ។ ហើយខ្ញុំបានយកទុកតែអាវហើយនិង -- ហើយសារុងគាត់ទេ ដណ្តប់។

[១៤:០៦:២០]

**ស៖** តើចំនួនមនុស្សដែលឃុំឃាំងនៅក្នុងគុកនោះមានចំនួនប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ កងទ័ពវាមាន១២នាក់ ហើយប្រធានៗហ្នឹងបីនាក់ ហើយវាអត់ទៀង កាលណាគេបញ្ជូនមកច្រើន គេត្រូវបញ្ជូនកន្លែងស្នាក់ការពីអង្គរការកន្លែង តាឃន ហ្នឹងទៅមូលគ្នាហ្នឹងទៅកន្លែងតាកិល នៅត្រពាំងព្រីងខាងលិចហ្នឹងក៏មកមូលគ្នាហ្នឹងដែរ វាអត់ទៀង។ បើថានៅសព្វមួយដងដូចរាល់ថ្ងៃ ម៉្វៃពីរបីនាក់បួនដប់នាក់អ៊ីចឹងអត់មាន ខាងកន្លែងដទៃៗហ្នឹងអត់មកទេ បើច្រើនតែម្តងបានថាកន្លែងដទៃៗហ្នឹងបញ្ជូនគ្នាមកមូលមួយកន្លែង។

**ស៖** តើអ្នកណាជាអ្នកសួរចម្លើយ?

**ឆ៖** សួរចម្លើយតែប្រធាន ហើយនិងអនុប្រធាន ហើយសមាជិកគាត់តែបីនាក់ហ្នឹង តាចេង, តាអាន់, តាពេញ បីហ្នឹង។

**ស៖** តើលោកដឹងដែរឬទេ ថាតើតាអាន់ ជាអ្នកជ្រើសរើសអ្នកទោសដែលនឹងត្រូវយកសម្លាប់នោះ?

**ឆ៖** ហេតុហ្នឹងខ្ញុំអត់សូវបានដឹងដែរ ព្រោះខ្ញុំអ្នកទោសដែរ តែបើថាពីរបីថ្ងៃសម្លាប់ៗ ប៉ុន្តែមុន

នឹងគាត់សម្លាប់គាត់មាននីរសារគាត់ពីរនាក់។ គាត់ធ្វើឯកសារហ្នឹងហើយ ខ្ញុំឃើញ ចុះខ្ញុំនៅផ្លូវ នៅមើលគោនៅនឹងផ្លូវ នៅរោងគោនៅផ្លូវច្រកចេញ។ កាលណានីរសារគាត់ជិះសេះទៅកន្លែងសាលា -- ទៅមន្ទីរស្រុកអ៊ីចឹងទៅ ទៅមួយសន្ទុះថ្ងៃល្ងាចមកដល់វិញឃើញបានស្រោមសំបុត្រមកវិញ ទៅបានសំបុត្រមកវិញមួយ។ ស្អែកឡើងជួនកាលមានកម្មវិធីអីផ្សេងៗក៏មានដែរ ប្រើខ្មោច តាននៗ ហ្នឹងគាត់ស្លាប់នៅកន្លែងហ្នឹងដែរ។ ប្រើ តានន ហ្នឹងឲ្យទៅកាប់រណ្តៅ។ “អូ៎! តែកាប់រណ្តៅមានរឿងទៀតហើយ” នឹកឃើញអ៊ីចឹងបាទ។

[១៤:០៨:៤៥]

**សៈ** តើនៅក្នុងដីពេលដែលលោកដាំដូងនោះ លោកបានឃើញអ្វីដែរ?

**ឆៈ** បាទ រណ្តៅដូងគឺ ជាពិសេសរណ្តៅដូង គឺលើសពទាំងអស់។ កាលណាសព ប៉ុន្តែអត់មែនសពគេសម្លាប់ទេអាហ្នឹង សពគេវៃស្នូរចម្លើយដោយអត់បាយក្រហាយទឹក ស្លាប់នៅតាមគុកនីមួយៗយកទៅដល់ថា ឧទាហរណ៍ស្លាប់ពីរនាក់អ៊ីចឹងហើយ ដល់កាប់រណ្តៅអាក្បែរៗរបងកប់អ៊ីចឹងទៅ។ ស្អែកឡើងខ្ញុំយកដូងទៅដាំលើរណ្តៅ កប់ដូងហ្នឹងហើយច្រុះដំឡូងមី ដាក់ដំឡូងមីពីលើហើយដាំដូងមួយដើម ព្រោះប្រធានគុកគាត់អ្នកប្រើខ្ញុំឲ្យទៅដាំដូងហើយ ដាក់ដំឡូងមីច្រុះពីលើហ្នឹងទៅ។ ដល់ដោតដំឡូងមីហើយបានបន្តិចមើមចុះពេញហ្នឹង។

**សៈ** នៅពេលរំដោះចេញពីគុកនោះ តើលោកបានរាប់ទៅឃើញថាមានចំនួនលលាដ៍ក្បាលចំនួនប៉ុន្មានដែរ?

**ឆៈ** អាហ្នឹងខ្ញុំអត់បានរាប់ទេ កាលដែលគាស់ហ្នឹង គាស់សពហ្នឹងខ្ញុំក៏ទៅគាស់ដែរ។ គាស់ដើម្បី -- គាស់សពហ្នឹងមុនដំបូងអត់មានអង្គការ ឬថ្នាក់ណាឲ្យគាស់តម្កល់ទុកទេ។ សពហ្នឹងគាស់ ទៅមុនដំបូង ទៅជ្រួលច្របល់មួយកំណាត់ឃុំទាំងអស់ហ្នឹង ទៅគាស់ដើម្បីរកធ្មេញមាសឪពុកខ្ញុំ។ ព្រោះឪពុកខ្ញុំធ្មេញមាសគាត់ទាំងអស់ទាំងលើទាំងក្រោមមាសសុទ្ធទាំងអស់។ ហើយដល់ទៅគាស់រកទៅ គេអ្នកគ្រប់គ្នាគេបាន ខ្ញុំក៏អត់មានបានគាស់ដែរ បានទៅមើលទេ សពហ្នឹងក៏អត់បានរាប់ដែរ ប៉ុន្តែចុងបញ្ចប់មានអង្គការនៅថ្នាក់ផ្សេងៗគេមករាប់ហ្នឹង បានចំនួនប្រហែលមួយម៉ឺនជាងនៅក្រាំងតាចាន់រាល់ថ្ងៃហ្នឹងមានមួយម៉ឺនជាង ប៉ុន្តែមួយម៉ឺនប៉ុន្មាន ខ្ញុំអត់បានចាំ។

**សៈ** នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនៅក្នុងគុកនេះ តើលោកធ្លាប់បានឃើញអ្នកមានឋានៈខ្ពស់ផ្នែកនយោបាយមកធ្វើទស្សនកិច្ចនៅក្នុងនឹងគុកហ្នឹងដែរឬទេ?

[១៤:១០:៥៧]

**ផៈ** បាទ ខ្ញុំ ពីឆ្នាំ -- ខ្ញុំអត់អាចចាំឆ្នាំទេ ឃើញគាត់ទៅបានប្រហែលជាម្ដង ក៏ពីរដង ក៏បីដង ក៏មិនដឹង។ ប៉ុន្តែឃើញគាត់ទៅ ៗអត់យូរទេ ទៅមួយភ្លែតទេ ទៅខ្ទង់រយៈកាលក្នុងមួយម៉ោងទេ បើមានអ្នកធំទៅដល់ហើយ គេបញ្ចូលអ្នកទោសហ្នឹងដាក់ក្នុងគុកទាំងអស់ ចូលក្នុងគុកចាក់សោចាក់អីហើយ គេ -- នៅតែកងទ័ពខាងក្រៅទេ ហើយកម្មាភិបាលដើរចុះដើរឡើងតែប៉ុណ្ណឹងទេ។ គាត់ទៅមួយភ្លែត ឡានចេញទៅវិញហើយ។ បាទ អាហ្នឹងឃើញ -- មិនបានឃើញផ្ទាល់ តែអើតតាមជញ្ជាំងមើលតាមជញ្ជាំង។ ប៉ុន្តែចុងក្រោយអាហ្នឹងគេបញ្ចូលខ្ញុំអត់ទាន់ គេថាលែងខ្ញុំ គាត់ទៅចុងក្រោយនេះ គាត់បានយករំពាត់មួយទៅវ៉ៃឆ្អឹងខ្នងខ្ញុំពីក្រោយទៀត វ៉ៃផាច់មួយរំពាត់ពីក្រោយបាទ។

[១៤:១១:៤១]

**សៈ** តើលោកៗអាចបញ្ជាក់ឈ្មោះអ្នកដឹកនាំម្នាក់ ឬក៏ច្រើននាក់ហ្នឹងបានដែរឬទេ?

**ផៈ** បាទ ស្គាល់ខ្ញុំ អត់ស្គាល់ពិតទេ ប៉ុន្តែកងទ័ពហ្នឹងអ្នកប្រាប់ខ្ញុំថា "អ្អែងស្គាល់ទេ?" ថា "អត់"។ "ហ្នឹងហើយ តា១៥ អ្អែងមិនស្គាល់មើល"។ គាត់ប្រាប់ខ្ញុំអ៊ីចឹងបាទ។

**សៈ** បន្ទាប់ពីលោកត្រូវបានដោះលែងពីគុកហ្នឹងហើយ តើលោកអាចភ្លេចរឿងរ៉ាវទាំងអស់ហ្នឹងបានដោយស្រួលដែរឬទេ?

**ផៈ** បាទ ខ្ញុំ -- ពីបញ្ហានៅក្រាំងតាចាន់ ដូចថាមិនចង់នឹកឃើញសោះទាំងអស់រាល់ថ្ងៃ ទោះបីនៅផ្ទះអ៊ីចឹងដែរ។ ជាប់ការងាររកស៊ីបន្តិចបន្តួច មានកាសែតនេះកាសែតនោះទៅសម្ភាសសួរពីនេះ ពីនោះចុះមានឈ្មោះខ្ញុំនៅហ្នឹង។ បើនៅយុវសន្តិភាព គាត់នៅកសាងរៀបចំនៅកន្លែងហ្នឹង បន្តិចមកដល់ៗ ខ្ញុំអត់ចង់ឃើញ តែឃើញ ពេលយប់ឡើងខ្ញុំស្រមៃនឹកឃើញ អ្ហ៎! អញដូចនៅជាប់ក្រាំងតាចាន់អ៊ីចេះ។ ឃើញប្រធានប្រើទៅធ្វើនេះធ្វើនោះអីអ៊ីចឹងទៅ ឬធ្វើអ៊ីចេះធ្វើអ៊ីចុះអី គឺស្រមៃឃើញរហូត។ បានខ្ញុំអត់ចង់ឃើញទេ ហើយអត់ចង់ដឹង អត់ចង់ឮទៀតរាល់ថ្ងៃហ្នឹង។ ថាចង់ចំណែកបុគ្គលខ្ញុំតែឯង ចង់បិទចោលមិនឲ្យដឹង មិនឲ្យឮតែម្ដង ប៉ុន្តែជៀសៗមិនផុត គេចមិនរួចបាទ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោក សយ សែន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា

ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់!

[១៤:១៤:១៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី! សុំទោស លោកដើមបណ្ដឹងរដ្ឋប្បវេណី។ នៅរសៀលនេះ ហើយនិងស្អែកព្រឹក ខ្ញុំសួរលោក។ ខ្ញុំនឹងសួរលម្អិតអំពីអ្វីដែលលោកបានឆ្លើយរួចមកហើយទៅខាងដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើលោកមិនយល់សំណួរខ្ញុំទេ សូមលោកប្រាប់ខ្ញុំ ធ្វើយ៉ាងណាគឺថាឲ្យលោកយល់ឲ្យបានច្បាស់ ហើយនិងឆ្លើយឲ្យបានជាក់លាក់ទៅនឹងសំណួរខ្ញុំពាក់ព័ន្ធនឹងអ្វីដែលលោកបានឮនៅក្រាំងតាចាន់។ ដូច្នេះ សូម -- បើលោកមិនដឹងទេ សូមលោកឆ្លើយថាលោកមិនដឹង។ ឥឡូវនេះ ខ្ញុំចង់ត្រលប់មកនិយាយអំពីរយៈពេលដែលគេចាប់ខ្លួនលោក និងដំណើរការនៃការចាប់ខ្លួនលោក។ ការពីព្រឹកមិញនេះ លោកនិយាយថាពេលគេចាប់ខ្លួនលោក លោកនិយាយអំពីដើមរកា ហើយនិងកន្លែងផ្សេងទៀតដែលចាប់ផ្ដើមដោយពាក្យថា "ត្រពាំង" ហើយខ្ញុំស្ដាប់ជាភាសាបារាំងនោះ ស្ដាប់មិនច្បាស់ទេ។ លោកអាចនិយាយម្ដងទៀតបានទេថា ពេលដែលគេចាប់លោកនោះ គេនាំលោកទៅណាមុនពេលបញ្ជូនលោកមកក្រាំងតាចាន់នោះ?

**លោក សយ សែន៖**

**ឆ៖** បាទ គេនាំចេញពីផ្ទះខ្ញុំមក ចេញពីភូមិស្នាក់នៅភូមិត្រពាំងលាន។ បាទ អ៊ីចឹងគេនាំមកមន្ទីរអង្គរកា គេថាមកនៅកន្លែងយុវជនអង្គរកា។ ដល់មកដល់អង្គរកាហ្នឹង កន្លែងហ្នឹងកន្លែងស្នាក់ការរបស់គុករបស់ តាឃន នៅអង្គរកាហ្នឹង។ មកដល់អង្គរកា គេបញ្ជូនខ្ញុំបកមកត្រពាំងព្រីង កន្លែងគុកតាកិល។ ដល់កន្លែង តាកិល ហ្នឹងយប់ឡើងគេបញ្ជូនមកក្រាំងតាចាន់ទៀត។ ទាំងអស់វាមានពីរដំណាក់បញ្ជូនមកបាទ។

[១៤:១៦:២៦]

**ស៖** នៅអង្គរកា លោកមានបានឃើញអ្នកទោសផ្សេងទៀតដែលគេចាប់ខ្លួនដូចលោកទេ?

**ឆៈ** បាទ បានឃើញ។ ឃើញជាប់នៅហ្នឹង ពេលយប់នោះជាប់មួយខ្សែនៅហ្នឹង ប្រហែលជាអាចមិនច្រើនទេ ទាំងអង្គរកាហ្នឹងខ្ពង់ប្រហែលប្រាំមួយប្រាំពីរនាក់ ហើយក៏១០នាក់ក៏មិនដឹង ខ្ញុំមិនបានអាចរាប់បានទេ។ ដល់ខ្ញុំជាប់ហ្នឹងបានមួយយប់ ស្អែកឡើងបានគេបញ្ជូនមកក្រាំងតាចាន់បាទ។

**សៈ** គេបញ្ជូនលោកទៅក្រាំងតាចាន់ហ្នឹងដោយរបៀបណាលោក? គេឲ្យលោកដើរទៅ ឬក៏គេមានឡាន មានម៉ូតូអីដឹកលោកទៅ?

**ឆៈ** បាទ អត់មានឡាន មានម៉ូតូទេ សម័យមុន គឺអត់មាន មានដើរគេចង។ ខ្ញុំពីរនាក់មិនមែនតែឯង មានពីរនាក់។ មានម្នាក់ទៀត ខ្ញុំអត់ស្គាល់ ប៉ុន្តែមិនដឹងអាសយដ្ឋានគាត់នៅណាក៏អត់ដឹង ប៉ុន្តែចងខ្សែតែមួយទេ។ ខ្ញុំដើរមុខគេ ម្នាក់ទៀតដើរពីក្រោយខ្ញុំ ប៉ុន្តែចងខ្សែតែមួយពីរនាក់ហ្នឹង។

**សៈ** មានអ្នកយាមនាំលោកទៅទេ ឬក៏មានឈ្លបអីនាំលោកទៅទីនុំងទេ?

[១៤:១៧:៥៥]

**ឆៈ** បាទ ទៅដល់កន្លែងស្នាក់ការ ដូចអង្គរកា ហើយត្រពាំងព្រីងផ្ទះ តាកិល ហ្នឹងគឺអត់មានឈ្លបទេ គឺសុទ្ធកងទ័ពពីកន្លែងហ្នឹងទៅយកមក ពីកន្លែងក្រាំងតាចាន់ហ្នឹងចុះទៅយកផ្ទាល់ខ្លួនឯង។ គឺទោះបីនាំអ្នកទោសមកដាក់នៅក្រាំងតាចាន់ហ្នឹង អ្នកឈ្លបខាងភូមិឃុំនាំមកក៏បានមកត្រឹមរបងទី១ខាងក្រៅ -- អ៎! របងទី៣ ខាងក្រៅ។ របងទី៣ ខាងក្រៅ មកដល់ត្រឹមហ្នឹងមានសញ្ញាចូលកន្លែងចូលកន្លែងមានខ្លោងទ្វារកន្លែងហ្នឹង មានសញ្ញាជួង គេយិនឡានកញ្ចាស់មួយនៅហ្នឹង ហើយដែកកញ្ចាស់មួយដើម ៗ គេត្រូវវ៉ៃជួយម៉ឺង១ទៅ បានកងទ័ពនៅក្នុងទៅទទួលពីក្រៅមក។ រឿងថាអ្នកឈ្លបភូមិឃុំនាំចូលដល់ហ្នឹង គេអត់ឲ្យចូលទេ ចូលបានត្រឹមរបងក្រៅ។ របងក្រៅ វ៉ៃជួងហើយអ្នកកងទ័ពនៅក្នុងចូលទៅយកមក ទៅនាំយកពីរបងខាងក្រៅមក។ គឺអ្នកនាំមកបកទៅវិញ មកត្រឹមហ្នឹងបកទៅវិញ អត់មានបានចូលទេ។

**សៈ** នៅពេលលោកចូលទៅដល់ក្រាំងតាចាន់ នៅខាងក្នុងមន្ទីរហ្នឹង គឺខ្ញុំសំដៅដល់ក្នុងរបងខាងក្នុងតែម្តង តើគេធ្វើយ៉ាងម៉េចដែរ? គេមានថតរូបលោក ឬក៏មានអីធ្វើទេ ពេលលោកចូលទៅដល់ភ្លាមនោះ?

**ឆៈ** បាទ អត់មានថតទេ ពីសម័យហ្នឹងនៅហ្នឹង ខ្ញុំអត់ដែលមានឃើញថតទេ។ ទៅដល់គេទោះបីថ្នាក់ណាក៏ដោយ តែនាំទៅដល់ហើយ គេត្រូវបញ្ចូលដាក់ក្នុងគុក គេអត់មានសួរយើងទេ។ ទៅដល់គេដាក់ខ្នោះដៃហើយ គេចាក់សោហើយចេញមកក្រៅបាត់ គេនៅនិយាយគ្នាក្រៅ អត់មានសួរយើង

ដល់ពីរបីថ្ងៃបានគេហៅយើងសួរបាទ។

[១៤:១៩:៤៧]

**ស៖** នៅពេលលោកចូលទៅដល់ទុំង តើលោកដឹងថាមានការប្រគល់ឯកសារពីខាងអ្នកឃាម ឬក៏ឈ្លបដែលនាំលោកទៅហ្នឹង ប្រគល់ទៅឲ្យបុគ្គលិកនៅក្រាំងតាចាន់ទេ?

**ឆ៖** បាទ អាហ្នឹងខ្ញុំអត់បានដឹងទេ ព្រោះដឹងតែគេនាំមកហើយបញ្ចូលក្នុងនោះ អត់បានដឹងឯកសារអី យ៉ាងណាយ៉ាងណីក៏ខ្ញុំអត់បានដឹង អាហ្នឹងអត់។

**ស៖** បន្ទាប់ពីថ្ងៃទី១៧ មេសា ៧៥ លោកដឹងទេថា មានគេបញ្ជូនមនុស្សពីគុកអង្គរកាមកក្រាំងតាចាន់?

**ឆ៖** បាទ អាហ្នឹងបានដឹង។ ដឹងសួរ ឧទាហរណ៍ថា ចូលមួយយប់ហ្នឹងថ្ងៃហ្នឹង ឧទាហរណ៍ថាចូលភ្ជាប់ជាមួយខ្ញុំអ៊ីចឹង ខ្ញុំសួរថា “មកពីណា?” ថា “មកពីអង្គរកា” ហើយថា “ផ្ទះនៅឯណា?” ថា “នៅ ដូចស្រែរនោង នៅឯណាដូចថាឧត្តមសូរិយា នៅអ៊ីចឹងទៅ”។ គេឆ្លើយចេះតែឆ្លើយអ៊ីចឹងទៅណាអង្គរកាអីអ៊ីចឹងទៅ។ សួរបានប៉ុណ្ណឹងឯង។

**ស៖** នៅក្រាំងតាចាន់ តើមានអ្នកទោសដែលមកពីឃុំជិតៗហ្នឹង ឬក៏មានអ្នកទោសមកពីឃុំឆ្ងាយៗនៅស្រុកត្រាំកក់ទុំងដែរ?

**ឆ៖** បាទ អានេះបើតាមដែលខ្ញុំមើលឃើញ ហើយអាចនៅស្គាល់គាត់ ហើយបានសួរគាត់ព្រោះខ្ញុំអាចជញ្ជូនសម្ភារៈចេញពីមុខគាត់អីហ្នឹង ពីលាមកអីនាយ ទឹកនោមទឹកអីទាំងអស់ហ្នឹង សួរគាត់អ៊ីចឹងលួចសួរគាត់ទៅ គាត់ប្រាប់ឆ្ងាយៗ។ បើតាមដែលខ្ញុំបានដឹង ឆ្ងាយអត់មាននៅស្រុកត្រាំកក់ហ្នឹងទេព្រោះអានេះ បើខ្ញុំអាចដឹងរបស់ខ្ញុំតែម្តង ដឹងដែលអាចកងទ័ពហ្នឹងប្រាប់ថា របស់ភូមិភាគបាទ គុកហ្នឹងគុករបស់ភូមិភាគ។

[១៤:២២:០៥]

**ស៖** បើខ្ញុំស្តាប់មិនច្រឡំទេ លោកឆ្លើយថា ក្រាំងតាចាន់ជាមន្ទីរសន្តិសុខថ្នាក់ស្រុក។ តើអ៊ីចឹងមែនទេ? លោកចង់និយាយថាមន្ទីរហ្នឹងជារបស់ស្រុក។ អ៊ីចឹងទេ?

**ឆ៖** បាទ អាហ្នឹងវារបស់ស្រុក១០៥ ប៉ុន្តែបើតាមអ្នកដែលជាប់ វាមានតាំងពីតានី ទូកមាស កំពត អ្នកយកមកសម្លាប់ តាកែវ កណ្តាល ស្ទឹ។ បានថា អានេះវា -- ដល់ហើយវាកងទ័ពគ្នាវាប្រាប់ថាប្រាប់ខ្ញុំថា អាហ្នឹងរបស់ភូមិភាគ បាទ។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកបានរៀបរាប់អំពីកន្លែងទីតាំង ហើយនិងអគារនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់។ ឥឡូវនេះ ខ្ញុំចង់សួរលោក ថាតើអគារដែលលោកបានរៀបរាប់មានរបងមានកន្លែងដែលគេឃុំអ្នកទោស កន្លែងសួរចម្លើយជាដើមហ្នឹង។ តើកន្លែងអស់ហ្នឹងមានការប្រែក្លាយទេ មានន័យថា ក្រោយពីថ្ងៃ១៧ មេសា ៧៥មក គេយកទៅធ្វើស្អីផ្សេង ឬមួយក៏ពេលដែលលោកនៅកន្លែងហ្នឹង គឺអត់មានការប្រែប្រួលអីទេ អគារហ្នឹងគឺនៅតែដដែល មានន័យថាកន្លែងគេឃុំអ្នកទោសនៅតែឃុំអ៊ីចឹង កន្លែងគេសួរចម្លើយនៅតែសួរចម្លើយដដែល?

**ឆ៖** បាទ អត់ប្រែទេ នៅដដែលបាទ នៅដដែលអត់មានប្រែទេនៅដដែល។ មានតែបន្ថែម។ គុកកាលឆ្នាំខ្ញុំទៅនៅដំបូង គឺមានគុកតែពីរទេ ដល់មកឆ្នាំ៧៥ ធ្វើគុកថែមពីរទៀត បានគុកបួន។

**ស៖** នៅពេលដែលលោកនិយាយថា មានអគារពីរមុនឆ្នាំ៧៥ ហើយនិងអគារពីរទៀតក្រោយឆ្នាំ៧៥ លោកសំដៅទៅលើកន្លែងគេសម្រាប់អ្នកទោស ឬក៏សំដៅលើកន្លែងផ្សេង?

[១៤:២៤:២៧]

**ឆ៖** បាទ សំដៅទៅលើអ្នកទោស ព្រោះគុកធ្វើហើយ ធ្វើគុកតែម្តងហ្នឹង វាយត្បាញលួសធ្វើដូចគុកពីមុនមក ដឹងតែធ្វើកន្លែងគុក។ ខ្ញុំដឹងថាធ្វើគុក ព្រោះគេឲ្យអ្នកទោសធ្វើទាំងអស់បាទ។

**ស៖** សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញជូននូវប្លង់មួយដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយសូមបង្ហាញនៅលើអេក្រង់កុំព្យូទ័រ។ នេះជាប្លង់ដែលធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយផ្អែកទៅលើសក្ខីកម្មរបស់លោកដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅពេលដែលទៅដល់ក្រាំងតាចាន់ ដើម្បីឲ្យខ្ញុំអាចបង្ហាញទីតាំងមួយចំនួន ឧទាហរណ៍ដូចជាខ្លោងទ្វារ ប៉ុស្តិ៍យាម កន្លែងឃុំឃាំង កន្លែងសួរចម្លើយ កន្លែងសម្លាប់មនុស្សជាដើម។ ប្លង់នេះ គឺមានលេខ D125/220.37 ។ ខ្ញុំសូមបញ្ជាក់លេខម្តងទៀត គឺឯកសារ D125/220.37។ ឯកសារនេះ គឺមានតែមួយទំព័រទេ ដូច្នេះខ្ញុំមិនបាច់ប្រាប់ ERN ទេ។ ដូច្នេះលោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់ឯកសារក្រដាសជូនដើមបណ្តឹងរដ្ឋប្បវេណី និងស្នើសុំការអនុញ្ញាតបញ្ចាំងឯកសារនេះ នៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៤:២៦:១៣]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្វាងលេ៖**

**ស៖** ខ្ញុំសូមអានផ្នែកខាងលើ នៅពេលដែលលោកកំពុងតែអាននេះ គឺឧបសម្ព័ន្ធ "ឃ" ប្លង់មន្ទីរសន្តិសុខក្រាំងតាចាន់ ដែលត្រូវបានចងក្រងពីព័ត៌មានដែលផ្តល់ឲ្យដោយសាក្សី សយ សែន។ មិនមាននៅសល់ស្លាកស្នាមអគារទេ។ នៅលើប្លង់នេះ យើងឃើញមានដីមួយដែលមានប្រហែលជាទទឹងនោះ -- បណ្តោយគឺ៩០ម៉ែត្រ ហើយទទឹង៩០ម៉ែត្រ -- បណ្តោយ៩០ម៉ែត្រ ទទឹង៧០ម៉ែត្រ។ ដូច្នេះលោកមើលឃើញហើយ ហើយលោកអាចបញ្ជាក់បានទេពីចំណុចនេះ?

**លោក សយ សែន៖**

**ឆ៖** អាហ្នឹងរបងៗក្នុង នេះហៅថារបងក្នុង របងក្នុងហ្នឹងរបងទី១ អាហ្នឹង។ បណ្តោយវា៩០ម៉ែត្រ ទទឹង៧០ម៉ែត្រហ្នឹងវា ពីមុនដីធំណាស់ ប៉ុន្តែមកប្រជាជនឆ្នាំរំដោះ ឆ្នាំ៧៩ហ្នឹង គាត់ទាមទារយកអស់ទៅ បានថាពីមុនដីធំមែនទែន ដីខ្សែក្រវាត់មុនធំណាស់ បាទ។ នេះនៅសល់ដី តែតូចៗកន្លែងក្រាំងតាចាន់ ប៉ុន្តែដីកន្លែងកប់សពហ្នឹងនៅភូមិខាងលិចមួយកន្លែងទៀត នៅខាងត្បូងហ្នឹងមួយកន្លែងទៀត។ នេះដីៗតួសម័យបច្ចុប្បន្នរាល់ថ្ងៃនេះបាទ។

**ស៖** នៅលើប្លង់ហ្នឹង យើងឃើញមានទ្វារពីរ ចូលទៅខាងក្នុង។ មួយគឺខាងលិច ហើយបន្ទាប់មកគឺថាយើងមាននូវប៉ុស្តិ៍យាមនៅជាប់ហ្នឹង។ លោកអាចប្រាប់បានទេ ថាអ្នកដែលគេចាប់ខ្លួនហ្នឹងចូលៗហ្នឹង ចូលតាមខាងណាដែរ? ខាងកើត ឬក៏ខាងលិច?

[១៤:២៨:២០]

**ឆ៖** បាទផ្លូវពីរហ្នឹង គឺអត់កំណត់ទេ ប៉ុន្តែភាគច្រើនមកពីកើតច្រើនជាង ភាគតិចមកពីលិចតិចជាង។ បើមកពីលិច មានខាងលិច មានក្លោងទ្វារមួយ គឺប្លង់គាត់ត្រូវរបស់គាត់ហើយ មានប្លង់ -- ពីលិចមានក្លោងទ្វារមួយ មានជួងសញ្ញានៅកន្លែងហ្នឹង វាអត់សូវមានអ្នកនៅទេពីលិច ច្រើនតែដាក់ជួង។ ដាក់ជួង កាលណានាំតាមភូមិឃុំមក មកដល់ហ្នឹង គឺវ៉ៃសញ្ញាជួង យប់ឡើងវ៉ៃសញ្ញាជួង កងទ័ពក្នុងទៅយក ទៅទទួលអាហ្នឹង។ ហើយពីកើតក៏អ៊ីចឹងដែរ ពីកើតនៅយាមតែពេលថ្ងៃទេ តែយប់អត់សូវយាមទេ មកយាមនៅកន្លែងគុកទាំងអស់។ ពីកើតគេដាក់សញ្ញាជួងដូចគ្នា អាខ្លោងទ្វារពីកើត។ ទៅដល់អ្នកនាំពីតាមមូលដ្ឋានមក វ៉ៃជួងពីខាងកើត។ វ៉ៃខាងកើត វ៉ៃម៉ឹងអ៊ីចឹង អ្នកខាងក្នុងទៅទទួល បាទ។

**ស៖** ដូច្នេះយើងឃើញក្នុងប្លង់នេះ គឺមានប៉ុស្តិ៍យាមបួន គឺពីរនៅខាងកើត -- ផ្លូវចូលខាងកើត

ខាងលិច ហើយនៅកណ្ដាលបួង់ហ្នឹង យើងឃើញមានប៉ុស្តិ៍យាមពីរទៀត។ លោកអាចចង្អុលបង្ហាញបាទទេថា ប្រធានក្រាំងតាចាន់ តាអាន់ ហ្នឹង ក្រោយឆ្នាំ -- ក្រោយខែមេសា ៧៥ ហ្នឹង គាត់ៗនៅកន្លែងណាដែរ តាអាន់ ហ្នឹង?

[១៤:២៩:៤២]

**ឆ៖** បាទខ្ញុំអត់បានដឹងទេ ពីៗឆ្នាំគាត់នៅ គ្រាន់ដឹងតែថាឆ្នាំគាត់ទៅដូរពីប្រធានមន្ទីរមុន។ ប្រធានមន្ទីរកាលខ្ញុំចូលទៅនៅដំបូងហ្នឹងវា តាឆេន។ តាឆេន គាត់កាន់កាប់មន្ទីរហ្នឹងមុនគេបង្អស់ ហើយពីតាឆេន មកបានដូរមក តាអាន់។ តាអាន់ ហ្នឹងមកនៅក្រោយខ្ទង់ឆ្នាំ ខ្ញុំមិនអាចចាំទេ ខ្ទង់រំដោះហើយគាត់មកនៅរំដោះហើយ។ តាឆេន ហ្នឹងគាត់ដូរ ដូរក៏ដូរក្នុងនាមរំដោះដែរ។ ប៉ុន្តែមានការងារច្រើនច្របូកច្របល់ឃើញគ្នាគាត់មកមូលគ្នាទាំងអស់ មកទាំងអស់។ ឃើញមកមូលគ្នាទាំង តាភី, តាឆេន, តាអាន់ អីមកមូលគ្នាមួយកន្លែងកាលណាមានការងារច្របូកច្របល់ច្រើនដូចឆ្នាំ៧៥ គេរំដោះហ្នឹងមនុស្សបញ្ជូលមក គាត់មកមូលគាត់គ្នាច្រើនគាត់។ ប៉ុន្តែមកតែមួយថ្ងៃហ្នឹង ល្ងាចបន្តិចគាត់បែកគ្នាបាត់ហើយ នៅតែមន្ទីរនៅតែកន្លែង តាអាន់ ហើយនិងកងទ័ពគាត់នៅហ្នឹងទេ។

**ស៖** តើ តាអាន់ ហ្នឹងគាត់មានមន្ទីរអីរបស់គាត់ផ្ទាល់ខ្លួនទេ?

**ឆ៖** អត់ទេ គាត់មានតែកន្លែងគាត់មួយនៅជិតកន្លែងគេដាក់ខ្ញុំ កន្លែងគុកខ្ញុំហ្នឹង គាត់នៅពីមុខខ្ញុំហ្នឹងតែម្តង នៅពីមុខគុកខ្ញុំហ្នឹងតែម្តង ទល់នឹងពីមុខគុកខ្ញុំហ្នឹងតែម្តង។

**ស៖** លោកបានរៀបរាប់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា មាននាក់វាយអង្គុលីលេខ។ ចុះតើអ្នកវាយអង្គុលីលេខហ្នឹងគាត់មានមន្ទីរ ឬក៏មានការិយាល័យរបស់គាត់ទេ? នៅក្នុងបរិវេណគុកហ្នឹង គាត់ធ្វើការនៅកន្លែងណាដែរ? លោកអាចចង្អុលបង្ហាញបានទេ អ្នកវាយអង្គុលីលេខហ្នឹង?

**ឆ៖** បាទ អ្នកវាយអង្គុលីលេខហ្នឹងគាត់កងទ័ពដូចគ្នា ប៉ុន្តែសម័យហ្នឹងគាត់ចេះជាងគេ។ ដល់ចេះទៅ គាត់ចេះអក្សរពីអក្សរច្រើនទៅ គាត់ ប្រធានមន្ទីរហ្នឹងឲ្យ ឌុចតូច នេះវាយអង្គុលីលេខ។ អ៊ីចឹងកន្លែងហ្នឹងវាមាន ឌុច ពីរ – ឌុច អនុប្រធានមួយ, ឌុចតូច ហ្នឹងមួយទៀត។ ឌុចតូច ហ្នឹងវាយអង្គុលីលេខបាទ។ គ្រាន់តែវាយជាប់នៅកន្លែង -- គាត់វាយនៅកន្លែង តាអាន់ ហ្នឹងតែម្តង ជាប់កន្លែងខ្ញុំហ្នឹងតែម្តង ជាប់នឹងកន្លែងគុក ពីមុខគុកខ្ញុំ ដីប្រហែលជាពីរម៉ែត្រពីកន្លែងគុកខ្ញុំ។

[១៤:៣២:០៧]

**ស៖** តើលោកអាចចូលទៅដល់កន្លែងដែល ឌុចតូច គាត់វាយអង្គុលីលេខហ្នឹងបានទេនៅក្នុង

មន្ទីរហ្នឹង? ជាកន្លែងដែលបិទជិត ឬក៏គេអាចឲ្យលោកចូលបានដែរ? មានន័យថាលោកមានសិទ្ធិចូលទៅដល់កន្លែងគាត់មើលគាត់វាយអង្គុលីលេខហ្នឹងបានដែរ ឬក៏កន្លែងហ្នឹងគេបិទជិតតែម្តង អត់មានឲ្យអ្នកណាចូលបានទេ?

**ឆ៖** បាទ បានទាំងអស់កន្លែង បើកន្លែងពួកគាត់ធ្វើការនៅហ្នឹង ខ្ញុំចូលបានទាំងអស់ ព្រោះដើម្បីខ្ញុំចូលបាន ព្រោះខ្ញុំអ្នកខាងបោសសម្អាត បោសសម្រាម បោសអីជូត បោសតុកៅអីហ្នឹងរបស់គាត់ហ្នឹង គឺខ្ញុំបោសបានទាំងអស់ ចូលបានទាំងអស់ បាទ។

**ស៖** លោកឆ្លើយថាកន្លែងគាត់ធ្វើការហ្នឹងមិនឆ្ងាយពីកន្លែងលោកប៉ុន្មានទេ។ អ៊ីចឹង នៅពេលដែលលោកចូលទៅដល់ក្រាំងតាចាន់ ក្នុងផ្ទះណា ឬក៏អគារណាដែរដែលលោកគេឃុំលោកនៅហ្នឹង?

[១៤:៣៣:២៣]

**ឆ៖** មុនដំបូងខ្ញុំចូលទៅដល់នៅ កាលហ្នឹងមានគុកតែពីរ សម័យឆ្នាំ៧៤ មានគុកតែពីរទេ មានគុកពីរ ខ្ញុំនៅគុកខាងលិច។ ទាល់តែយូរឆ្នាំដែរ យូរខែដែរ បានខ្ញុំមកនៅគុកកើត ធ្វើគុកកើតមកហើយមួយទៀតបានមកនៅគុកថ្មីកើតមក។ គុកថ្មីកើតហ្នឹងនៅគុកកណ្តាលដែលជាប់កន្លែង តាអាន់ ជាប់កន្លែង តាអាន់ ហ្នឹងតែម្តង បាទ។

**ស៖** តើអគារនៅខាងកើតហ្នឹងជាសម្រាប់ជាកន្លែងសម្រាប់អ្នកទោសស្រាលឬក៏អ្នកទោសធ្ងន់?

**ឆ៖** បាទ កន្លែងខ្ញុំជាប់ហ្នឹង វាពីរខ្សែ។ ខ្សែជើងត្បូង១ ខ្ញុំជាប់ខាងត្បូង មួយជួរខាងត្បូងហ្នឹងគឺគេលែងអ្នកធ្វើការ១ ប៉ុន្តែខ្ញុំនៅចុងផុតគេ ចុងផុតក្បែរមាត់ទ្វារតែម្តង។ កាលណាតែដោះខ្នោះខាងក្រៅចេញ ដោះរនុកចេញក្រៅហូតខ្វាកមក ដល់ខ្ញុំហ្នឹង ដោះខ្នោះរួចចេញតែក្រៅ គាត់ត្រូវការយប់ព្រលប់អីគឺហូតខ្ញុំចេញក្រៅមុនគេ បាទ។

**ស៖** លោកបានរៀបរាប់ថា មានផ្ទះបួនសម្រាប់ឃុំអ្នកទោស។ លោកអាចរៀបរាប់អំពីសម្ភារៈដែលគេសាងសង់ផ្ទះហ្នឹងទេ? ហើយមានការសាងសង់អគារផ្សេងគ្នាទេសម្រាប់អ្នកទោសស្រាល និងអ្នកទោសធ្ងន់នោះ?

[១៤:៣៥:០៥]

**ឆ៖** បាទ អត់ទេ ដូចតែគ្នា ដូចគ្នាទាំងអស់។ ក្បាញល្អស រ៉ៃក្តារ ក្បាញល្អសលើក្រោម ដូចគ្នាទាំងអស់។ គ្រាន់តែទោសស្រាល គេលែងឲ្យធ្វើការ មិនថាស្រាលទេ វាខ្លះជួនកាលត្រូវការគេ ផែនការធ្លាក់ពីលើទៅ អង្គការពីលើទៅត្រូវតែកម្ទេច កម្ទេចដូចតែគ្នាអ្នកចេញខាង។ មើល៍ តាននខ្មោច តានន

នោះ កំពុងតែធ្វើការជាមួយខ្ញុំ នៅដើរ តានន គាត់ខាងដើរដាក់មង មងត្រី។ ដើរដាក់មងត្រីយកទៅឲ្យប្រធានមន្ទីរ ព្រលឹមឡើងមកពីសាមងវិញ តាចេង នោះគាត់ហៅ "អ៊ីតា! តាឯងទៅកើតមួយភ្លែតទៅ!" គាត់ថាឲ្យទៅកើតមួយភ្លែត គាត់បែរមកប្រាប់ខ្ញុំថា "អញទៅមុនអ្នែងហើយ"។ គ្រាន់តែថា ទៅមុនអ្នែង មួយសន្ទុះឮសូរភូសនៅនោះគាត់បាទ។ អាហ្នឹងបានថាស្រាលដូចធ្ងន់ ធ្ងន់ដូចស្រាល ព្រោះកន្លែងនោះវាអត់មានប្រកាន់ឋានៈផង។

[១៤:៣៦:០១]

**ស៖** តើលោកដឹងទេ ថាខ្មែរក្រហម ឬកម្មាភិបាលហ្នឹង បែងចែកយ៉ាងម៉េចរវាងអ្នកទោសស្រាល និងអ្នកទោសធ្ងន់នោះ? គាត់មានលក្ខខណ្ឌយ៉ាងម៉េច ដើម្បីចាត់ទុកថា អ៊ូ! អ្នកទោសនេះជាអ្នកទោសស្រាល អ្នកទោសនេះជាអ្នកទោសធ្ងន់អីចឹង។ តើលោកដឹងទេ?

**ឆ៖** បាទ អត់បានដឹងទេអាហ្នឹង បាទ។

**ស៖** កាលពីព្រឹកមិញលោកបានឆ្លើយថា មុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ អ្នកទោសចូលក្រាំងតាចាន់ហ្នឹងគឺ មានពីរនាក់ បីនាក់ ឬក៏ប្រាំនាក់អីអីចឹង។ ក៏ប៉ុន្តែក្រោយរំដោះមក គឺច្រើនណាស់ មានអ្នកទោសចូល ជួនកាលដល់១០ ដល់២០អីចឹង។ តើលោកអាចប្រាប់បានទេ ថាក្នុងរយៈពេលប៉ុន្មានថ្ងៃ ឬប៉ុន្មានខែ ក្រោយពី១៧ មេសា ៧៥មកមានអ្នកទោសកើនឡើងច្រើននៅក្រាំងតាចាន់?

**ឆ៖** បាទ អាហ្នឹងកើនឡើងពីឆ្នាំរំដោះហើយបានកើន អាហ្នឹងឧទាហរណ៍ថា គេយកពីភ្នំពេញរំដោះពីភ្នំពេញ ថាយកឈ្លើយសឹក ដូចថាទាហានលន់ នល់ អីចឹង គេហៅឈ្លើយសឹក។ ហើយប្រជាជន១៧ហ្នឹង គេថាប្រជាជន១៧ហ្នឹង គេថានៅក្នុងសុទ្ធតែស័ក្តិ២ ស័ក្តិ៣ យកទៅច្រើន ជំនាន់ហ្នឹងច្រើន។ ហើយបើជំនាន់ខ្ញុំជាប់ហ្នឹង ពីសម័យហ្នឹង សង្គ្រាមគេធ្វើរណសិរ្សរួបរួមជាតិកម្ពុជា កន្លែងហ្នឹងគេថាពាក់ព័ន្ធពីអាខ្លះ ឪពុកនៅខាងក្នុង ឧទាហរណ៍ដូចខ្ញុំផ្ទាល់អីចឹង ពាក់ព័ន្ធឪពុកនៅខាងក្នុង កូននៅខាងក្រៅ។ ពាក់ព័ន្ធ -- គេថា ទាក់ទងនៅខាងក្នុងអីចឹង គិញ សេ.អ៊ី.អា របស់ខ្មាំងអីចឹង គេនិយាយអីចឹង ប៉ុន្តែថាជំនាន់ហ្នឹងវាតិច។ ហើយដល់ជំនាន់រំដោះហើយ អាហ្នឹងវាទូទៅ ភាគច្រើនឲ្យតែពួក១៧មេសាគឺថា ពួកហ្នឹងច្រើនឋានៈ គេសុទ្ធតែទាហាន។ គេទៅដល់ គេសួរថា "អ្នកឯងពាក់សក្តិប៉ុន្មាន? ឬឋានៈប៉ុន្មាន?" គេសួរតែអីចឹង អត់មានសួរអីផង។ តាមខ្ញុំស្តាប់មើល សួរតែប៉ុណ្ណឹង។

[១៤:៣៨:២១]

**ស៖** តើលោកដឹងថា ជាអតីតទាហានយោធា លន់ នល់ ឬក៏អ្នក១៧មេសាហ្នឹង យ៉ាងម៉េចបាន

លោកដឹង? លោកបានពិភាក្សា ឬក៏ជជែកគ្នាជាមួយអ្នកទោសទាំងហ្នឹងផ្ទាល់តែម្តង ឬក៏លោកទទួលបានព័ត៌មានពីកម្មាភិបាល ឬក៏អ្នកយាមគុកនៅក្រាំងតាចាន់?

**ឆ៖** បាទ បានទទួលពីអ្នករងគ្រោះផង ហើយអ្នកកងទ័ពហ្នឹងផង។ កងទ័ព វាដូចថាកងទ័ពគាត់ ពួកគាត់បីបួននាក់ហ្នឹងថារាងទុកចិត្តខ្ញុំ ក៏លេងសើចជាមួយខ្ញុំច្រើនអ៊ីចឹង យ៉ាងម៉េចមួយយ៉ាងម៉េចពីរ ហើយអាចប្រាប់ខ្ញុំបានខ្លះដែរ បាទ។

**ស៖** ទាហាន -- កងទ័ពណាដែលថា លោកនិយាយលេងច្រើននេះ នៅក្រាំងតាចាន់ហ្នឹង ដែលថាលោកបាននិយាយលេងច្រើន ហើយគេប្រាប់លោកហ្នឹង ជាកងទ័ពណាដែរ?

**ឆ៖** បាទ ស៊ីម ជួនកាល ស៊ីម ប្រាប់អ៊ីចឹងហើយ ជួនកាល បងខុចតូច អ៊ីចឹងទៅ។ អត់ពីបងខុចតូច មាន ស៊ាន់, អត់ ស៊ាន់, សាំង អីអ៊ីចឹងទៅ គាត់ចេះតែប្រាប់ខ្ញុំទៅ ដូចថាប្រើបានអ៊ីចឹង ប្រើទៅនេះទៅនោះបាន គាត់ទុកជាបាយកក បាយក្តាំងទុកឲ្យខ្ញុំហូបបានៗខ្លះអ៊ីចឹង នៅកន្លែងគាត់អ៊ីចឹងគាត់ប្រាប់ទៅ។ បាទ ចេះតែណែនាំប្រាប់ខ្ញុំខ្លះៗទៅ។

[១៤:៣៩:៥៦]

**ស៖** អម្បាញ់មិញនេះលោកឆ្លើយថា គេដូរលោកពីផ្ទះឃុំហ្នឹងបីបួនដង។ អ៊ីចឹងមានន័យថាលោកអាចស្នាក់នៅកន្លែងផ្សេងក្រៅពីផ្ទះដែលគេឃុំអ្នកទោសហ្នឹងមែនទេ?

**ឆ៖** ផ្ទះអ្នកទោសដូចគ្នាៗ គុកដូចគ្នាៗ ប៉ុន្តែខ្ញុំមកនៅឯកើតមក មកនៅឯកើតគេអ្នកលែងអ្នកធ្វើការៗ ឲ្យនៅដីខាងកើត កើតជាប់កន្លែងគុកប្រធានមន្ទីរហ្នឹងតែម្តង។ អ្នកលែងធ្វើការហ្នឹងបីបួនដប់នាក់ហ្នឹងនៅជាប់ហ្នឹង ប៉ុន្តែខ្ញុំជាប់ចុងផុតជាងគេ បើនិយាយឲ្យខ្លីទៅខ្ញុំអ្នកធ្វើទឹកត្នោតជូរឲ្យគាត់ គាត់ឲ្យជាប់ខាង។ ហើយយប់ឡើង គាត់លែងខ្ញុំឲ្យចុះទៅឡើងត្នោតជូរហើយ ទៅចុះលលកជាមួយគាត់។ មករវៃ ដើររវៃ គេដាក់យ៉ាន់កង់ពីមុនដាក់ឌីណាម៉ូកង់ ហើយដាក់រវៃៗយ៉ាន់កង់ហើយដាក់ឌីណាម៉ូមកដាក់នៅខ្នងហើយស្ពាយ គាត់ចេះតែដើរផ្លុះដើរបាញ់លលកជាមួយខ្ញុំនៅពេលយប់ហ្នឹង បាញ់ស្ពាប្រធាន។ បាទបានលលកហ្នឹងពេលយប់ហ្នឹងម្តង ប្រើខ្ញុំឲ្យទៅដាក់ត្នោតជូរទាំងយប់ បានន័យថាគាត់ទុកឲ្យខ្ញុំនៅក្រៅគេ នៅជាប់ផុតពីគេ។

[១៤:៤១:២២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ។ ខ្ញុំឃើញថាពេលវេលាដូចជាទៅមុខហើយលោកប្រធាន ដូច្នេះតើខ្ញុំ--

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ។ ហើយទី២ សូមរំឭក និងជម្រាបតំណាងសហព្រះរាជអាជ្ញា ជ្រាបថា ក្រុមសហព្រះរាជអាជ្ញាមានពេល៣០នាទីទៀត បន្ទាប់ពីចូលមក ពុំមែនឆ្លងទៅដល់ថ្ងៃស្អែក ដូចលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងនោះទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំសូមការបំភ្លឺលោកប្រធាន។ ខ្ញុំអត់សូវយល់អំពីអ្វីដែលលោកប្រធានបានលើកឡើង។ ខ្ញុំគិតថា ដើមបណ្ដឹងរដ្ឋប្បវេណី ហើយសហព្រះរាជអាជ្ញាមានរយៈពេល១ថ្ងៃដើម្បីចោទសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះ ហើយមេធាវីការពារក្ដីក៏មានរយៈពេល១ថ្ងៃពេញដែរ។ ដូច្នេះ ខ្ញុំគិតថាថ្ងៃនេះ ខ្ញុំអាចបន្តទៅដល់ម៉ោងបួន ហើយស្អែកព្រឹកពេញមួយព្រឹកតែម្ដង ខ្ញុំសួរបន្តទៀតលោកប្រធាន តើអីចឹងមែនទេ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៣:៥៩]

**ប្រធានអង្គជំនុំ៖**

កែសម្រួលឡើងវិញ។ អីចឹងខ្ញុំប្រហែលជាភ័ន្តច្រឡំដោយសារខ្ញុំខ្លួនឯងទេ តាមពិត២ថ្ងៃ។ ១ថ្ងៃមួយភាគី ដូច្នេះអាចបន្តតាមពេលវេលាដែលបានកំណត់នេះ ហើយនិងពេលវេលាដែលបានធ្វើរួចហើយ ដើម្បីប្តូកដកគ្នា។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ រួមទាំងបុគ្គលិកអង្គការ ភី.ធី.អូ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅពេលវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៤ នាទី)*

[១៥:០៤:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ លោកដើមបណ្តឹងរដ្ឋប្បវេណី យើងអម្បាញ់មិញនេះយើងបានមើលប្លង់នៅក្រាំង-តាចាន់ ដែលបានធ្វើដោយអ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេតទៅតាមចម្លើយរបស់លោក។ បាទ នៅលើប្លង់នេះ គឺថាមានកន្លែងចុងភៅពីរ គឺថាមួយសម្រាប់អ្នកទោស មួយទៀតសម្រាប់អ្នកយាម។ សម្រាប់អ្នកយាមនោះ គឺនៅក្បែរកន្លែងសួរចម្លើយ។ អ៊ីចឹងតើលោកអាចឆ្លើយប្រាប់បានទេថាតើលោកអាចក្នុងឋានៈលោកជាអ្នកទោសនេះ ដែលក្នុងការបំពេញការងាររបស់លោកនោះ លោកអាចចូលទៅក្នុងផ្ទះបាយទាំងពីរហ្នឹង ឬក៏កន្លែងចង្ក្រានបាយទាំងពីរហ្នឹង? លោកអាចជម្រាបជូនបានទេ? លោកមានសិទ្ធិធ្វើអ៊ីចឹងទេ?

**លោក សយ សែន៖**

**ឆ៖** បាទ អត់បានទេ។ បានតែខាងផ្ទះអ្នកទោស ផ្ទះបាយខាងកងទ័ពពួកគេ គឺទាល់តែគេប្រើ។ ថាប្រើថា "អ្នក! អ្នែងត្រូវយកអានេះទៅនេះ យកអានោះទៅនោះ" បានអាចចូលបាន។ ហើយបើអត់ប្រើទេ អត់មានសិទ្ធិចូលបានទេបាទ។

[១៥:០៥:៥៤]

**ស៖** បាទ ឥឡូវខ្ញុំសូមឲ្យលោកជួយបំភ្លឺកន្លែងមួយ ថាទាក់ទងនឹងកន្លែងដេករបស់លោក។ ខ្ញុំសូមធ្វើយ៉ាងម៉េចដើម្បីឲ្យច្បាស់លាស់កន្លែងនេះ ខ្ញុំមានអត្ថបទមួយដែលចុះផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺអត្ថបទស្វែងរកការពិតដែលមានលេខកូដ D22/1370.2។ បាទ ខ្ញុំសូមអានសម្រង់នៃអត្ថបទនេះមួយដែលគេនិយាយអំពីលោក មានសរសេរនៅទំព័រអង់គ្លេសគឺ 00527800 ហើយនិងជាភាសាខ្មែរគឺ 00527797។ មាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ សម្រាប់អ្នកបកប្រែ គឺយើងខ្ញុំ

និយាយជាភាសាអង់គ្លេស អ៊ីចឹងសូមអ្នកបកប្រែជាភាសាអង់គ្លេស។ "ក្រោយពីរយៈពេលដ៏យូរ ខ្ញុំគិតថាព្យាយាមឲ្យអ្នកយាមទុកចិត្ត ហើយអនុញ្ញាតឲ្យដេកនៅក្នុងចង្ក្រានបាយជាមួយអ្នកទោស -- ជាមួយអ្នកយាមដទៃទៀតឈ្មោះ តាចិន"។ បាទ បញ្ចប់ការដកស្រង់។ លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកធ្លាប់ដេកនៅរោងបាយជាមួយនឹងអ្នកទោសអ្នកទៀតដែលឈ្មោះថា តាចិន លោកធ្លាប់បានដេកជាមួយគាត់ទេ?

**ឆ៖** បាទបានធ្លាប់។ ធ្លាប់ដោយសារក្នុងគុកវាពេញណែនទាំងអស់ទៅ ដល់ណែនទាំងអស់ទៅគាត់ឲ្យខ្ញុំដើរដាក់ខ្នោះ ដល់ពេលចុងបញ្ចប់មកថា "អ្អែងដេកហ្នឹង អ្អែងមិនចាំបាច់ទៅណាទេ ពីរនាក់តាចិន ដេកហ្នឹង ដេកនៅកន្លែងចង្ក្រានបាយហ្នឹង"។ ដេកនៅចង្ក្រានបាយ ហ្នឹងជិតកន្លែងកងទ័ព ហើយប្រធានមន្ទីរក៏នៅជិតហ្នឹងដែរបាទ។

[១៥:០៨:២០]

**ស៖** បាទ ខ្ញុំកត់សម្គាល់ឃើញថាលោកហៅ ចិន ហ្នឹងថាឈ្មោះហៅថា តាចិន នៅក្នុងចម្លើយរបស់លោកមួយចំនួន។ តើគាត់អាយុប៉ុន្មានដែរកាលនោះដែលលោកហៅគាត់ថា តាចិន ហ្នឹង?

**ឆ៖** បាទ គាត់អាយុគាត់ខ្ញុំមិនអាចដឹងទេ ប៉ុន្តែប្រហែលជាអាចអាយុគាត់ខ្ទង់៥០ជាងជំនាន់ហ្នឹង ៥០ជាង។

**ស៖** បាទ សូមអរគុណ។ ខ្ញុំត្រលប់មកនិយាយពីចំណុចនេះនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំសូមបន្តនិយាយអំពីប្លង់ហ្នឹងនេះទៀត។ គឺឯកសារ D125/220.37 សូមផ្ទុះបញ្ចាំង ហើយឃើញមានកន្លែងសួរចម្លើយដែលនៅចម្ងាយប្រហែលជា១០ម៉ែត្រជាងពីអគារអ្នកទោស។ តើលោកបាននិយាយអ៊ីចឹងមែនទេទៅចៅក្រមស៊ើបអង្កេតនោះ?

**ឆ៖** បាទ បានប្រាប់វា មិនជា១០ម៉ែត្រជាង អាចជាខ្ញុំថា ស្នាដីហ្នឹងប្រហែលជាអាចចូល២០ម៉ែត្រ ក៏វា១០ម៉ែត្រជាង ១០ម៉ែត្រក្រាស់ មិនមែន១០ម៉ែត្រស្ដើងទេបាទ។

[១៥:០៩:៤៨]

**ស៖** វាមានចម្ការដំឡូងមីផងដែរ។ តើកន្លែងហ្នឹងថា ចម្ការហ្នឹងថានៅចន្លោះកន្លែងសួរចម្លើយហើយនិងកន្លែងផ្សេងៗទៀតនៃគុកហ្នឹង តើចម្ការដំឡូងហ្នឹង បើយើងមើលពីកន្លែងអ្នកនេះ កន្លែងគេដាក់អ្នកទោស ផ្ទះដាក់អ្នកទោសនុ៎ង មើលឃើញឆ្លងទៅដល់កន្លែងអ្នកសួរចម្លើយទេ? មើលពីកន្លែងអ្នកទោសទៅឃើញកន្លែងគេសួរចម្លើយទេ?

**ឆ៖** បាទ មើលឃើញតែដំបូលលើទេ មើលខាងក្រោមមើលអត់ឃើញទេ ព្រៃដំឡូងមីជិតឈើងទាំងអស់ ព្រោះអាហ្នឹងគេដាំអត់ដកទេ ដាំការពារទុកសម្រាប់កុំឲ្យមនុស្សមើលឃើញទៅត្បូង។

**ស៖** នៅក្នុងរយៈពេល៥ឆ្នាំដែលលោកជាប់ឃុំនៅក្រាំងតាចាន់ហ្នឹង តើលោកបានមើលសង្កេតមើលថា តើកន្លែងសួរចម្លើយនោះវាមានទ្រង់ទ្រាយយ៉ាងម៉េចដែរ? លោកអាចពិពណ៌នាអគារសួរចម្លើយនុ៎ងបានទេ ផ្ទះសួរចម្លើយ?

[១៥:១១:០២]

**ឆ៖** បាន បាទ។ ខាងមុខហ្នឹងគឺគេធ្វើដូចថារវ៉ង់ដា ជញ្ជាំងតឿខ្ចីអ៊ីចឹងមក វាដូច ប៉ុន្តែអ្នកអង្គុយសួរចម្លើយហ្នឹង តែដុំឈើទេ។ កាត់ដុំឈើ ជាឈើមូលៗកាត់ដុំម៉ុៗធ្វើកង់ៗអង្គុយ ហើយអាកន្លែងសួរចម្លើយ គេវ៉ៃជើងម៉ា ជើងម៉ាឈើ ក្ដារមួយសន្លឹក ដាក់ជើងម៉ាអង្គុយ។ ហើយគេ -- កងទ័ពគេ និងកម្មាភិបាលអីអង្គុយខាងៗ ហើយពីមុខអ៊ីចេះប្រធាន ប្រធានគុកអង្គុយមួយ។ អាហ្នឹងមានកៅអី -- អត់មានកៅអីទេ មានតែដុំឈើជាកង់ កាត់កង់ដុំអង្គុយ អត់មានជាកៅអីអត់មានទេ។ ហើយក្នុងប្រដាប់សួរចម្លើយហ្នឹង មានតែដំបងឫស្សីប៉ុនៗកងដៃនេះ ប្រវែងៗនេះ បីបួនកំណាត់ ហើយនិងក្រមាហ្នឹងពីរបី ហើយកៅស៊ូ អាកៅស៊ូ-សហ្នឹង សម្រាប់ចងមុខហ្នឹង បីបួនសន្លឹកនៅហ្នឹងបាទ។

**ស៖** តើលោកបានសង្កេតឃើញអ្វីទាំងអស់ហ្នឹងពីខាងក្រៅ ឬក៏ពេលម្ដងម្កាលហ្នឹងលោកធ្លាប់ចូលទៅដល់កន្លែងគេសួរចម្លើយហ្នឹង ដោយខ្លួនឯងផងដែរ?

**ឆ៖** បាទ ខ្ញុំបានចូលទៅបោសសម្អាត ឧទាហរណ៍បោសស្លឹកឈើ បោសសម្រាមចេញហើយបានគាត់ចូលទៅធ្វើការម៉ោងប្រាំបី ម៉ោងប្រាំបួនបានចូល ហៅសួរចម្លើយ។ ព្រលឹមឡើងត្រូវតែបោសសម្អាតកន្លែងហ្នឹងឲ្យហើយ។

**ស៖** បាទ ខ្ញុំនឹងត្រឡប់មកនិយាយអំពីការសួរចម្លើយនេះនៅពេលក្រោយ។ តើមាន -- កន្លែងហ្នឹង កន្លែងសួរចម្លើយហ្នឹងមានកន្លែងគ្រប់គ្រាន់ដើម្បីសួរអ្នកទោសម្ដងពីរនាក់បានទេ ឬក៏គេសួរតែម្ដងម្នាក់ទេ?

[១៥:១២:៥៥]

**ឆ៖** បាទ សួរតែម្ដងតែម្នាក់ទេ។

**ស៖** តើកន្លែងសួរចម្លើយហ្នឹងមានជញ្ជាំងរឹងមាំទេ ឬក៏ជញ្ជាំងហ្នឹងគេធ្វើអំពីអ្វីដែរ?

**ឆ៖** បាទ ជញ្ជាំងពីខាងមុខហ្នឹងវ៉ៃក្ដារ ក្ដារជញ្ជាំងតឿហ្នឹង ក្ដារខ្លីៗទាបៗគេដាក់អង្គុយមនុស្ស

អង្គុយមើលឃើញត្រឹមចង្កេះឡើងមកលើ។ ហើយបើខាងក្នុងនេះគេរើជញ្ជាំងថែប អាជញ្ជាំងថែបយើងស្លឹកត្នោត យើងដេរស្លឹកត្នោតហើយរើប្រជីសឫស្សីអបពីរតឹកមួយៗ ដាក់ឫស្សីប្រជីស គេហៅជញ្ជាំងប្រជីសៗឫស្សី ប៉ុន្តែពីក្នុងហ្នឹងស្លឹកត្នោត។

**ស៖** តើលោកអាចប៉ាន់ស្មានពីចម្ងាយចង្ក្រានបាយរបស់អ្នកយាម ហើយនិងកន្លែងសួរចម្លើយអ្នកទោសដែរឬទេ?

**ឆ៖** បាទ ដីហ្នឹងប្រហែលជាជាង១០ម៉ែត្រដូចគ្នា ពីកន្លែងអ្នកយាមហើយទៅកន្លែងសួរចម្លើយហើយចង្ក្រានបាយកងទ័ពហ្នឹង ជាងៗ១០ម៉ែត្រដូចគ្នាបាទ។

[១៥:១៤:៣១]

**ស៖** សូមអរគុណ។ គឺទាក់ទងទៅនឹងប្លង់ដដែល ឯកសារដដែល យើងឃើញថាមានសរសេរនៅៗ -- មានរណ្តៅរួមមួយនៅខាងកើត ហើយនៅខាងនិរតីនៃចម្ការនោះ ហើយកាលនោះមានសាកសពដែលគេកប់នៅខាងក្រោមដើមដូងផងដែរ។ នៅខាងត្បូងក៏មានដែរ។ អ៊ីចឹងតើមានកន្លែងផ្សេងទៀតដែលគេសម្លាប់អ្នកទោស ហើយកប់សាកសពនៅក្នុងបរិវេណ គឺនៅក្នុងជុំទី១ហ្នឹង ឬក៏មានអ្នកផ្សេងទៀត អ្នកទោសផ្សេងទៀតត្រូវបានគេសម្លាប់ហើយ ដាក់កប់នៅជុំខាងក្រៅ ដែលយើងឃើញមានរូបក្នុងប្លង់យើងនេះ?

**ឆ៖** បាទមានៗ នៅខាងក្រៅក៏មានដែរ។ ឧទាហរណ៍ថានៅខាងជួររបងហ្នឹងវាកប់ហើយដាក់ដូងពីលើពេញអស់ទៅ នៅខាងៗគឺស្លាប់ក្នុងអគារហ្នឹង ក្នុងគុកហ្នឹង ម្យប់មួយម្យប់ពីរហ្នឹងយកទៅសែងទៅដាក់នៅវាលស្រែខាងត្បូងដើមអំពិល។ ខាងត្បូងដើមអំពិល យើងកប់ជម្រៅប្រហែលជាអាចប្រាំមួយតឹក ឬប្រាំពីរតឹក កុំឲ្យភ្ជួរទើស អត់ឲ្យភ្ជួរទើស។ ភ្ជួរស្រែកាលណាទើស ទើសសពហ្នឹង គេឲ្យកប់ខ្ពស់ពីនង្គ័លបាទ។

**ស៖** បើខ្ញុំយល់មិនច្បាស់ទេ តើក្រៅពីកន្លែងទាំងបីហ្នឹង កន្លែងគេកប់សពទាំងបីកន្លែងហ្នឹងក្រៅពីជុំទី១ ជុំទី២ ជុំទី៣ហ្នឹង មានរណ្តៅផ្សេងទៀតដែលគេធ្វើសម្រាប់កប់ខ្មោចដែរឬទេ? កប់សាកសពដែរឬទេ?

[១៥:១៦:៣៥]

**ឆ៖** បានមាននៅភូមិខាងលិច ហើយខាងត្បូងមាត់ត្រពាំង បាទ។ មានរណ្តៅនៅទល់វាល់ថ្ងៃហ្នឹងបាទ។

**សៈ** តើចាប់ពីពេលណាដែរ ដែលគេកប់សាកសពនៅក្រៅពីជុំទី១?

**ឆៈ** បាទហ្នឹងពេលឆ្នាំ៧៧ បាទ ពេលគេសម្លាប់ច្រើនឆ្នាំ៧៧ យកមកដាក់នៅក្រៅហ្នឹង។

**សៈ** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាហេតុអ្វីបានជាការចាំបាច់ចាប់ពីឆ្នាំ ១៩៧៨ហ្នឹងទៅ ដោយសារមានការកាប់សម្លាប់ទ្រង់ទ្រាយធំ ត្រូវតែកប់នៅក្រៅជុំទី១ ឬក៏បរិវេណក្នុងទី១ហ្នឹង?

**ឆៈ** បាទ ព្រោះខាងក្នុងវាដាក់ច្រើន ហើយវាពេញណែនចង់អស់ បានយកមកដាក់នៅភូមិខាងក្រៅ ដាក់ខាងលិចមាត់ត្រពាំង ខាងត្បូងមាត់ត្រពាំង បាទ។ អាហ្នឹងនៅភូមិខាងក្រៅ ប៉ុន្តែក្រៅនៅក្នុងជួរក្នុងរបងៗផុតអារបងទី២ ផុតរបងទី២ អត់ទាន់ផុត -- ផុតរបងទី២។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

បាទសូមអរគុណ។

ឥឡូវនេះ ខ្ញុំសូមលោកប្រធាន សូមការអនុញ្ញាតបង្ហាញរូបថតមួយ ទៅដើមបណ្តឹងរដ្ឋប្បវេណី គឺជារូបថតដែលសហចៅក្រមស៊ើបអង្កេតបានថត នៅពេលដែលគាត់នាំទៅក្រាំងតាចាន់ កាលពីខែមីនា ឆ្នាំ២០០៩ គឺជារូបថតដែលមានលេខកូដ D125/220.24 ដែលមានលេខកូដ P00355388 ។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតផ្តល់រូបថតនេះទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសូមបញ្ចាំងបង្ហាញលើអេក្រង់ផងដែរ លោកប្រធាន។

[១៥:១៩:០១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

បាទសូមអរគុណលោកប្រធាន។ រូបថតហ្នឹង យើងឃើញបន្តិចទៀតហើយ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ពាឯល៖**

**សៈ** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកអាចពិពណ៌នាអំពីអ្វីដែលនៅលើរូបថតហ្នឹង? ហើយលោកស្គាល់កន្លែងហ្នឹងទេ?

**លោក សយ សែន៖**

**ឆៈ** បាទស្គាល់។ អាហ្នឹងវាមុនដំបូងស្រះទឹកៗ គេជីកតូចមួយទេ តូចមួយ ដល់ពេលដល់ឆ្នាំ

៧៧មក អាងពីខាងត្បូងនេះ អាងពីខាងត្បូងខ្លោងទ្វារចូលនេះ អាហ្នឹងមួយរណ្ដៅពីខាងត្បូងហ្នឹង អាហ្នឹងកន្លែងកប់សពទាំងអស់បាទ មួយកំណាត់ខាងត្បូងនេះកប់សព ពីមុនតូចមួយទេ ជីក -- អ្នកទោសអ្នកជីកកន្លែងហ្នឹង បាទ។

**ស៖** តើលោកផ្ទាល់នោះលោកមាន លោកបានជីករណ្ដៅហ្នឹងជាមួយអ្នកទោសផ្សេងទៀតទេ?

**ឆ៖** បាទ ខ្ញុំបាន។ បាន ប៉ុន្តែជីក ខ្ញុំជីកតែចុងក្រោយទេ ជីកពីមុនខ្ញុំអត់បានជីកទេ។ ជីកអាចុងក្រោយគេឲ្យកាប់សម្រាប់ឆ្នាំ៧៧នេះ អាចុងកំណាត់ខាងត្បូងនេះសម្រាប់កប់សពថែមពីលើហ្នឹងបានតែឆ្នាំ៧៧។

[១៥:២០:៤៥]

**ស៖** បាទសូមអរគុណ។ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីលក្ខខណ្ឌនៃការឃុំឃាំងនៅក្រាំងតាចាន់ ហើយនិងពីផ្ទះផ្សេងៗនៅក្នុងមន្ទីរក្រាំងតាចាន់នេះ។ ហើយខ្ញុំសូមអានសម្រង់មួយនៃកំណត់ហេតុស្ដាប់ចម្លើយរបស់លោក នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែលមានលេខកូដ E3/5214, ERN ជាភាសាបារាំងគឺ 00702900, ERN ជាភាសាអង់គ្លេសគឺ 00225512 និងជាភាសាខ្មែរគឺ 00223069។ បាទខ្ញុំសូមដកស្រង់នូវអ្វីដែលលោកបាននិយាយ នេះគឺជាពាក្យពេចន៍របស់លោក៖ “ផ្ទះឃុំឃាំងទាំងអស់នេះធ្វើអំពីឈើ ជញ្ជាំងប្រក់ស្លឹក ដំបូលប្រក់ក្បឿង ហើយព័ទ្ធជុំវិញទៅដោយខ្សែលួស ហើយនៅខាងលើពិដានក៏មានលួស ខាងក្រោមរនាបក្ដារក៏មានលួសដែរ។ អ្នកទោសទាំងអស់ហ្នឹងឲ្យដេកនៅលើរនាបក្ដារហ្នឹង ហើយនៅៗខាងលើហ្នឹង នៅខាងលើដំបូលពីក្រោមហ្នឹងក៏មាននេះដែរ ក្រោមក្ដារហ្នឹងក៏មានបន្ទាលួសដែរ”។ ខ្ញុំសូមបង្ហាញរូបថតបួនជូនលោកមើល ដែលត្រូវបានគេថតដែលគេបានថតក្រោយពីឆ្នាំ១៩៧៩ នៅក្រាំងតាចាន់។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

រូបថតទី១ ដែលខ្ញុំចង់បង្ហាញនោះគឺ លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញ -- មើលគឺរូបថតពីរ សូមទោស។ គឺ D313/1.2.150។ ខ្ញុំអានម្ដងទៀត D313/1.2.150 ដែលមានលេខ P00407123។ រូបថតទី២គឺ D313/1.2.151 ដែលមានលេខយោង P00407125។ បាទលោកប្រធានអ៊ីចឹងខ្ញុំសូមអនុញ្ញាតផ្ដល់រូបថតទាំងពីរនេះទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងសូមបញ្ចាំងលើអេក្រង់ជាបន្តបន្ទាប់លោកប្រធាន។ សូមលោកប្រធានអនុញ្ញាត។

[១៥:២៣:៤១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកស្គាល់កន្លែងនេះទេ ឃើញនៅលើរូបថតចាស់នេះ ប្រភេទផ្ទះហ្នឹងលោកស្គាល់ទេ?

**លោក សយ សែន៖**

**ឆ៖** បាទ ស្គាល់។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេថា រូបថតហ្នឹងជាអ្វីដែរនុ៎ង?

**ឆ៖** បាទរូបថតនេះ ជា -- ផ្ទះនេះជាផ្ទះចាស់។ ប៉ុន្តែផ្ទះចាស់ហ្នឹងពីមុនមិនមែនគុកទេ ផ្ទះហ្នឹងកន្លែងៗគេដាក់ស្នាក់ការពីខាងត្បូងហ្នឹងមួយជិតកន្លែងចង្ក្រានបាយមួយទៀត ប៉ុន្តែស្នាក់ការហ្នឹងគេដាក់ស្នាក់ការហ្នឹង អានេះគេវ៉ៃឈើខ្វែងនេះ អាបន្ទាលួសនេះ ប្រជាជនឆ្នាំ៧៩ទេយក -- រំដោះហើយយកលួសទៅដាក់ទាក់អាហ្នឹងទាក់ជាខ្នោះ ទាក់ខ្នោះទុកឲ្យគ្រាន់បងប្អូនយើងមើល។ កាលជំនាន់ហ្នឹងវាអត់ទាន់មានកើតជាស្អី ឬអង្គការណា ឬថ្នាក់ណាចុះទៅមើលទេ អត់មានទេ បានន័យថាយកមកព្យួរៗ។ ហើយអាហ្នឹងក៏ -- រោងហ្នឹងហើយក៏ប្រមូលសពៗដាក់នៅក្នុងផ្ទះហ្នឹងទេ។ បើថាគុកនោះ អត់មានគុកហ្នឹងទេ អត់មានគុកទេ អាហ្នឹងអត់ទេ គុកគេអត់ធ្វើអីចឹងទេ អាហ្នឹងកន្លែងស្នាក់ការគេពីមុន គេហៅថា "ស្នាក់ការ" ហើយក៏គេយកសពទៅដាក់ហ្នឹង ហើយយកអាខ្នោះហ្នឹង ហើយយកច្រវាក់ហ្នឹង យកទៅទាក់ខ្វាត់ខ្វែងៗហ្នឹងទុកជាភស្តុតាង គឺថាទុកបងប្អូនថតមើល ហើយដល់ចុងបញ្ចប់មកផ្ទះហ្នឹងក៏វាបាក់ពុក រលើងរលត់អស់ហើយ រាល់ថ្ងៃហ្នឹងក៏សាងជាថ្មីមួយសាទៀតដែរ។

[១៥:២៥:៤៥]

**ស៖** បាទ សូមអរគុណ។ គឺថាមានព្យួរខ្នោះដែក អីចឹង ខ្ញុំសុំឲ្យលោកមើល តើខ្នោះទាំងអស់ហ្នឹងដែលលោកកំពុងតែមើលឃើញហ្នឹង គឺជាខ្នោះដែលគេបានប្រើនៅក្រាំងតាចាន់ ឃើញដូចគ្នា -- អីចឹងឃើញរូបខ្នោះហ្នឹង ជារូបខ្នោះដែលគេបានប្រើនៅក្រាំងតាចាន់មែនទេ ដែលគេខ្នោះយកដាក់ជើងអ្នកទោស?

**ឆ៖** បាទ ជាពិតប្រាកដ អត់មានរបស់ក្លែងទេ ពិតប្រាកដតែម្ដងបាទ។

**ស៖** លោកអាចជម្រាបជូនតុលាការបានទេថា ការដែលជាប់ខ្នោះហ្នឹង គឺធ្វើឲ្យមានការឈឺ

ចាប់ ហើយអាចធ្វើឲ្យស្នួងជើង កជើងហ្នឹងមានរបួសអីជាដើមហ្នឹង? អាចមានអ៊ីចឹងទេ?

**ឆ៖** បាទ នេះវាឃើញខ្មោះ ដូចខ្ញុំបានជម្រាបពីព្រឹកម្ដងថា ខ្ញុំអត់ចង់ឲ្យឃើញ ហើយក៏មិនចង់ឲ្យដឹងទេក្រាំងតាថាន់។ គឺជាក់ស្ដែងពីស្នួងរបស់ខ្ញុំគឺនៅដំបៅទល់រហូត តថៅ ព្រោះថៅខ្ញុំធំអាយុជិត ១០ឆ្នាំហើយថៅ ខ្ញុំបានប្រាប់ថៅ សព្វថ្ងៃថាអាហ្នឹងហើយ ខ្នោះតា ខ្នោះកុងជំនាន់ជាប់ខ្នោះជើងដោយសារឧក្រិដ្ឋកម្ម បាទ។ ជាក់ស្ដែងរូបខ្ញុំ ភស្តុតាងទុកឲ្យកូន និងថៅមើលសព្វថ្ងៃ បាទ។

**ស៖** បាទ ខ្ញុំសូមអភ័យទោសដែលចោទសំណួរនេះទៅធ្វើឲ្យដំបៅចាស់រើឡើងវិញ។ តើកាលនោះ ដំបៅដែលបង្កដោយខ្នោះហ្នឹងវាក្លាយទេ?

**ឆ៖** បើនិយាយពីក្លាយ ៗរហូតដំបៅអត់ដុះរោមទល់សព្វថ្ងៃហ្នឹង ក្លាយទល់សព្វថ្ងៃ។ ប៉ុន្តែសម័យនោះបានគុណទឹកដោះម្ដាយថ្លៃ រើតែកូនកង្កែប អាកូនកង្កែបយើងគេលែងចេញធ្វើការ រើកូនកង្កែបយកមកបុកជាមួយអំបិល ហើយយកមកស្អំ យកមកបិទ គឺបានជាទាំងក្បាលនិងជើងទល់សព្វថ្ងៃ។ ប៉ុន្តែកន្លែងហ្នឹងអត់ដុះៗ ក្បាលក៏អត់ដុះសក់ -- ជើងក៏អត់ដុះរោមៗ កន្លែងដាក់ខ្នោះហ្នឹងបាទ។

[១៥:២៨:១៨]

**ស៖** ឥឡូវខ្ញុំសុំត្រឡប់មកនិយាយអំពីលក្ខខណ្ឌអនាម័យនៅក្នុងមន្ទីរឃុំឃាំងហ្នឹង ហើយលោកបាននិយាយហើយអំពីរបៀបដែលអ្នកទោសទាំងអស់ហ្នឹងគាត់បត់ដៃបត់ជើង ហើយនិងគាត់ហូបចុក។ តើអ្នកទោសហ្នឹងមានទឹកដើម្បីលាងដៃមុននឹងហូបចុកទេ ឬក៏ក្រោយពីពេលគាត់បត់ដៃបត់ជើងហើយហ្នឹង គាត់មានទឹកលាងដៃលាងជើងទេ?

**ឆ៖** បាទ ទឹកគេឲ្យខ្ញុំ ពេលហូបបាយហើយគេឲ្យខ្ញុំយួរមួយធុងយើង មានធុងមិនមែនធុងប៉េត្រូទេ សម័យហ្នឹងអត់មានធុងប៉េត្រូទេ មានតែធុងគេដំៗ ថាំងៗ ប៉ុន្តែថាំងដូចជាថាំងឈើអ៊ីចឹង គេធ្វើដូចថាំងឈើចាក់ទឹកក្នុងហ្នឹង ខ្ញុំយួរមួយថាំងហ្នឹងដាក់ត្រឡោកមួយ។ ពេលបាយដួសដាក់បាយហើយតាមជួរហ្នឹង យួរថាំងដើរតាម កន្លែងណាចង់បានទឹក ដងទឹងហ្នឹងដាក់មួយត្រឡោក។ ប៉ុន្តែដងទឹកដាក់មួយត្រឡោកហ្នឹងទាល់ហូបបាយហើយៗ យកត្រឡោកបាយហ្នឹងដងទឹកពីថាំងខ្ញុំអ្នកយួរទៅឲ្យ អត់មានត្រឡោកដងទុកឲ្យហ្នឹងអត់មាន យកត្រឡោកបាយហូបហើយ អ្នកណាហូបបាយមុនគេហើយមុនគេយកត្រឡោកបាយហ្នឹងដងទឹកជូតមុខជូតមាត់ ហូបហើយជូតមុខជូតខ្លួនអីបានខ្លះ។ ប៉ុន្តែយួរពេក គេអត់ឲ្យយួរទេ ឲ្យប្រញាប់ ព្រោះអ្នកយាមគេនៅយាមឈរយាមនៅមាត់ទ្វារហ្នឹងថា៖ "អ្អែងយួរម្ល៉េះ?" "ខ្ញុំថាគាត់រវល់ដងទឹក"។ អ៊ីចឹងគេសម្លុតដាក់ ដងបានតែមួយភ្លែតៗហ្នឹងទេ បាទ។

**សៈ** នៅពេលដែលអ្នកទោសហូបចុក តើគាត់ហូបចុកដោយមានចានមានស្លាបព្រាអី ឬក៏ហូបចុកនឹងដៃ នឹងម្រាមដៃទេ?

[១៥:៣០:០៦]

**ឆៈ** បាទ ខ្លះក៏អត់កាត់អាស្លឹកត្នោតអត់ទាន់ អាស្លឹកត្នោត យើងកាត់អាស្លឹកត្នោតងាប់ៗកាត់ប្រវែងណេះៗធ្វើស្លាបព្រា។ កាលណាកាត់មិនទាន់ គ្នាខ្លះក៏លើកទាំងត្រឡោកហុតគ្រូកអ៊ីចឹងមក ក៏អស់ទៅ ហើយខ្លះក៏នៅត្រឡោក នៅស្លាបព្រាត្រឡោកៗ មានខ្លះ ភាគច្រើនស្លឹកត្នោត ព្រោះត្រឡោក កាលណាគេប្រើស្លាបព្រា គេខ្លាចយើងលាក់ស្លាបព្រាគាស់ខ្នោះជើង គាត់ខ្នោះជើងរួចរត់រួច បានហើយគេការពារខ្លាំង ធ្ងន់មែនទេ គឺសន្តិសុខរបស់វា គឺខ្លាំងមែនទេ អត់មានខ្សោយទេជំនាន់នោះបាទ។

**សៈ** តើក្លិននៅក្នុងអគារ ឬក៏ផ្ទះអ្នកទោសហ្នឹង យើងអាចទ្រាំទ្រក្លិនហ្នឹងបានទេ?

**ឆៈ** បាទ ឃ្យូរទៅធម្មតាៗ។ ប៉ុន្តែបើនិយាយពីយប់ឡើង ខមាទោសបាទ ទាំងបត់ជើងតូចទាំងបត់ធំអី ពេញហ្នឹងអស់ណែនពេញហ្នឹងអស់ អាខ្លះវាអត់មានត្រឡោកអត់មានអី ប៉ុន្តែទាល់តែឃ្យូរៗទៅដាក់គុកឃ្យូរៗ អត់មានអីបត់ជើង មានតែទឹកនោម បើលាមកអត់សូវមានទេ ព្រោះអត់មានហូបបានលាមកពីណាបត់ មានតែទឹកនោមៗបានដោយសារទឹកបាទ។

**សៈ** លោកបាននិយាយថាលោកជាអ្នកទោសដែលគេឲ្យធ្វើការ ហើយអ៊ីចឹងលោកទទួលបានលក្ខខណ្ឌឃុំឃាំងប្រសើរជាងគេ។ តើអ្នកទោសធម្មតាហ្នឹងត្រូវបានចាត់ទុកដោយអ្នកយាម ហើយនិងកម្មាភិបាលនៅក្រាំងតាចាន់ហ្នឹងដោយគោរព និងដោយគោរពភាពថ្លៃថ្នូររបស់គាត់ទេ?

[១៥:៣២:០០]

**ឆៈ** បាទ រឿងថាគោរព ខ្ញុំមិនគោរពបាន១០០ភាគរយ ព្រោះកាលណាគេលែងខ្ញុំ គេទុកចិត្តខ្ញុំដោយសារខ្ញុំមើលក្របីនិងមើលសេះ សេះផង ក្របីផង គោផង គ្នាពីរនាក់។ បើអ៊ីចឹងពីរនាក់ តាចិនហ្នឹង ដល់ពេលលែងចេញមកក្រៅ ខ្ញុំអាចរស់រានមានជីវិត អាចរាងសាច់ឈាមវាភ្លឺជាងគេ ដោយសារខ្ញុំបានដុតត្នោតទុំនិងដូងៗ បានដូងហូបញ៊ីក ហើយត្នោតទុំ ហើយនិងដំឡូងៗមី។ ទៅមើលគោហ្នឹង ដុតបំពក់មួយភ្នក់អ៊ីចឹង ដុតៗហើយ បំពក់ជីពីខាងលិចកន្លែងគុកចាស់ ពីខាងលិចហ្នឹងមានគ្រលុកជីមួយអាគ្រលុកហ្នឹងលាមកអីទឹកនោមអី សែងដាក់គ្រលុកជីហ្នឹង ខ្ញុំបំពក់ដុតហ្នឹង យកដំឡូងមកញាត់នៅហ្នឹងមួយមើមអីទៅ។ ពេលវាលែងចេញឲ្យមើលគោហ្នឹង ចេញមកមើលគោនៅខាងក្រៅ បានដំឡូងមីហ្នឹងមួយមើមៗបាទ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង នេះលោករៀបរាប់អំពីអាហារដែលលោកបានទទួល ក៏ប៉ុន្តែចំពោះអ្នកទោសផ្សេង ដែលអ្នកទោសធម្មតាដែលថាអាចត្រូវរស់នៅហ្នឹងបានប្រហែល១ខែអីប៉ុណ្ណឹង។ អ៊ីចឹងបើតាមការសង្កេតរបស់លោកហ្នឹង តើៗបុគ្គលិកនៅក្រាំងតាចាន់ហ្នឹងមើលទៅគាត់ក្នុងលក្ខណៈជាមនុស្សទេ គោរពភាពថ្លៃថ្នូររបស់គាត់ទេ?

**ផ៖** បាទ ពីជំនាន់នោះ ឃើញគេថាខ្លាច ខ្លាចតែម្តង ឃើញខ្លាចបាទ ទាល់តែគោរពគេ ធ្វើម៉េចឲ្យបានរស់បាទ។

**ស៖** នៅពេលអ្នកទោសស្លាប់នៅក្នុងផ្ទះឃុំនៅពេលយប់ ឧទាហរណ៍ តើប៉ុន្មានម៉ោងដែរដែលគេអូសសពហ្នឹងចេញពីផ្ទះឃុំឃាំងហ្នឹងចេញទៅ?

[១៥:៣៤:០៧]

**ផ៖** បាទ បើថាស្លាប់ពីយប់ហ្នឹងអ៊ីចឹង ដល់ល្ងាចម៉ោងបួន បានអាចយកចេញបាន។ យកចេញបាន អត់យកពេកព្រឹកទេ យកពេលល្ងាច។ កាលណាលែងអ្នកទោសធ្វើការអ៊ីចឹង ពេលព្រឹកគេលែងអ្នកទោសធ្វើការ។ លែងធ្វើការ ដល់សពហ្នឹងនៅក្នុងហ្នឹងរហូត ដល់ល្ងាចបញ្ចូលអ្នកទោសវិញបានដកអាខ្នោះហ្នឹងរហូត បានដោះដល់អ្នកទោសស្លាប់នៅកណ្តាល ឬនៅចុងបំផុតខាងកើតអ៊ីចឹង ដោះផុតហើយ បានដាក់មកវិញ។ ដោះអាខ្នោះជើងខ្នោចហ្នឹង ខ្ញុំអ្នកចូលដោះចេញៗពីខ្នោចមកទៅដាក់ឲ្យៗអ្នកជាៗ អ្នករស់នៅចេះតែដាក់ អ្នកខ្មោចដោះចេញមក។ ហើយទុកដល់ល្ងាចម៉ោងបួន បញ្ចូលអ្នកទោសហើយ បានអាចយកសពហ្នឹងទៅកប់បានបាទ។ គេអត់ឲ្យយកពេលភ្លឺទេ យកពេលថ្ងៃ -- ពេលព្រលប់ៗថ្ងៃល្ងាចអី។

**ស៖** ដូច្នេះបើសិនជាខ្ញុំស្តាប់មិនច្រឡំនោះ គឺថានេះសម្រាប់អ្នកទោសដែលធ្វើការ។ ខ្ញុំគិតថាប្រហែលជាមានការបញ្ច្រាបកប្រែហើយ។ ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ថា លោកអាចយកសពហ្នឹងចេញពីផ្ទះឃុំហ្នឹងបាន នៅពេលដែលលោកត្រឡប់មកពីធ្វើការវិញ។ អ៊ីចឹងមែនទេ?

**ផ៖** បាទ ទាល់តែបញ្ចូលអ្នកទោសថ្ងៃល្ងាចវិញ បានយកសពហ្នឹងចេញបានបាទ។ គេឲ្យចេញតែថ្ងៃល្ងាច ទោះបីសម្លាប់ពីយប់ក៏ដោយ ស្លាប់ពីថ្ងៃរម៉ាន យើងចូលពីយប់ កណ្តាលយប់ហ្នឹង ដឹងនៅហ្នឹងហើយ។ ស្អែកឡើងថ្ងៃល្ងាចម៉ោងបួន ម៉ោងបីបញ្ចូលអ្នកទោសធ្វើការ បានយកបាន។ ពេលព្រឹកវាកំពុងលែងអ្នកទោសធ្វើការ គេអត់ឲ្យយើងសែងខ្មោចសែងអីចេញយកទៅទុកដាក់អីទេ កន្លែងគេដឹងទុកដាក់ខ្មោច គេអត់ឲ្យឃើញទេ។

[១៥:៣៥:៥៧]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ត្រឡប់មកក្រោយបន្តិច និយាយអំពីការសួរចម្លើយរបស់លោកនៅក្រាំងតាចាន់។ លោកបានបញ្ជាក់ថា លោកត្រូវបានចាប់ខ្លួននៅប្រហែលជាឆ្នាំ៧៤។ តើលោកអាចប្រាប់បានទេថា ក្រោយពីពេលគេចាប់ខ្លួនលោកនុំងគេមានសួរចម្លើយលោកទេ? ហើយបើសួរៗចម្លើយប៉ុន្មានដងដែរ?

**ឆ៖** គេចាប់ខ្ញុំមកដល់កន្លែងគុកក្រាំងតាចាន់ហ្នឹង ប្រហែលជាអាចរយៈកាល ប្រហែលជាអាចយូរដែរ។ ខ្ញុំបានឆ្លើយព្រឹកមិញម្ដងថា បើមិន១០ថ្ងៃលើស ក៏ជិតតែ១ខែក៏មិនដឹង បានៗគេសួរចម្លើយខ្ញុំ។ អត់មានសួរអីទាំងអស់ ពេលមកដល់ហើយឱ្យចូលដាក់គុករហូត គេហៅសួរចម្លើយហើយ ហៅក៏ស្អែកឡើងលែងឱ្យខ្ញុំចេញធ្វើការតែម្ដងបាទ។ ហើយសួរចម្លើយអត់មានសួរអីទេ សួរថា៖ "អ្អែងមានដែលទាក់ទងទៅណាទៅណីដែរអត់? អត់ទេ ខ្ញុំអត់ដែលដឹងអីណាផង"។ ថាអ្អែងដែលទាក់ទងទៅខាងអង្គតាសោមខាងអីអត់? អង្គតាសោមកាលហ្នឹងមានទាហានលន់នល់នៅអង្គតាសោម ហើយនៅតាកែវ។ ថាខ្ញុំអត់ដែលបានស្គាល់ផងបាទ។ សួរតែប៉ុណ្ណឹងក៏គេលែងសួរ សួរមួយម៉ាត់ពីរម៉ាត់ គេក៏បញ្ជូនមកវិញយកដាក់គុកវិញជាធម្មតា។ កាលហ្នឹងខ្ញុំវានៅក្មេង វាមិនដឹងអី ម្ល៉ោះហើយខ្ញុំអត់ដែលដឹងអីខ្ញុំ។ ដាក់គុកជាធម្មតា ដល់ស្អែកខានស្អែកឡើងលែងខ្ញុំទៅបោចស្មៅៗស្រែបាទ។

**ស៖** តើការសួរចម្លើយហ្នឹងមានសួរអំពីទំនាក់ទំនងរបស់លោកជាមួយនឹងឪពុកលោកទេ?

**ឆ៖** បាទ អត់ទេ អត់មានសួរអីទាំងអស់។ សួរតែប៉ុណ្ណឹង សួរថា ខ្ញុំមានទាក់ទងទៅតាកែវ ទៅអង្គតាសោមអីជាមួយទាហានលន់នល់ទេ។ ថាខ្ញុំមិនដែលស្គាល់ទាហានលន់នល់ មិនស្គាល់អីអង្គតា-សោមអី តាកែវអីម៉េចផង។ ឆ្លើយតែប៉ុណ្ណឹង។ បាន ថា--

[១៥:៣៨:១១]

**ស៖** តើលោកចាំឈ្មោះដែលគេ -- នៅអង្គតាមសោមពេលគេសួរចម្លើយលោកហ្នឹងទេ? គេមានសួរលោកថា មានទំនាក់ទំនងជាមួយឈ្មោះអីៗអ៊ីចឹងទេ?

**ឆ៖** បាទ អត់ទេ។ គេសួរថា "ទាក់ទង មានទាក់ទងទៅខាងក្នុងដែរអត់? ខ្ញុំថា ខ្ញុំអត់ដែលស្គាល់ផង" ខ្ញុំឆ្លើយប៉ុណ្ណឹង។ ប៉ុន្តែខ្ញុំអាចចាំបាន ខ្ញុំប្រុងបន្ថែមថា ប្រធានមន្ទីរមុននឹងគាត់បានផ្ដាំផ្ញើ ដល់គាត់ដូរទៅគាត់ផ្ដាំផ្ញើ តាអាន់ ថា៖ "វាទុកឱ្យវារស់ផង វាមិនដឹងអីវាទេកូនហ្នឹង វារលីវលើ គ្មានដឹងអីទេ"។ ហ្នឹង តាឆេន គាត់អ្នកផ្ដាំផ្ញើប្រធានមន្ទីរចុងក្រោយ។ ហើយមកចុងបញ្ចប់ជាបច្ចុប្បន្នរាល់ថ្ងៃនេះ

គាត់សុំរាប់អានខ្ញុំទុកជាកូនគាត់បច្ចុប្បន្ន គាត់ជាប្រធានគុកក្រាំងតាចាន់មុនគេ។ ឥឡូវគាត់ទៅនឹងខាងអន្លង់វែងហ្នឹង គាត់បានតេទូរស័ព្ទមកខ្ញុំរហូតដែរថា ទុកជាកូនបាទ ព្រោះគាត់អ្នកផ្ដាំផ្ញើទុកឲ្យរស់រានមានជីវិត។ គាត់និយាយអ៊ីចឹងដែរ។

**ស៖** ដូច្នេះខ្ញុំត្រូវយល់ថា តាចិន សួរចម្លើយលោក។ អ៊ីចឹងមានអ្នកផ្សេងទៀតទេដែលមានវត្តមាននៅពេលដែលគេសួរចម្លើយលោកហ្នឹង?

**ឆ៖** បាទ អត់មានទេ។ មានតែ តាឆេន មួយហ្នឹង។ តែមួយ ហើយពីមុនមក តាអាន់ ហ្នឹង គាត់អត់ទាន់ចូលនៅទេ មានតែ តាឆេន ៗហើយនិង តាចេង។

**ស៖** ដូច្នេះលោកនៅតែពីរនាក់តទល់ជាមួយ តាឆេន ទេ ឬក៏មានអ្នកផ្សេងទៀតនៅទីនោះដែរ ប៉ុន្តែគេអត់សួរលោកទេ គ្រាន់តែឈរមើល តាឆេន សួរលោក?

[១៥:៤០:០១]

**ឆ៖** បាទនៅហ្នឹង គ្នាគាត់ទាំងអស់បីនាក់ ប៉ុន្តែសួរ តាឆេន ហើយ តាចេង តែពីរនាក់ហ្នឹងទេ ខាងនោះគេអត់សួរទេ កងទ័ពគាត់ម្នាក់ទៀត។ កងទ័ពនៅឈរខាងក្រៅ នៅផ្លូវចូលពីខាងក្រៅ ប៉ុនវាមានកៅអីនៅឈរខាងក្រៅ ហើយយើងចូលទៅក្នុងហ្នឹង មានកន្លែងដូចថា ជញ្ជាំងតឿ ដូចថាកន្លែងការិយាល័យ ជំនាន់នុងហៅការិយាល័យ ប៉ុន្តែវាធ្វើបណ្ដោះអាសន្នពីកូនឈើអី ប៉ុនគេឈរខាងក្រៅ ដូចកាំភ្លើងមួយដើមនៅស្ពាយនឹងខាងហ្នឹង តែប៉ុណ្ណឹងបាទ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីរយៈពេលក្រោយថ្ងៃទី១៧ មេសា ៧៥ និងនិយាយអំពីតួនាទីផ្សេងៗរបស់លោកនៅមន្ទីរក្រាំងតាចាន់ ។ លោកបានលើកឡើងអំពីឈ្មោះមួយចំនួន អ៊ីចឹងខ្ញុំសូមលើកឡើងនូវកំណត់ហេតុស្ដាប់ចម្លើយលោក គឺឯកសារ E3/5214។ គឺលេខ ERN ជាភាសាខ្មែរ 00223063, ជាភាសាបារាំង 00702894 និងជាភាសាអង់គ្លេស 00225507រហូតទៅ 08។ ខ្ញុំសូមដក់ស្រង់នូវចម្លើយរបស់លោក៖ "ខ្ញុំដឹងពីព្រោះថា ខ្ញុំគេមិនចាត់ទុកខ្ញុំដូចជាអ្នកទោសផ្សេងទៀតទេ។ ជួនកាលគេឲ្យខ្ញុំយាមដូចទាហាននៅទីនុងដែរ ប៉ុន្តែខ្ញុំអត់មានកាំភ្លើងទេ ហើយគេអត់ឲ្យខ្ញុំដើរទៅណាឆ្ងាយទេ។ ជួនកាលគេឲ្យខ្ញុំរាប់ចំនួនអ្នកទោស។ អ្នកទោសនុង ត្រូវបានគេសម្លាប់ជារៀងរាល់ថ្ងៃ។ របៀបគេនាំអ្នកទោសទៅកន្លែងសម្លាប់ហ្នឹង គឺដូចតទៅ៖ ដំបូងគេដោះខ្នោះនាំចេញទៅក្រៅ បន្ទាប់មកពេញ ដែលជាសមាជិកហ្នឹងប្រាប់ទៅអ្នកទោសថា ឥឡូវនេះអ្នកទាំងអស់គ្នា ត្រូវគេដោះលែងហើយ ហើយបញ្ជូនទៅសហករណ៍។ ដូច្នេះត្រូវគោរពបញ្ជាអង្គការនៅសហករណ៍ កុំធ្វើអីឲ្យផ្ទុយទៅនឹង

អង្គការ កុំឲ្យខុសនឹងកងចក្រប្រវត្តិសាស្ត្រ។ ហើយគេអត់ចូលទៅដល់ខាងក្នុងគុកទេ ពីព្រោះថានៅក្នុងគុក មានៗក្លិនស្អុយខ្លាំងណាស់ លាមកអ៊ីចឹង អ៊ីចឹងគេប្រកាសពីខាងក្រៅគុក។ ពេញ កាន់បញ្ជីឈ្មោះហើយប្រកាសអ្នកទោសដែលត្រូវយកទៅសម្លាប់។ គាត់នាំអ្នកទោសម្តងចេញទៅប្រហែលជាបួននាក់ ដំបូងគេនាំទៅកន្លែងសួរចម្លើយសិន ក្រោយមកគេចងដៃហើយគេរុំបិទមុខ។ គឺគេធ្វើអ៊ីចឹងទៅដើម្បីកុំឲ្យមានការគុំគួននឹងអង្គការ។ បន្ទាប់មកគេនាំអ្នកទោសហ្នឹងទៅកន្លែងសម្លាប់។ នៅពេលដែលគេសម្លាប់នោះ គេៗគេកាប់ឈើ គេចាក់មីក្រូ ចាក់ភ្លេង ដើម្បីកុំឲ្យឮសំឡេងអ្នកទោសស្រែក"។ សូមបញ្ចប់ការដកស្រង់។ លោកបានឆ្លើយបញ្ជាក់រួចមកហើយ ពាក់ព័ន្ធនឹងចំណុចនេះ ក៏ប៉ុន្តែខ្ញុំចង់សួរលោកមួយចំណុចម្តងៗ ពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក។ ជាដំបូងនោះ ក្នុងសំណុំឯកសារនោះ លោកនិយាយថាជួនកាលនោះ លោកត្រូវយាមអ្នកទោស ក៏ប៉ុន្តែលោកអត់មានកាំភ្លើងទេ។ លោកអាចបញ្ជាក់បានទេថានៅពេលណា ហើយនៅកន្លែងណាដែលលោកយាមអ្នកទោសនោះ?

[១៥:៤៤:១៥]

**ឆៈ** បាទបញ្ជាក់បាន។ ឧទាហរណ៍ថា ខ្ញុំចូលគុក ដល់ពេលចូលនុង ដាក់គេហើយអស់អ៊ីចឹងទៅដល់ដាក់ខ្លួនឯង។ មុនដំបូងអត់ទាន់ដាក់ខ្លួនឯងទេ ចូលរាប់គេ រាប់មួយជួរមានប៉ុន្មាន មួយជួរមាន ២៥ ឬមួយជួរ៣០។ បើអ៊ីចឹងប្រធានគេ ឬកងទ័ពអីឈរនៅមាត់ទ្វារថា "ប៉ុន្មាន? អ្អែងរាប់ឃើញប៉ុន្មាន?" ថា "២៥ បង"។ "ចុះអាជើងប៉ុន្មាន" "អាជើង៣២" អ៊ីចឹងទៅបាទ បាទ៣២។ "ហើយខ្លួនអ្អែងរាប់នៅ?" ថា "ខ្ញុំអត់ទាន់រាប់ខ្លួនឯងផង ព្រោះខ្ញុំអត់ទាន់ដាក់ផង រាប់ធ្វើអីខ្លួនឯង" ខ្ញុំថាអ៊ីចឹងបាទ។

**សៈ** សូមអរគុណ។ ចុះការយាមអ្នកទោសហ្នឹង លោកមានតួនាទីអីទេ? ឧទាហរណ៍ថាលោកនាំអ្នកទោសទៅកន្លែងណាមួយ ឬក៏នាំទៅកន្លែងធ្វើការ អ៊ីចឹងខ្ញុំចង់ដឹងថាតួនាទីលោកដែលជាអ្នកយាមអ្នកទោសម្តងម្កាលហ្នឹង លោកធ្វើយ៉ាងម៉េចដែរ?

**ឆៈ** បាទ អាហ្នឹងគេហៅថា ស្ទួងៗគ្នាប្រាំពីរអ៊ីចឹង ហើយដល់កងទ័ពហ្នឹងវាមានបញ្ហាច្រើន ការងារច្រើន នាំអ្នកទោសមកច្រើនអ៊ីចឹង គ្រប់កន្លែងអ៊ីចឹងមក គេត្រូវទទួលអ្នកទោសនៅក្នុងគុកអ៊ីចឹង ខ្ញុំនៅស្រែខាងក្រៅហ្នឹង របងគុកខាងក្រៅហ្នឹង ថា "អ្អែងនៅហ្នឹងមើលៗមនុស្ស" "បាទ គ្មានទៅណាទេបង រត់ក៏មិនដឹងរត់ទៅណាដែរ រត់រួចអី"។ "អីអ្អែងមើល អ្អែងប្រយ័ត្នបាត់ តែបាត់មួយអ្អែងអត់រស់ទេអ្អែង"។ ហ្នឹងបានមើលមែនបាទ។

[១៥:៤៥:៥៧]

**ស៖** ចុះកន្លែងធ្វើការរបស់អ្នកទោសទាំងអស់ហ្នឹងនៅក្នុងបរិវេណទី១ហ្នឹង ឬក៏ឆ្ងាយពី -- នៅឧទាហរណ៍ដូចជានៅក្នុងបរិវេណទី២ ឬទី៣?

**ឆ៖** បាទធ្វើការចេញតែរបងទី១ ហើយរបងទី២ នៅក្រៅ នៅក្នុងរបងទី១ ខាងក្រៅ។ មានរបងមួយជាន់ខាងក្រៅមួយទៀត ប៉ុន្តែរបងរង្វើលនៅក្រៅ របងត្បាញលួសរង្វើលៗអីហ្នឹង។

**ស៖** សូមអរគុណអម្បាញ់មិញនេះលោកឆ្លើយថាលោកត្រូវរាប់ចំនួនអ្នកទោស។ ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេគឺថា រាប់អ្នកទោសនៅក្នុងផ្ទះឃុំឃាំងដែលលោកស្នាក់នៅ។ គឺអ៊ីចឹងមែនទេ?

**ឆ៖** បាទ រាប់ក្នុងគុក។ ពេលថ្ងៃល្ងាចឡើង តែបញ្ចូលគេត្រូវរាប់ រាប់មនុស្សឃើញប៉ុន្មានមួយជួរ។ ហើយត្រូវរាប់ហើយមួយសាហ្នឹង ដល់១ម៉ោងក្រោយរាប់មួយសាទៀត ១ម៉ោងក្រោយអាហ្នឹងវាចូលរាប់ខ្លួនវា ហ្នឹងកងទ័ពចូលរាប់ខ្លួនឯងព្រោះវាដូរក្នុង១ម៉ោងដូរគ្នាម្តងៗ បាទ។

**ស៖** តើនៅក្នុងផ្ទះឃុំឃាំងលោកហ្នឹងមានអ្នកទោសប៉ុន្មាននាក់ដែរ?

**ឆ៖** បាទអត់ទៀងទេ ជួនកាលខែហ្នឹងមានច្រើនអ៊ីចឹង គេយកចេញទៅអស់អ៊ីចឹងទៅ នៅសល់ប្រហែល១០នាក់អ៊ីចឹងទៅ សល់២០នាក់អ៊ីចឹងទៅ។ ចុះល្ងាចឡើងចូល២០, ៣០ទៀតទៅ ស្អែកឡើងយកចេញអស់ទៀត ស្អែកខានស្អែកឡើងចូល២០, ៣០នាក់ទៀត អត់ទៀងទេកន្លែងហ្នឹង កន្លែងចេញចូលៗ ចេញចូលរហូតអត់ទៀងបាទ។

**ស៖** លោកបាននិយាយជាច្រើនរួចមកហើយថា ក្រោយខែមេសា ឆ្នាំ៧៥ហ្នឹង មានការសម្លាប់អ្នកទោសក្នុងទ្រង់ទ្រាយធំ។ តើនៅក្នុងពេលនោះហ្នឹង ផ្ទះឃុំទាំងបួនហ្នឹង មានកន្លែងសម្រាប់ដាក់មនុស្ស សម្រាប់ដាក់អ្នកទោសគ្រប់គ្រាន់ដែលមកមន្ទីរក្រាំងតាចាន់ហ្នឹងដែរ?

[១៥:៤៨:៤៩]

**ឆ៖** បាទមានៗអ្នកទោសដែលនៅជាប់ៗហ្នឹង ដូចថាៗឧទាហរណ៍ដូចខ្ញុំអ៊ីចឹង វាប្រជាជនមូលដ្ឋាន កាលណាមូលដ្ឋានជាប់បានយូរៗ។ បើថា ១៧មេសាហ្នឹងជាប់អត់បានយូរទេ បើជួនកាលយកទៅដល់អ៊ីចឹង ដូចថាអ្នកល្បីៗឈ្មោះអ៊ីចឹង យកទៅថ្ងៃល្ងាចអ៊ីចឹងៗ ថ្ងៃល្ងាចយកទៅសម្លាប់ចោល។ ឧទាហរណ៍ដូច គីម ណូវ៉ា, ណុប ណែម អ៊ីចឹងគាត់ ខ្ញុំបានស្គាល់ដោយសារប្រធានមន្ទីរហ្នឹងគាត់អ្នកប្រាប់ខ្ញុំ គាត់ថា “អ្នែងស្គាល់ទេ?” ខ្ញុំថា “អត់បង”។ “ហ្នឹងហើយ ណុប ណែម តួកុនពីមុនមក” ខ្ញុំថា “ខ្ញុំអត់ដែលស្គាល់អត់ដែលដឹងផង ឮតែឈ្មោះ”។ ហើយដល់ហើយយកប្តីទៅសម្លាប់ទៅ នាំប្តីទៅបាត់

ទៅគាត់នៅញ៉េះញ៉េាះជាមួយប្រពន្ធ ណុប ណៃម ហ្នឹង ខ្ញុំនៅអង្គុយបោសសម្រាមបោសអីនៅក្បែរគាត់ហ្នឹង បោសសំរាម ធ្វើបោសសំរាមអីនៅកន្លែងក្បែរគាត់ហ្នឹង។ គាត់នៅញ៉េះញ៉េាះដូចឆឹកនាយឆឹកអាយឆឹកថ្កាល់អី គីម ណូវ៉ា អ៊ីចឹងញ៉េះញ៉េាះហ្នឹង ហើយកូនចេះតែសួរថា៖ "ប៉ាទៅដល់ណាយូរម្ល៉េះម៉ាក់? ប៉ាទៅណាយូរម្ល៉េះម៉ាក់?" គាត់ថា "អ្ហឺ! ប៉ាអ្នែងមកដល់ឥឡូវហើយៗ"។ ចាប់យកទៅសម្លាប់មួយសន្ទុះហើយ បកមកវិញហើយមកយកប្រពន្ធទៅអ៊ីចឹង ទៅជួបគ្នាមូលគ្នា មូលគ្រួសារគ្នា "តោះជួបប្ដីជួបប្រពន្ធ" ក៏ទៅយកទាំងអស់ហ្នឹងទៅបាន។ អាហ្នឹង គីម ណូវ៉ា ហ្នឹងខ្ញុំឃើញជាក់ស្ដែងភ្នែកហ្នឹងតែម្ដង។ ប្រហែលជាសម្លាប់មិនអាច មិនភ្លេចទេ ខ្ទង់ប្រហែលជាម៉ោងបួនល្ងាច បាទអត់ភ្លេចទេ។

[១៥:៥០:១១]

**ស៖** ខ្ញុំដូចជាស្ដាប់មិនសូវយល់ ពាក់ព័ន្ធទៅនឹងការសម្លាប់នេះទេ។ នៅពេលដែលត្កុកនទាំងពីរទៅដល់ហ្នឹង តើគេដាក់ឲ្យស្នាក់នៅក្នុងផ្ទះហ្នឹង ឬក៏គេយកទៅសម្លាប់ចោលតែម្ដង ដោយគាត់មិនបានស្នាក់នៅក្នុងផ្ទះនុ៎ងទេ?

**ឆ៖** បាទ អត់ទេ។ គ្រាន់តែបញ្ជូន ណុប ណៃម ទៅដល់ភ្លាម ខ្ញុំក៏អត់ស្គាល់ទេ បាទ ម្ដងហើយម្ដងទៀត។ ខ្ញុំក៏អត់ស្គាល់ដែរ គាត់ទេអ្នកនិយាយប្រាប់ ប្រធានមន្ទីរគាត់អ្នកប្រាប់ផ្ទាល់តែម្ដង។ គ្រាន់តែទៅដល់ភ្លាមគាត់ថា "អ៊ីចឹង ណុប ណៃម ទៅជួបអង្គការមួយភ្លែត"។ ទៅជួបអង្គការមួយភ្លែត នាំទៅកន្លែងសួរចម្លើយ យក ណុប ណៃម ទៅសម្លាប់ ហើយប្រពន្ធនៅសល់នៅកន្លែងប្រធានមន្ទីរ នៅកន្លែងតាអាន់ នៅក្បែរកន្លែងគុកខ្ញុំហ្នឹង នៅអង្គុយនិយាយកន្លែងគុក តាអាន់ នៅកន្លែងគុកខ្ញុំមុខការិយាល័យរបស់ តាអាន់ ហ្នឹង តាអាន់ គាត់សម្រាន្តហ្នឹង។ គាត់ចេះតែញ៉េាះលិចញ៉េាះកើត សួរអ៊ីចេះសួរអ៊ីចុះអីគាត់លូកដៃលើក្រោមអីនៅហ្នឹង គាត់ថា ដល់ហើយបានយកទៅអស់អ៊ីចឹងបានគាត់ប្រាប់ខ្ញុំថា៖ "ហ្នឹងហើយ ណុប ណៃម ត្កុកនពីដើម អ្នែងមិនដែលស្គាល់ទេ"។

[១៥:៥១:៣៣]

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់។ ខ្ញុំសួរចង់ដឹងថាតើអ្នកទាំងពីរហ្នឹង ឬក៏ក្រុមមនុស្សផ្សេងទៀតនោះចូលទៅដល់ក្រាំងតាចាន់ត្រូវបានគេសម្លាប់ចោលភ្លាមតែម្ដង ឬក៏គេឲ្យស្នាក់នៅក្នុងផ្ទះអ្នកទោសហ្នឹងប៉ុន្មានយប់សិនមុននឹងគេយកទៅសម្លាប់ចោល?

**ឆ៖** វាមានពីរប្រភេទ។ បើប្រជាជនមូលដ្ឋាន ហ្នឹងបាននៅសួរចម្លើយឆ្លងនេះឆ្លងនោះយូរហើយបើជា ១៧ហ្នឹង គេថា ជាស័ក្ដ៣ ស័ក្ដ៤ មេទាហានអីចេះចុះអី ហ្នឹងខ្ញុំអត់បានដឹងទេ ខ្ញុំអត់បាន

ស្នាក់យូរទេ។ យ៉ាតយឺតផុតអស់របឹតក្នុងរយៈកាលមួយអាទិត្យ រយៈកាលមួយអាទិត្យត្រូវបាត់ខ្លួនអស់ហើយ ហើយបើនៅហ្នឹងក៏នៅពាក់ព័ន្ធ ឧទាហរណ៍ថានៅប្រជាជន១៧នៅ ម្នាក់ពីរនាក់នៅពាក់ព័ន្ធពីបញ្ហាផ្សេងៗហ្នឹងខ្ញុំអត់បានដឹងទេ ហ្នឹងគេទុកបានខ្លះ នៅ១៧ នៅខ្លះ ប៉ុន្តែនៅៗតែស្លាប់ដដែល ប៉ុន្តែទុកបានយូរខ្លះ យូរយ៉ាងម៉េចមួយម៉េចពីរ ខ្ញុំអត់បានដឹងទេកន្លែងហ្នឹងនោះ។

**ស៖** ពាក់ព័ន្ធប្រជាជន ១៧មេសា តើមានអ្នកខ្លះនុ៎ង មិនបានដេកនៅក្នុងគុកទេ ពីព្រោះថានៅក្នុងគុកហ្នឹងមានមនុស្សច្រើនណាស់ទៅហើយ។ មានអ៊ីចឹងទេ?

**ឆ៖** អត់ទេ អត់អ៊ីចឹងទេ។ កាលណា៧មេសា ដែលខ្ញុំបានប្រាប់គាត់ពីមុនមកហ្នឹងថា ឧទាហ-រណ៍ថាអ្នកធំៗបានយកមកដល់អត់ចូលគុកទេ ត្រូវដាក់នៅអង្គុយតុខាងក្រៅ ឬធ្វើនៅកន្លែងផ្ទះខាងក្រៅ អត់មានប្រជាជនទេ មានតែផ្ទះទេ មានតែពួកវាទៅទទួលនៅខាងក្រៅហ្នឹងកាប់ដូងខ្ចីកាប់អីទទួលនៅខាងក្រៅហ្នឹង ថាលោកនេះលោកនោះអ៊ីចឹងទៅ ហើយយកមកកងទៅសិនទៅ ហ្នឹងបានគេអ្នកធំៗ ដូចថា ខ្ញុំបានស្គាល់ដូចថា តាឈួនៗ និង តាចិន ហ្នឹងគាត់ប្រាប់ខ្ញុំថា "ហ្នឹងមេទាហានព្រៃស្ដែក តាស្រមូមអី តាសង្គ្រាជ ប៉ាញ អ៊ីចឹង ហ្នឹងដូចថាគាត់មេទាហានអ៊ីចឹងណ៎ា។ ហ្នឹងបានស្គាល់ដោយសារតាចិន ហ្នឹង បាទ គាត់ប្រាប់ ហើយគេដាក់នៅខាងក្រៅៗហើយ យកមកដល់ៗក្នុងគុកហើយគេបណ្ដើរទាំងខ្សែយកចេញទៅក្រៅ អត់បានយកបញ្ចូលគុកទេហ្នឹងអត់បានចូលទេ ដូច ណុប ណែម ដូចគ្នា។

[១៥:៥៤:១០]

**ស៖** សូមអរគុណច្រើនលោក។ នៅសល់ប៉ុន្មាននាទីចុងក្រោយនេះ ខ្ញុំចង់និយាយអំពីបែបបទក្នុងការនាំអ្នកទោសយកទៅសម្លាប់នៅក្នុងសម្រង់ដែលខ្ញុំបានអាននោះ គឺលោកបញ្ជាក់ថា មានការដោះខ្នោះនិងនាំចេញពីផ្ទះឃុំហ្នឹង ហើយបន្ទាប់មក ពេញ ហ្នឹងហៅឈ្មោះអ្នកទោសដែលត្រូវយកទៅសម្លាប់ចោល ហើយគាត់ប្រាប់អ្នកទោសហ្នឹងថា "គេនាំទៅសហករណ៍ទេ ឬក៏នាំទៅផ្ទះ" ហើយនៅពេលដែលញប្រកាសថាគេឲ្យគាត់ទៅសហករណ៍អ៊ីចឹង អ្នកទោសគាត់មានប្រតិកម្មយ៉ាងម៉េចដែរពេលនុ៎ង?

**ឆ៖** បាទខ្លះក៏ដឹង ក៏ស្រងូតស្រងាត់ ខ្លះដែលអត់ដឹងទះដៃផុរក្នុងគុកហ្នឹង។ បានរួចទៅផ្ទះ ទះដៃផុរទាំងគេទាំងខ្ញុំអី មុនដំបូងទាំងអស់គ្នាហ្នឹងអត់ដឹង។ បើអ្នកដឹង រាងមុខស្រងូតស្រងាត់បាទ។

**ស៖** ក្នុងសម្រង់ដែលខ្ញុំបានអានអំម្បាញ់មិញនេះមានការបញ្ជាក់ថាបន្ទាប់មកគេនាំអ្នកទោសទៅកន្លែងសួរចម្លើយ។ តើលោកអាចប្រាប់ខ្ញុំបានទេ តើអ្នកណាជាអ្នកនាំអ្នកទោសទាំងអស់ហ្នឹងទៅកន្លែងសួរចម្លើយ? ហើយអ្នកណាជាអ្នកៗចងដៃនិងបិទមុខ មានអ្នកយាមជាក់លាក់ទេសម្រាប់ការងារហ្នឹង?

**ឆ៖** បាទ គេនាំទៅសួរចម្លើយ គេយកទៅតែម្តងតែម្នាក់ទេ សួរចម្លើយ។ អត់ដែលសួរពីរនាក់ទេ សួរម្តងម្នាក់ៗ។ សួរម្តងម្នាក់ តាចេង គាត់អ្នកដឹកនាំ។ តាចេង បើអត់តាចេង តាពេញគាត់មកនាំអ៊ីចឹងគាត់មកហៅឈ្មោះ បើកទ្វារ ដកខ្នោះសោហូតខ្នោកចេញមកមួយមក ថាឈ្មោះអី ឈ្មោះ “ក” ក៏ចេញមកមួយមក ហើយដកចូលខ្នោះមកវិញមកអ្នកនៅក្នុងហ្នឹង ចូលខ្នោះវិញអត់ អត់មានឲ្យលែងខ្នោះទេ ដាក់ខ្នោះហើយ បានយកអ្នកនោះចេញទៅ។ ចេញទៅម្តងមួយៗ សួរប្រហែលរយៈកាល ១ម៉ោង ឬក៏១ម៉ោងជាង បានហើយបានអ្នកណាដែលឆ្លើយត្រង់ក៏បានរួចមកវិញ។ អ្នកណាមិនឆ្លើយត្រង់ ក៏គេវាយធ្វើទារុណកម្ម ដេកដួល ដើរមិនរួច មកមិនរួច នៅទន់រលីករលាក់នៅហ្នឹង បានគាត់មកផ្ទះ -- មកកន្លែងអស់មក គាត់ប្រាប់ថាខ្ញុំហើយនិងតាចិនថា “អ្អែងទៅត្បូងយកទុកអ្នា!” គ្រាន់ថាប៉ុណ្ណឹងទេ គាត់អត់មានប្រាប់ថាមនុស្សធំ “អ្អែងទៅត្បូងយកមកទុកមក”។ ថាអ៊ីចឹង ខ្ញុំទៅត្បូងពីរនាក់តាចិន ទៅក្រៀកយកមក ខ្ញុំវាតូចជាងគេ។ កាលណាវាយរហូតដល់ស្លាប់ទៅ ខ្ញុំក៏អត់លើករួចដែរ ខ្ញុំបានតែកាន់ដៃក្រោយក្បាលពីក្រោយអូសនឹងដីអ៊ីចឹង តាចិនគាត់អូសជើងពីរទៅអ៊ីចឹងទៅ ក្បាលក្រោយខ្ញុំបានតែកាន់ដៃឡើងលើធ្វើអ៊ីចឹងតិចៗ ព្រោះខ្ញុំតូចជាងគេ ខ្ញុំមិនបានសែងរួចទេ ប៉ុនបានតែពីរនាក់តាចិន ហ្នឹងបាទ។

[១៥:៥៧:០៧]

**ស៖** សូមអរគុណ។ ខ្ញុំគិតថាប្រហែលជាមានការភ័ន្តច្រឡំបន្តិចលោក។ ក្នុងសម្រង់ដែលខ្ញុំអាននោះ ខ្ញុំនិយាយអំពីបែបបទនៃការសម្លាប់ គឺក្នុងនោះមានជំហានមួយ គឺគេនាំទៅកន្លែងសួរចម្លើយសិនដើម្បីចងដៃបិទភ្នែក។ ខ្ញុំមិននិយាយអំពីការសួរចម្លើយទេ។ ខ្ញុំគ្រាន់តែចង់ដឹងពីជំហាននាំយកទៅកន្លែងសម្លាប់។ លោកអាចប្រាប់បានទេថា ចំពោះក្មេងៗ តើគេមានចងដៃបិទភ្នែកបិទមុខដូចមនុស្សធំទេ មុននឹងយកទៅសម្លាប់ចោលនោះ។

**ឆ៖** បាទ ក្មេងគឺខ្ញុំមិនអាចឃើញផ្ទាល់។ ឃើញផ្ទាល់តែម្តងដោយសារគេវះយកប្រមាត់ ខ្ញុំនៅលើចុងត្នោត បានឃើញតែម្តងហ្នឹងទេ ក្មេងបាទ។ ក្រៅពីហ្នឹងទៀត ខ្ញុំអត់ដែលឃើញ មិនដឹងគេសម្លាប់របៀបរបបម៉េច ខ្ញុំអត់ដឹងទេ។ បើមនុស្សចាស់ ខ្ញុំឃើញតែចងដៃៗចងមុខ ដល់ក្មេង ខ្ញុំអត់បានឃើញបាទ។

**ស៖** ចុះមនុស្សធំ លោកអាចប្រាប់ឈ្មោះទាហាន ឬក៏អ្នកយាមដែលនាំអ្នកទោសយកទៅសម្លាប់នោះ។ លោកបានរៀបរាប់អ្នកយាមមាន១២នាក់។ លោកអាចប្រាប់ថាអ្នកទាំង១២ហ្នឹងជាអ្នក

សម្លាប់តែម្តង ឬក៏មានមនុស្សតែមួយចំនួនទេជាអ្នកសម្លាប់នោះ?

**ឆ៖** បាទ ខ្ញុំនៅហ្នឹងរយៈកាលយូរឆ្នាំមកហើយ ខ្ញុំអាចដឹង។ គឺឲ្យតែនៅកន្លែងហ្នឹង គឺអត់ដែលឃើញសម្លាប់គឺមានតែប្រធានមួយទេ។ ប្រធាននៅពេលដែលគេសម្លាប់ គាត់ស្លៀកពាក់ខោខ្លីមួយឈ្នួតក្បាលមួយយ៉ាងធំ លីកាំបិតដើរសងខាងរបង គាត់ដើរអារុងខាងរបងៗ។ បើក្រៅពីហ្នឹង ទូទៅទាំងអស់ឲ្យតែនៅកន្លែងហ្នឹងជាកងទ័ព គឺទូទៅទាំងអស់ ឲ្យតែកងទ័ពនៅកន្លែងហ្នឹងបាទ។

[១៥:៥៩:២៥]

**សៈ** លោកបាននិយាយថាលោកត្រូវកាប់ឈើ ឬក៏ចាក់ភ្លេងនៅពេលគេសម្លាប់។ អ៊ីចឹងលោកអាចប្រាប់បានទេថាកន្លែងដែលគេចាក់ភ្លេងហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** បាទ មុខៗដែលមាត់ទ្វារចូលគុកអ៊ីចឹង ពេលបើកមាត់ទ្វារអ៊ីចឹង មានដើមស្វាយកន្លែងចង្ក្រានបាយអ្នកទោសប្រហែលជាឃ្លាតពីកន្លែងគុកហ្នឹងប្រហែលជាដីចំនួនប្រហែល៥ម៉ែត្រ គឺចងមីក្រូកញ្ចាញមីក្រូមួយសំដៅនៅចំមាត់គុកហ្នឹង ហើយខ្ញុំគេឲ្យពុះឧស កាត់ឧសខ្លីៗអាមែកដើមពង្រ ហើយដើមឈើទាលហ្នឹង កាត់មែកខ្លីៗយកមកកាប់ចិញ្ច្រាំអ៊ីចឹងទៅ ចេះតែកាប់ប៉ិកប៉ុកៗអ៊ីចឹងទៅ ធ្វើម៉េចពេលគេយកទៅកាប់ មើលដំណើរថាគេជិតដល់ហើយបានបង្ខំពុះឧសនេះ ហើយមីក្រូចាក់ឲ្យឮទៀត។ តែប៉ុណ្ណឹង ប៉ុន្តែមិនមែនចាក់មីក្រូ ជំនាន់នោះថាគេហៅ “ម៉ាញ៉េតូ” – ចាក់ម៉ាញ៉េតូ។ បានដាក់ដោតកញ្ចាញមីក្រូ ចាក់ម៉ាញ៉េតូ។

**សៈ** អ៊ីចឹងម៉ាញ៉េហ្នឹង មីក្រូហ្នឹង គេដាក់បែរទៅខាងអ្នកទោស ឬក៏ដាក់បែរមកខាងកន្លែងសួរចម្លើយ?

**ឆ៖** បាទ អត់មានដាក់ទៅកន្លែងសួរចម្លើយ ដាក់នៅចំផ្ទះអ្នកទោសនៅតែម្តង។ ចាក់ចំមាត់ទ្វារអ្នកទោស មិនឲ្យឮសូរសំឡេងពីត្បូងមក។

**សៈ** សូមអរគុណ។ ដូច្នេះ បើខ្ញុំស្តាប់មិនច្រឡំទេ គឺថាលោកត្រូវជីករណ្តៅ ហើយត្រូវចាក់ភ្លេងនៅពេលដែលមានការសម្លាប់។ អ៊ីចឹងមុនពេលដែលសម្លាប់នុ៎ង តើប៉ុន្មានដែរ ប៉ុន្មានម៉ោងដែរមុនពេលដែលគេសម្លាប់នុ៎ង ដែលគេបញ្ជាឲ្យលោកទៅជីកផ្នូរនុ៎ង -- ជីករណ្តៅ (សូមទោស)?

[១៦:០១:៣៧]

**ឆ៖** បាទ អត់កំណត់ម៉ោងទេ។ ឧទាហរណ៍ថា សម្លាប់ថ្ងៃល្ងាចហ្នឹង ពេលព្រឹកនេះ ឲ្យខ្ញុំតាចិន ហើយនិងតានន ពីរបីនាក់ ទៅជីកបីនាក់។ ទៅជីកថា -- គេទៅដល់ កងទ័ពមួយនៅហ្នឹងដែរ។

កងទ័ពនៅហ្នឹងគេអត់ជីកទេ គ្រាន់អង្គុយមើលយើងធ្វើហ្នឹង ថា "ជីកអានេះដល់នេះៗ"។ អ៊ីចឹងគេយកទទឹងបណ្ដោយអីប៉ុណ្ណឹង គេគូសដីប្រាប់យើងជម្រៅប៉ុន្មានៗគេប្រាប់ថា "អឺ! ជីកប្រវែងហ្នឹងបានហើយ ថាជម្រៅត្រឹមកអ្នែង ឬក៏ជម្រៅត្រឹមចង្កេះអ្នែង" អ៊ីចឹងគេប្រាប់អ៊ីចឹង ហើយគេ "បានហើយៗ ឲ្យឡើងមកវិញ" ឡើងមក។ គេថា គេទៅមើលដែរ មិនជីក ចេះតែជីកចិត្តឯងអត់ទេ។ គេនៅមើលនៅហ្នឹងដែរ។

**ស៖** ប្រសិនបើការសម្លាប់ហ្នឹងនៅពេលល្ងាច អ៊ីចឹងតើលោកចេញពីផ្ទះឃុំឃាំងហ្នឹង ដើម្បីលុបៗរណ្ដៅហ្នឹងវិញ ឬក៏ត្រូវតែទៅចាំដល់ស្អែកឡើងនោះទេ បានៗត្រូវលុបរណ្ដៅនុ៎ង?

**ឆ៖** បាទ កាលណាគេពួកវាវៃហើយអ៊ីចឹង គេលុបហើយៗអស់ហើយ។ លុះត្រាតែជង្ហុកណាជ្រៅ ហើយជ្រៅអ៊ីចឹងវៃហើយ ឧទាហរណ៍ថាជង្ហុកហ្នឹងត្រូវដាក់ចំណុះប៉ុន្មាន ឧបមាថាខ្ញុំជីកបានប៉ុន្មាន ថាលិចមួយក្បាលខ្ញុំ។ លិចមួយក្បាល អ៊ីចឹងវៃបានតែ៣០នាក់ទេ អ៊ីចឹង៣០នាក់ វាអត់ពេញៗគេលុបចោលហ្នឹងហើយដល់ពីរបីថ្ងៃវាហើម ដល់ហើមវាប្រេះដី ដល់ប្រេះដីវាចេះតែស្អុយភាយចេញមកកន្លែងក្លិន កន្លែងយើងនៅខ្លាំងទៅៗ ប្រធានមន្ទីរគាត់ហៅខ្ញុំថា "អាសែន!" បាទ។ ហ៊ឺះ!ៗ អ្នែងទៅត្បូងបន្ដិចទៅ!" គាត់ធ្វើតែហ៊ឺះៗប៉ុណ្ណឹងទេ ឲ្យខ្ញុំទៅត្បូង ដល់ខ្ញុំទៅត្បូង ខ្ញុំដឹងថា គាត់ឲ្យខ្ញុំទៅជាន់បង្ហាប់ខ្មោចហ្នឹងកុំឲ្យវាផ្ទុះឡើងបាទ។ ជាន់បោះដីបោះអីថែម តែប៉ុណ្ណឹងទេ។ ដល់ថ្ងៃក្រោយឡើង ខ្មោចហ្នឹងវាស្រុតទៅ វៃពីលើហ្នឹងថែមទៀត ថែមក្រលុកហ្នឹងទៀតបាទ។

[១៦:០៣:៤២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ ឥឡូវនេះ ដល់ពេលត្រូវសម្រាកនៅពេលល្ងាចហើយ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែកចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ អង្គជំនុំជម្រះសូមអរគុណចំពោះលោក សយ សែន ហើយដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកនៅក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី នៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យលោកមកបន្តផ្ដល់សក្ខីកម្មនៅព្រឹកថ្ងៃស្អែកទៀត ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក ហើយលោកអាចវិលត្រឡប់ទៅកាន់ទីកន្លែងដែលលោកស្នាក់នៅវិញបានហើយ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនលោក សយ សែន វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ

ហើយនិងសូមអញ្ជើញគាត់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅថ្ងៃ នៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។

ហើយអង្គជំនុំជម្រះក៏អរគុណ ហើយនិងក៏អញ្ជើញលោកដែលជាបុគ្គលិកអង្គការ ធី.ភី.អូ មកបន្តអង្គុយអមដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីជាជំនួយពង្រឹងស្មារតីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅសវនាការថ្ងៃស្អែកទៀតដែរ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*